# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

---

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៧ លេខ ១១ ខែ វិច្ឆិកា

ព. ស. ២៥០៧ គ. ស. ១៩៦៥

– ភ្នំពេញ –

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

១– សេចក្ដីអធិប្បាយ អំពី នរក សួគ៌ និព្វាន អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង ១១១០

*ផ្នែកអក្សរសាស្ត្រ*

២– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . ១១៤៩
៣– ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . ១១៥១
៤– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឱ. គាម ស្រាវជ្រាវ (ត) . . . . . ១១៧១
៥– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង(ត) . . . ១១៨៧
៦ – កំណត់ហេតុអនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃទី ២១ ឆ្នាំ ១៩៦៥ . . . ១១៩១
៧– ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ ក្នុងឆមាសទី ១ ឆ្នាំ ១៩៦៦ . . . ១២០៤
៨– សេចក្ដីកត់ហេតុ ទី ៣ . . . . . . . . . . . ១២១៤
៩– សេចក្ដីកត់ហេតុ ទី ៤ . . . . . . . . . . . ១២២១
១០– សេចក្ដីកត់ហេតុ ទី ៥ . . . . . . . . . . . ១២២៦

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០រ៛០០ ។

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

# នរក សួគ៌ និព្វាន

អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រី

រៀបរៀង

## ភាគទី ១ ស្ដីអំពីនរក

សេចក្ដីអធិប្បាយ

### ១– អំពីផ្លូវនរក

ទុគ្គតិ ទុកជាផ្លូវនរក ឬ ផ្លូវអបាយ ពីព្រោះទុគ្គតិ បានដល់ផ្លូវជាទីនាំទៅកាន់កំណើតអាក្រក់ ក្នុងអបាយភូមិ ៤ គឺ នរក ប្រេត អសុរកាយ និង តិរច្ឆាន ។

រីឯបាបកម្ម ទុកជាហេតុនៃទុគ្គតិ ពីព្រោះបាបកម្មដែលមនុស្សបានធ្វើហើយដោយចេតនា តែងប្រែក្លាយទៅជា អបាយបរាយណកម្ម គឺអំពើបម្រុងតែនឹងនាំអ្នកធ្វើ ឲ្យទៅកើតក្នុងអបាយភូមិ ៤ ណាមួយ មិនខានឡើយ ។

រីឯបាបកម្ម គឺអំពើបាបនោះ សំដៅយកចំពោះទុច្ចរិត ១០ ឬអកុសល-
កម្មបថ ១០ មានកាយទុច្ចរិត ៣ គឺការសម្លាប់សត្វ ១ ការលួច
ទ្រព្យគេ ១ ការប្រព្រឹត្តខុសក្នុងកាម ១ ជាដើមនោះឯង ។

ឯទុច្ចរិត ១០ មានកាយទុច្ចរិត ៣ ជាដើមនោះ ទុកជា អាចិណ្ណ-
កម្ម គឺកម្មដែលមនុស្សធ្លាប់សន្សំឬធ្លាប់បានប្រព្រឹត្តជារឿយ ៗ នោះ ។

ក្រៅពីបាបកម្មដែលជាអាចិណ្ណកម្មនោះ មានបាបកម្មធ្ងន់ជាទីបំផុត
៥ យ៉ាងទៀត ឈ្មោះថា អនន្តរិយកម្មគឺ

១. មាតុឃាត ការសម្លាប់មាតា,

២. បិតុឃាត ការសម្លាប់បិតា,

៣. អរហន្តឃាត ការសម្លាប់ព្រះអរហន្ត,

៤. លោហិតុប្បាទ ការធ្វើព្រះលោហិតរបស់ព្រះពុទ្ធឲ្យពុះពង,

៥. សង្ឃភេទ ការបំបែកសង្ឃ ។

រីឯបាបកម្ម កាលបើបុគ្គលណាបានប្រព្រឹត្ត ដោយចេតនាហើយ
តែងតែផ្តល់ឲ្យបុគ្គលនោះ នូវទោសផ្សេង ៗ តាមកម្លាំងផលនៃបាបកម្ម
ដែលខ្លួនធ្វើមិនខានឡើយ ។

រីឯទោសនៃបាបកម្មនោះ គឺសំដៅចំពោះទោស ៥ យ៉ាងនៃទុច្ចរិត
ដូចតទៅនេះ ៖

១. សូម្បីខ្លួនឯង ក៏តិះដៀលខ្លួនឯងបាន,

២- បណ្ឌិតតែងតិះដៀល,

៣- តែងបានកិត្តិស័ព្ទអាក្រក់ផ្សាយទៅសព្វទិស,

៤- តែងវង្វេងក្នុងពេលធ្វើមរណកាល,

៥- បន្ទាប់ពីធ្វើមរណកាល តែងបានទៅកើត ក្នុងអបាយ ៤ ណាមួយ មិនខានឡើយ ។

ទោស ៤ ខាងដើម ទុកជា ទិដ្ឋធម្មិកផល គឺផលដែលកើត ឲ្យឃើញជាក់ស្តែង ក្នុងបច្ចុប្បន្ននេះ ហើយទោសទី ៥ នោះ ទុកជា សម្បរាយិកផល គឺផលដែលនឹងកើតជាក់ស្តែងឡើង ទៅក្នុង បរលោកឯណោះ ។

កាលបើទោសទី ៥ នោះ មិនទាន់មានកម្លាំងខ្លាំងក្លា អាចញ៉ាំង បុគ្គលអ្នកប្រព្រឹត្ត នូវបាបកម្ម ឲ្យទៅកើតក្នុងឋាននរកទេ បុគ្គលនោះក៏គង់ បានកំណើតអាក្រក់ក្នុងឋានមនុស្សមិនខានឡើយ គឺបុគ្គលនោះតែងបាន កើតជា មនុស្សប្រេតោ គឺមនុស្សប្រេត ឬជា មនុស្សតិរច្ឆានោ គឺមនុស្សតិរច្ឆាន ឬជា មនុស្សនេរយិកោ គឺមនុស្សនរក ឬជា ទុគ្គតមនុស្សោ គឺមនុស្សខ្វត់ខ្វាយទ្រព្យ បើពុំនោះសោតទេ ត្រូវ បានកើតជាសត្វតិរច្ឆាន ឬជាអសុរកាយ តាមកម្លាំងផលនៃបាបកម្ម មិនខានឡើយ ។

រីឯអសុរកាយនោះ វចនានុក្រមបានប្រាប់ថា ជាអបាយសត្វកើត អាស្រ័យនៅក្នុងមនុស្សលោក ច្រើនត្រាច់ក្នុងវេលាយប់គេស៊ីអសុចិវត្ថុ

មានគម្រង់ជាដើម ជួនកាលពួកខ្លះលង់បន្ទាចមនុស្សក៏មាន ខ្លះអាស្រ័យនៅទីកន្លែងដែលមនុស្សធ្វើឲ្យនៅក៏មាន ៗ ខ្មោចបិសាច ខ្មោចអារក្សព្រាយ ។ ល ។ ក៏រាប់ចូលក្នុងពួកអសុរកាយដែរ ។

រីឯទោសនៃបាបកម្ម ជាទិដ្ឋធម្មិកផលក្តី ជាសម្បរាយិកផលក្តី ស្រេចហើយតែអបុញ្ញាភិសង្ខារ ជាអ្នកតាក់តែងសម្រេចឲ្យកើតជាក់ស្តែងទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោកនោះឯង ។

រួមសេចក្តីទៅឃើញថា បាបកម្មឬអកុសលកម្ម ដូចបានអធិប្បាយបញ្ជាក់ខាងលើនេះ ជាហេតុពិតមែននៃទុគ្គតិ ដែលជាផ្លូវនាំទៅកាន់កំណើតអាក្រក់ ក្នុងអបាយភូមិ ៤ ណាមួយ មិនខានឡើយ ។

ម្យ៉ាងទៀត អកុសលធម៌ ៥ ប្រការ ដូចមានសេចក្តីអធិប្បាយបញ្ជាក់ខាងក្រោមនេះ ក៏ត្រូវចាត់ទុកថាជាផ្លូវនរក ពីព្រោះមនុស្សដែលនឹងហ៊ានប្រព្រឹត្តនូវបាបកម្មផ្សេង ៗ ដូចបានរៀបរាប់ខាងលើនេះ ក៏ព្រោះតែមនុស្សនោះ ប្រកបព្រមដោយអកុសលធម៌ ៥ប្រការ គ្របសង្កត់ចិត្តធ្វើឲ្យវង្វេងភ្លេចខ្លួនភ្លេចស្មារតី ប្រែក្លាយទៅជាអ្នកមិច្ឆាទិដ្ឋិ យល់ដឹងខុសត្រូវ ល្អអាក្រក់ ហ៊ានប្រព្រឹត្តនូវអំពើទុច្ចរិត ដោយចេតនានោះឯង ។

រីឯមនុស្សដែលប្រកបព្រមដោយអកុសលធម៌ ៥ ប្រការនោះគឺ

១- អស្សទ្ធោ គឺអ្នកមិនមានសទ្ធា ។ ឯ អស្សទ្ធោ នេះ បានដល់អ្នកមិនជឿកម្ម ១ មិនជឿផលនៃកម្ម ១ មិនជឿថា សត្វមានកម្មជារបស់

ខ្ទួន ១ មិនជឿចំពោះប្រាជ្ញាត្រាស់ដឹង របស់ព្រះតថាគត ១ ។

២- អហិរិកោ គឺអ្នកមិនមានហិរិ ពោលគឺអ្នកមិនខ្មាសបាប ។

៣ អនោត្តប្បី គឺអ្នកមិនមានឱត្តប្ប: ពោលគឺអ្នកមិនខ្លាចបាប ។

៤- កុសីតោ គឺអ្នកខ្ជិលច្រអូស ។

៥ ទុប្បញ្ញោ គឺអ្នកឥតប្រាជ្ញា ។

អកុសលធម៌ទាំង ៥ នេះ ទុកជាហេតុនៃបាបកម្ម ពីព្រោះអកុសល-ធម៌ ៥ នោះ កាលបើកើតមានក្នុងខន្ធសន្តាននៃបុគ្គលណាហើយ តែង ញុំាងបុគ្គលនោះឲ្យធ្វើនូវបាបកម្មជានិច្ច ព្រោះខ្លួនមិនអាចតាំងនៅក្នុងព្រះ ធម៌បានសោះឡើយ ។ ម្យ៉ាងទៀត លោភៈ ទោសៈ មោហៈ ដែលជាអកុសលមូល គឺជាឫសនៃអកុសលនោះ ក៏ត្រូវចាត់ទុកជាផ្លូវនរក ដែរ ពីព្រោះអកុសលមូលទាំង ៣ នោះ ជាមូលហេតុនៃអកុសលធម៌ ៥ ប្រការ ដូចបានបញ្ជាក់ខាងលើនេះ ដោយហេតុថា បុគ្គលដែលនឹង ប្រកបព្រមដោយអកុសលធម៌ ៥ ប្រការនោះ ក៏ព្រោះតែបុគ្គលនោះមាន សន្តានចិត្តសៅហ្មងដោយ លោភៈ ទោសៈ និង មោហៈ ជា មូលហេតុនោះឯង ។

រួមសេចក្តីទៅឃើញថា បាបកម្ម អកុសលធម៌ ៥ និងអកុសលមូល ៣ នោះហើយ ដែលជាផ្លូវតែងនាំសត្វឲ្យធ្លោះទៅកាន់កំណើត កើត ជាសត្វនរក នៅក្នុងឋាននរកណាមួយ មិនខានឡើយ ។

## ២- អំពីឋាននរក ៦

ឋាននរក ជាឋានតាំងនៅឯបាតាល ពោលគឺនៅឯ អធោ-លោក ខាងក្រោមនោះ ។ ឋាននរកជាទីអបាយភូមិប្រាសចាកសុខ និងសេចក្ដីចម្រើនគ្រប់បែបយ៉ាង ព្រោះហេតុនោះ ឋាននរក បានឈ្មោះជា អបាយលោក ឬ ទុគ្គតិភព ។

ម្យ៉ាងទៀត ឋាននរកមានន័យ ៤ យ៉ាង ដូចតទៅនេះ ៖-

១- ឋាននរក ជាទីមិនប្រសើរ,

២- ឋាននរក ជាទីមានអារម្មណ៍អាក្រក់,

៣- ឋាននរក ជាទីដែលសត្វតែងទៅដល់ ដោយកម្មអាក្រក់តែម្យ៉ាង;

៤- ឋាននរក ជាទីដែលសត្វតែងមិនចំពាក់ចិត្ត ។

### ឯឋាននរកនោះ មាន ៦ ជាន់គឺ

ជាន់ទី ១ ឈ្មោះថា ឋានកាឡសុត្តនរក

ជាន់ទី ២ " ឋានសង្ឃាតនរក

ជាន់ទី ៣ " ឋានរោរុវនរក

ជាន់ទី ៤ " ឋានមហារោរុវនរក

ជាន់ទី ៥ " ឋានតាបនរក

ជាន់ទី ៦ " ឋានអវីចិនរក ។

កន្លែងនរកនីមួយ ៗ មានរណ្ដៅនរក សម្រាប់ជាទីនៅនៃសត្វនរក ហើយមាននរកផ្សេងៗ សម្រាប់ធ្វើទារុណកម្មទៅលើរូបសត្វនរក តាមកម្លាំងបាបកម្មដែលខ្លួនធ្វើ ដូចមានអធិប្បាយតទៅនេះ :

## អំពីរណ្ដៅនរក

រីឯរណ្ដៅនរកនោះ មាន ៨ គឺ

១- រណ្ដៅ សញ្ជីវ
២. រណ្ដៅ កាឡសុត្ត
៣- រណ្ដៅ សង្ឃាត
៤- រណ្ដៅ រោរុវ
៥- រណ្ដៅ មហារោរុវ
៦- រណ្ដៅ តាប
៧- រណ្ដៅ មហាតាប
៨- រណ្ដៅ អវីចិ

តើរណ្ដៅនរកទាំង ៨ នោះ តាំងនៅកន្លែងនរកណាខ្លះ ?

បើពិនិត្យតាមឈ្មោះ នៃរណ្ដៅនរកទាំង ៨ នោះ ខ្ញុំសន្និដ្ឋានដូចតទៅនេះគឺ

១- រណ្ដៅ សញ្ជីវ ១ និងកាឡសុត្ត ១ តាំងនៅកន្លែង កាឡសុត្តនរក

២- „ សង្ឃាត តាំងនៅកន្លែង សង្ឃាតនរក

៣- „ រោរុវ តាំងនៅកន្លែង រោរុវនរក

៤- „ មហារោរុវ តាំងនៅកន្លែង មហារោរុវនរក

៥- „ តាប ១ និងមហាតាប ១ តាំងនៅកន្លែង តាបនរក

៦- វណ្ណា អវីចិ តាំងនៅក្នុងឋាន អវីចិនរក នោះឯង ។

## ៤- អំពីនរក

រឯនរកសព្វក្នុងទីនេះ បើតាមខ្ញុំយល់នោះគឺចំពោះវត្ថុផ្សេង ៗ ទុកជាគ្រឿងឧបករណ៍ សម្រាប់ធ្វើទារុណកម្ម ទៅលើរូបសត្វនរក តាមកម្លាំងផលនៃបាបកម្មដែលខ្លួនធ្វើ ។ មានអត្ថបទខ្លះ បានប្រាប់ថា ព្រះពុទ្ធជាបរមគ្រូ បានសម្ដែងទុក ក្នុង ទេវទូតសូត្រ ថា នរកនោះមាន ៧ ដូចតទៅនេះ

១- លោហកុម្ភីនរក, ២- អវីចិនរក, ៣- គូថនរក, ៤- កុក្កុលនរក, ៥- សិម្ពលីនរក, ៦- អសិបត្តនរក, ៧- ខារោទកនរក ។

ចំពោះនរកទាំង ៧ នោះ ខ្ញុំសូមដកស្រង់តែពត៌មានខ្លះ មកបរិយាយបញ្ជាក់ ដោយត្រួសៗ ដូចតទៅនេះ :

### ១- លោហកុម្ភីនរក

ឯលោហកុម្ភីនរក គឺនរកខ្ទះទង់ដែងនោះ ជានរកពេញដោយទឹកទង់ដែង ដេះឡើងជាអណ្ដាតភ្លើង ។ សត្វនរកដែលធ្លាក់ចុះ ក្នុងលោហកុម្ភីនរកនេះ ត្រូវលិចចុះក្នុងទឹកទង់ដែងដល់បាតខ្ទះ ហើយអណ្ដែតឡើងវិញ គឺលិចចុះអណ្ដែតឡើងដូច្នេះ រងទុក្ខវេទនា រៀងរាបរហូតដល់អស់បាបកម្មដែលខ្លួនធ្វើ ។

## ២- អវីចិនរក

ឯអវីចិនរក គឺនរកមិនទំនេរ ជានរកធំមានជ្រុង ៤ មានទ្វារ ៤ មានទសជាដែក ឆេះឡើងជាអណ្តាតភ្លើង មានកំពែងដែកព័ទ្ធជុំវិញ ហើយឆេះចេញជាអណ្តាតភ្លើងទៀត ៗ សត្វនរក ដែលធ្លាក់ចុះក្នុងអវីចិនរកនេះ ត្រូវរត់ឆ្វេឆ្វាទៅវិញទៅមករកច្រកចេញ លុះទៅដល់ទ្វារមួយ ៗ ស្រាប់តែទ្វារទាំង ៤ នោះ បិទអស់ធ្វើឲ្យសត្វនរកនោះ ឆេះទីងអណ្តាតភ្លើង ឈឺខ្លោចផ្សា រងទុក្ខវេទនារហូតដល់អស់បាបកម្មដែលខ្លួនធ្វើនោះ ៗ

## ៣- គូថនរក

ឯគូថនរក គឺនរកជុំលាមកនោះ ជានរកពេញទៅដោយជុំលាមកទឹកមូត្រនិងហុងជន្លំ ៗ បញ្ចេញក្លិនអសោចស្អុយជាមហិមា ៗ សត្វនរកដែលធ្លាក់ចុះក្នុងគូថនរកនេះ ត្រូវស៊ីជុំលាមក ផឹកទឹកមូត្រជាអាហារ រងទុក្ខវេទនា លុះត្រាតែអស់បាបកម្មដែលខ្លួនធ្វើ ៗ

## ៤- កុក្កុលនរក

ឯកុក្កុលនរក គឺនរកផេះនោះ ជានរកពេញទៅដោយរណ្តៅផេះក្តៅនិងរណ្តៅរងើកភ្លើង ៗ សត្វនរកដែលធ្លាក់ចុះក្នុងកុក្កុលនរកនេះ ត្រូវធ្លាក់ចុះក្នុងរណ្តៅផេះ និងក្នុងរណ្តៅរងើកភ្លើងតែត្រឹមចង្កេះ ឆេះរលួយរលះ ឈឺចាប់ រងទុក្ខវេទនា រហូតដល់អស់បាបកម្មដលខ្លួនធ្វើនោះ ៗ

## ៥- សិម្ពលីនរក

ឯសិម្ពលីនរក គឺនរកដើមរកានោះ ជានរកពេញទៅដោយដើមរកាដែកមានបន្លាវែងស្រួច ៗ សត្វនរកដែលឡើងដើមរកាដែកនោះ ត្រូវមុតនឹងបន្លាដើមរកាដែក លុះឡើងដល់ទៅចុង ត្រូវសត្វក្អែកត្មាតធំ ៗ ហើរមកចឹកក្បាល លុះចុះមកដីវិញត្រូវហ្វូងឆ្កែធំ ៗ ខាំត្របាក់ធ្វើឲ្យសត្វនរកនោះឡើងចុះ ៗ ឡើង រងទុក្ខវេទនា ដរាបលុះត្រាតែអស់បាបកម្ម ដែលខ្លួនធ្វើនោះ ៗ

## ៦- អសិបត្តនរក

ឯអសិបត្តនរក គឺនរកស្លឹកដាវនោះ បានដល់នរកដែលពេញទៅដោយដើមឈើធំ ៗ មានម្លប់ត្រជាក់ កាលបើសត្វនរក ចូលទៅឈប់សម្រាកក្រោមម្លប់ដើមឈើនោះហើយ ស្រាប់តែខ្យល់បក់ធ្វើឲ្យស្លឹកឈើនោះធ្លាក់មក ហើយក្លាយទៅជាដាវ ប្រហារសត្វនរកនោះ ដាច់ជាកំណាត់ ៗ ឈឺចាប់ រងទុក្ខវេទនា រហូតដល់អស់បាបកម្ម ដែលខ្លួនធ្វើនោះ ៗ

## ៧- ខារោទកនរក

ឯខារោទកនរក គឺនរកស្ទឹងទឹកទន់ដែង ដែលពេញទៅដោយបរិក្ខារនរកជាច្រើនគឺ

១– ដើមផ្តៅមានបន្លាវែងស្រួច , ២– ចម្រូងដែកចុងស្រួច ,

៣– ស្លឹកឈូកដែក , ៤ ទឹកផ្សា , ៥– ទឹកក្រុត, ៦– សន្ទូច,
៧– ផ្ទាំងដែកក្រហម, ៨– ដុំដែកក្រហម ។

សត្វនរកក្នុងខារោទកនរកនោះ ត្រូវបរិវារនរកនោះធ្វើទារុណកម្មរឿងជាលំដាប់ លុះមកដល់សន្ទូចដែកធំ ។ ទើបសន្ទូចដែកស្ទូចថ្ពក់ឡើងលើមាត់ស្ទឹង ដាក់ឲ្យដេកលើផ្ទាំងដែកក្រហម ដើម្បីឲ្យនិរយបាលប្រកដុំដែកក្រហមនិងទឹកទង់ដែងទៅក្នុងមាត់ ដើម្បីឲ្យសត្វនរកនោះរងទុក្ខវេទនារហូតដល់អស់បាបកម្ម ។

រួមសេចក្ដីទៅឃើញថា បណ្ដានរកទាំង ៧ នោះ មានតែខារោទក-នរកទេ ដែលទុកជានរកធំជាងគេ ព្រោះខារោទកនរកនោះមានបរិវារនរកច្រើនជាងនរកឯទៀត ។ មនុស្សដែលប្រព្រឹត្តនូវបាបកម្មផ្សេង ៗ តែងធ្លាក់ចុះក្នុងនរកដ៏ធំនេះ ។

រីឯបាបកម្មដែលជាមូលហេតុ នាំឲ្យសត្វនរកធ្លាក់ចុះក្នុងនរកមួយ ៗ នោះ ខ្ញុំមិនលើកយកមកអធិប្បាយនៅទីនេះទេ ដើម្បីកុំឲ្យវែងសេចក្ដីពេក ពីព្រោះបាបកម្មនោះ មិនគឺបាបកម្មអ្វីក្រៅពីទុច្ចរិត ឬអកុសលកម្មបថ ១០ មានកាយទុច្ចរិត ៣ ជាដើមនោះទេ យើងគប្បីទុកចិត្តទៅលើអបុញ្ញាភិ-សង្ខារដែលជាអ្នកតាក់តែងកត់ គឺដំណើរកើតតាមយថាកម្មទៅចុះ ។

## ៥- អំពីសត្វនរក

មនុស្សណាប្រព្រឹត្តនូវអំពើបាបជារឿយ ៗ ដោយចេតនា មនុស្ស

នោះ បន្ទាប់ពីសេចក្ដីស្លាប់ តែងតែបានកំណើតអាក្រក់ក្នុងទុគ្គតិភព គឺក្នុងឋាននរកមិនខានឡើយ ។ រីឯកំណើតអាក្រក់ក្នុងឋាននរកនោះ មាន ២ យ៉ាងគឺ កំណើតជាសត្វនរក ១ និង កំណើតជាប្រេត ហៅថា ប្រេតវិស័យ ១ ។ សត្វនរកនិងសត្វប្រេតនេះហើយ ដែលបានឈ្មោះហៅថា យមក្ខន គឺពួកសត្វនរកនោះឯង ។

សត្វនរកនិងសត្វប្រេត ទុកជា ឧបបាតិកសត្វ គឺសត្វដែលឧប្បត្តិក កើតឡើងឯង ឥតមានមេមានបាអ្វីឡើយ គឺឧប្បត្តិកកើតឡើងឯង ដោយអំណាចផលបាបបណ្ដាលឲ្យទៅកើត ។ ដោយហេតុនេះ សត្វនរកនិងសត្វប្រេត ជាអបាយសត្វប្រាសចាកសុខ និងសេចក្ដីចម្រើនគ្រប់បែបយ៉ាង ព្រោះជាសត្វត្រូវនរកតូចធំធ្វើទារុណកម្មជានិច្ចនិរន្តរ៍ ស្លាប់កើត ៗ ស្លាប់ ក្នុងរណ្ដៅនរក ដរាបលុះត្រាតែអស់កម្ម ទើបបានរួចខ្លួន ត្រឡប់ឡើងមកកើតក្នុងឋានមនុស្សវិញ ។ សេចក្ដីអធិប្បាយមកនេះ សឲ្យឃើញច្បាស់ថា សត្វនរកសម្បូណ៌ដោយទុក្ខតែម្យ៉ាង គ្មានបានជួបប្រទះនឹងសុខបន្តិចឡើយ ។

## ៦- អំពីព្រះយមរាជ

ឯសត្វនរកនោះ នៅក្រោមការត្រួតត្រា នៃពួកនិរយបាល ឬ យមបាល ដែលជាអ្នកមានការកិច្ចជាពិសេស គឺត្រៀមចាំចាប់សត្វនរក បោះទម្លាក់ទៅក្នុងរណ្ដៅនរកនោះឯង ។

ពួកនិរយបាលទាំងនោះ នៅក្រោមអធិបតីនៃព្រះយមរាជ ដែលជា

ស្តេចគ្រប់គ្រងលើឋាននរកទាំង ៦ នោះ ៗ

គ្រង់នេះខ្ញុំសូមលើកបញ្ហា ១ មកពោលថា តើព្រះយមរាជ និងពួកនិរយបាលនោះ ជាសត្វនរកដែរ ឬដូចម្តេច ?

ចំពោះបញ្ហានេះ ខ្ញុំបានឃើញអត្ថបទ ១ ប្រាប់បញ្ជាក់ថា ព្រះយម-រាជនោះ គឺស្តេចប្រេត នាមឈ្មោះព្រះបាទ វេមានិកប្រេត ព្រះអង្គមានវិមានទិព្វ មានស្រីស្នំទិព្វ តែព្រះអង្គសោយសុខខ្លះទុក្ខខ្លះ ៗ ចំណែកឯពួកនិរយបាលនោះ មិនឃើញមានសេចក្តីបញ្ជាក់ទេ តែខ្ញុំយល់ថា ពួកនិរយបាលនោះ ជាវេមានិកប្រេត ដូចព្រះយមរាជនោះដែរ ?

## ៣- អំពីអាយុក្នុងឋាននរក

ព័ត៌មានដែលខ្ញុំរាវរកឃើញ បញ្ជាក់ឲ្យដឹង ដូចតទៅនេះ ៖

១- អាយុក្នុងរណ្តៅសញ្ជីវនរក មានកំណត់ ៥០០ ឆ្នាំ
២- អាយុក្នុងរណ្តៅកាឡសុត្តនរក " ១០០០ ឆ្នាំ
៣- អាយុក្នុងរណ្តៅសង្ឃាតនរក " ២០០០ ឆ្នាំ
៤- អាយុក្នុងរណ្តៅរោរុវនរក " ៤០០០ ឆ្នាំ
៥- អាយុក្នុងរណ្តៅមហារោរុវនរក " ៨០០០ ឆ្នាំ
៦- អាយុក្នុងរណ្តៅតាបនរក " ១៦០០០ ឆ្នាំ
៧- អាយុក្នុងរណ្តៅមហាតាបនរក " កន្លះអន្តរកប្ប

៨– អាយុកន្លះណ្ណាអវិចិនរក មានកំណត់ ១ អន្តរកប្ប

រីឯកំណត់អាយុក្នុងឋាននរកដូចខាងលើនេះ ឃើញថាវែងឆ្ងាយជាង អាយុឋានសួគ៌ទៅទៀត ។

ពិតមែនតែអាយុក្នុងឋាននរកមានកំណត់ដូចបានពោលខាងលើនេះ តែសត្វនរកមានត្រឡប់មកកើតជាមនុស្សវិញបានដោយអស់កម្មនោះឯង ។

## ៨- អំពីវត្តប្រតិបត្តិដើម្បីបិទផ្លូវនរក

វត្តប្រតិបត្តិដើម្បីបិទផ្លូវនរក គឺសំដៅចំពោះវត្តប្រតិបត្តិដែលអនុលោមទៅតាមពុទ្ធសាសនី ត្រង់បទទី ១ ដែលថែងថា សព្វបាបស្ស អករណំ បានសេចក្តីថា ចូរកុំធ្វើនូវបាបទាំងពួងនោះ ពីព្រោះការតាំងវិរតិចេតនា វៀរមិនប្រព្រឹត្តនូវអំពើបាបទាំងពួង ជាឧបាយសម្រាប់បិទផ្លូវនរក ដើម្បីមនុស្សសម្បត្តិនោះផង ។

ម្យ៉ាងទៀត ពុទ្ធសាសនីត្រង់បទទី ១ នោះ មានគោលដៅ ២ យ៉ាង គឺ ដឹកនាំសត្វឲ្យដោះខ្លួនរួចផុតពាកអបាយទុក្ខ ព្រមទាំងឲ្យបានទទួលនូវអានិសង្ស ៥ ប្រការ របស់ សីលសម្បទា ផង ដូចតទៅនេះគឺ

១- តែងបានភោគសម្បទជាទីគាប់ចិត្ត ,

២- តែងបានកិត្តិស័ព្ទដ៏ពីរោះផ្សាយទៅសព្វទិស ,

៣- តែងបានសេចក្តីអង់អាចក្លៀវក្លាចូលកាន់ទីប្រជុំ ,

៤- តែងមិនវង្វេង ធ្វើមរណកាល ,

អានិសង្សទាំង ៤ នេះ ទុកជា ទិដ្ឋធម្មិកាផល ឃើញជាក់ស្តែងក្នុងបច្ចុប្បន្ននេះ ។

៥-បន្ទាប់ពីសេចក្តីស្លាប់ តែងបានកំណើតល្អក្នុងសុគតិភព គឺក្នុងឋានមនុស្ស ឬ ក្នុងឋានទេវលោក តាមកម្លាំងសីល ដែលខ្លួនបានរក្សានោះ ។

អានិសង្សទី ៥ នេះ ទុកជា សម្បរាយិកាផល គឺផលឲ្យឃើញជាក់ច្បាស់ទៅក្នុងបរលោក ។

មិនតែប៉ុណ្ណោះ សត្វលោក ដែលបានប្រព្រឹត្តតាមពុទ្ធសាសនីគ្រប់ចំទី ១ នោះ តែងតែបានសម្រេចជាទីបំផុត នូវមនុស្សសម្បត្តិដូចតទៅនេះ :

ឯមនុស្សសម្បត្តិនេះ គឺការដល់ព្រមដោយធម៌ ១០ យ៉ាង គឺអាយុ វណ្ណៈ សុខៈ ពលៈ យសៈ អាធិបតេយ្យៈ រូបៈ សទ្ទៈ គន្ធៈ រសៈ និងផោដ្ឋព្វៈ ក៏ប៉ុន្តែធម៌ ១០ យ៉ាងនេះ ពុំមានលក្ខណៈជាទិព្វ ដូចបណ្តាការធម៌ ១០ ដែលជាទិព្វសម្បត្តិនោះទេ ។

សេចក្តីអធិប្បាយអំពីនរក ចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

# ភាគទី ២ ស្តីអំពីសុគតិ

សេចក្តីអធិប្បាយ

## ១- អំពីផ្លូវសុគតិ

សុគតិ ទុកជាផ្លូវសួគ៌ ពីព្រោះសុគតិបានដល់ផ្លូវជាទីនាំទៅកាន់កំណើតល្អកន្លែងសុគតិកត ពោលគឺឋានសួគ៌នោះឯង ។

រីឯបុញ្ញកម្មនោះ ត្រូវចាត់ទុកជាហេតុនៃសុគតិ ពីព្រោះបុញ្ញកម្មដែលមនុស្សបានធ្វើដោយចិត្តជ្រះថ្លាហើយ តែងតែប្រែក្លាយទៅជាសគ្គបរាយនកម្ម គឺអំពើបម្រុងតែនឹងនាំអ្នកធ្វើ ឲ្យទៅកើតឯឋានសួគ៌មិនលែងឡើយ ។

រីឯបុញ្ញកម្ម គឺអំពើបុណ្យនោះ គឺសំដៅចំពោះសុចរិត ១០ ឬកុសលកម្មបថ ១០ មានកាយសុចរិត ៣ ជាដើម និងចំពោះបុញ្ញកិរិយាវត្ថុ ១០មានទាន សីល ភាវនាជាអាទិ ។

ក្រៅពីបុញ្ញកម្ម ឬ កុសលកម្ម ២ ពួក ដែលជាអាចិណ្ណកម្មនោះ នៅមានមហាបរិច្ចាគ ៥ ប្រការទៀត ដូចតទៅនេះ :

១ - អង្គបរិច្ចាគ គឺបរិច្ចាគសរីរាង្គៈជាទាន,

២ - ធនបរិច្ចាគ គឺបរិច្ចាគទ្រព្យជាទាន,

៣ – បុត្តបរិច្ចាគ គឺបរិច្ចាគបុត្រជាទាន;

៤ – ទារបរិច្ចាគ គឺបរិច្ចាគភរិយាជាទាន,

៥ – ជីវិតបរិច្ចាគ គឺបរិច្ចាគជីវិតជាទាន,

ឯមហាបរិច្ចាគ ៥ ប្រការនេះ ទុកជាមហាបុញ្ញកម្ម គឺមានតែព្រះ

ពោធិសត្វទេ ដែលបានបំពេញនូវមហាបរិច្ចាគនោះ កាលពីបុពណ្ណ សម័យ ប៉ុណ្ណោះឯង ។

បុញ្ញកម្មទាំងឡាយ ដូចបានអធិប្បាយខាងលើនេះ កាលបើមនុស្សបានបំពេញ ឲ្យកើតមានឡើងជារឿយ ៗ ហើយ តែងតែផ្តល់ឲ្យមនុស្សនោះ បាននូវអានិសង្សផ្សេង ៗ តាមកម្លាំងបុញ្ញកម្ម ដែលខ្លួនបានបំពេញនោះ មិនខានឡើយ ។

រីឯអានិសង្សនោះ គឺសំដៅចំពោះអានិសង្ស ៥ យ៉ាងនៃសុចរិតគឺ

១- សម្បត្តិខ្លួនឯង ក៏គេះដៀលខ្លួនឯងមិនបាន,

២- តែងបានសេចក្តីសរសើរអំពីបណ្ឌិត,

៣- តែងបានកិត្តិស័ព្ទពីរោះផ្សាយទៅសព្វទិស,

៤- តែងមិនវង្វេង ក្នុងមរណកាល,

៥- តែងបានកំណើតល្អទាំងក្នុងឋានសួគ៌ទាំងក្នុងឋានមនុស្ស ។

អានិសង្ស ៤ ខាងដើម ទុកជាទិដ្ឋធម្មិកផល គឺផលដែលកើតឡើងឲ្យឃើញជាក់ស្តែង ក្នុងបច្ចុប្បន្ននេះ ឯអានិសង្សទី ៥ ទុកជាសម្បរាយិកផល គឺផលដែលនឹងកើតឡើងឲ្យឃើញជាក់ស្តែង ទៅក្នុងបរលោកឯណោះ ។

មួយវិញទៀត ការបរិច្ចាគទាន ក៏ជាហេតុនាំឲ្យបានអានិសង្ស ហៅថាអានិសង្សទាន មាន ៥ ប្រការគឺ

១- ជាទីស្រឡាញ់ពេញចិត្តនៃសាធារណជន,

២- បណ្ឌិតតែងចូលចិត្តរាប់រក;

៣- តែងមានកិត្តិស័ព្ទពីរោះផ្សាយទៅសព្វទិស,

៤- តែងក្លៀវក្លាចូលទៅកាន់ទីប្រជុំ,

អានិសង្សទាំង ៤ នេះទុកជា ទិដ្ឋធម្មិកផល គឺផលក្នុងបច្ចុប្បន្ន,

៥- បន្ទាប់ពីសេចក្តីស្លាប់ តែងបានទៅកើតក្នុងសុគតិភព អានិសង្ស ទី ៥ នេះ ទុកជា សម្បរាយិកផល គឺផលទៅក្នុងបរលោក ឯណោះ ។

ត្រង់នេះខ្ញុំសូមបញ្ជាក់ថា កាលបើអានិសង្សទី ៥ ខាងសុចរិតឬខាងទាន មិនទាន់មានកម្លាំងខ្លាំងក្លា អាចញុំាងបុគ្គលអ្នកធ្វើនូវបុញ្ញកម្មនោះឲ្យទៅកើតឯឋានសួគ៌ទេ បុគ្គលអ្នកធ្វើនូវបុញ្ញកម្មនោះ ក៏តែងបានកំណើតល្អក្នុងឋានមនុស្សមិនខានឡើយ គឺតែងបានកើតជា មនុស្សខ្ពស់ គឺមនុស្សល្អបរិសុទ្ធ ឬជា មនុស្សធំៗ គឺមនុស្សទៅតាមិនខានឡើយ។

ម្យ៉ាងទៀតចំពោះអានិសង្សនៃសុចរិតក្តីឬអានិសង្សនៃទានក្តី ស្រេចហើយតែបុញ្ញាភិសង្ខារជាអ្នកតាក់តែង និងជាអ្នកសម្រេចឲ្យកើតមានឡើងឲ្យឃើញជាក់ស្តែង ទាំងក្នុងបច្ចុប្បន្ន ទាំងទៅក្នុងបរលោកនោះឯង ។

អាស្រ័យហេតុនោះ បានជាបុញ្ញកម្មដូចបានរៀបរាប់ខាងលើនេះ ត្រូវចាត់ទុកជាហេតុនៃសុគតិ ពោលគឺផ្លូវជាទីនាំទៅកាន់ឋានសួគ៌នោះ ។

ម្យ៉ាងទៀត កុសលធម៌ ៥ ប្រការ ក៏គួរចាត់ទុកថាជាផ្លូវសួគ៌ដែរ

តែព្រោះមនុស្សដែលនឹងមានចិត្តជ្រះថ្លា បំពេញនូវបុញ្ញកម្មផ្សេង ៗ ដូចបានរៀបរាប់ខាងលើនេះ គំលុះណាតែមនុស្សនោះ មានសន្តានចិត្តប្រកបព្រមដោយកុសលធម៌ ៥ ប្រការនោះ ជាមូលហេតុដែរ ។

រីឯមនុស្សដែលប្រកបព្រមដោយកុសលធម៌ ៥ ប្រការនោះគឺ

១- សទ្ធា មានសទ្ធា ។ ឯសទ្ធានេះ បានដល់ការជឿកម្ម១ ជឿផលនៃកម្ម១ ជឿថាសត្វមានកម្មជារបស់ខ្លួន១ ជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះតថាគត ១ ។

២- ហិរិមា មានហិរិខ្មាសបាប,

៣- ឱត្តប្បី មានឱត្តប្បៈខ្លាចបាប,

៤- អារទ្ធវីរិយោ មានការព្យាយាម,

៥- បញ្ញវា មានប្រាជ្ញា ។

រីឯកុសលធម៌ ៥ ប្រការនេះ កាលបើបិតនៅក្នុងសន្តានចិត្តនៃបុគ្គលណាហើយ តែងញុំាងបុគ្គលនោះ ឲ្យកើតមានសតិបញ្ញា ព្រមទាំងមានសទ្ធាជ្រះថ្លា ដើម្បីបំពេញកងការជាកុសលផ្សេង ៗ ឲ្យកើតមានឡើងជាលំដាប់ តែព្រោះកុសលធម៌ ៥ យ៉ាងនោះ តែងញុំាងបុគ្គលនោះ ឲ្យតាំងនៅក្នុងព្រះសទ្ធម្មជានិច្ចនោះឯង ។

រួមសេចក្តីទៅឃើញថា បុញ្ញកម្មទាំងឡាយ និងកុសលធម៌ ៥ យ៉ាងនោះហើយ ដែលទុកជាហេតុនៃសុគតិ គឺផ្លូវជាទីនាំទៅកាន់កំណើតល្អ

ក្នុងឋានសួគ៌ តាមសេចក្ដីប្រាថ្នាបាន ។

## ២- អំពីឋានសួគ៌

ឯឋានសួគ៌នោះ បានដល់កាមាវចរសួគ៌ ៦ ជាន់ ដែលតាំងនៅលើអាកាស មានវិមានទិព្វ ជាទីអាស្រ័យនៅនៃពួកទេវតា ព្រោះហេតុនោះ ឋានសួគ៌នោះ ឈ្មោះថា ទេវលោក ឬ សុគតិភព ។

ឯឋានសួគ៌នោះ មានន័យ ៤ យ៉ាងគឺ

១- ឋានសួគ៌ ជាទីប្រសើរល្អ,

២- ឋានសួគ៌ ជាទីមានអារម្មណ៍ល្អ,

៣- ឋានសួគ៌ ជាទីដែលសត្វគប្បីទៅដល់ ដោយកម្មល្អតែម្យ៉ាង,

៤- ឋានសួគ៌ ជាទីដែលសត្វទាំងឡាយ តែងចំពាក់ចិត្ត,

រីឯឋានសួគ៌នោះ មាន ៦ ជាន់ ដូចតទៅនេះ :

ឋានសួគ៌ជាន់ទី ១ ឈ្មោះថា ចាតុម្មហារាជិកា

ឋានសួគ៌ជាន់ទី ២ " តាវត្តិង្ស ឬ ត្រៃត្រិង្ស

ឋានសួគ៌ជាន់ទី ៣ " យាមា

ឋានសួគ៌ជាន់ទី ៤ " តុសិត

ឋានសួគ៌ជាន់ទី ៥ " និម្មានរតី

ឋានសួគ៌ជាន់ទី ៦ " បរនិម្មិតវសវត្តី

ឯឋានសួគ៌ទាំង ៦ នេះ បានជាមានឈ្មោះហៅផ្សេងគ្នា ព្រោះឋានសួគ៌

មួយ ៗ មានលក្ខណៈពិសេស ដូចតទៅនេះ :

## ១- ឋានចាតុម្មហារាជិកា

ឯឋានសួគ៌ជាន់ទី ១ នោះ បានជាឈ្មោះថា ឋានចាតុម្មហារាជិកា ពីព្រោះឋានសួគ៌ជាន់ទី ១ នោះ ជាទីនៅរបស់មហាក្សត្រទាំង ៤ អង្គគឺ ធតរដ្ឋៈ ១ វិរុឡ្ហកៈ ១ វិរូបក្ខៈ ១ កុវេរៈ ១ ។

## ២- ឋានតាវត្តិង្ស

ឯឋានសួគ៌ជាន់ទី ២ បានជាឈ្មោះថា ឋានតាវត្តិង្ស ឬ ត្រៃត្រិង្ស នោះ ពីព្រោះឋានសួគ៌ជាន់ទី ២ នោះ ជាទីកើតនៃមនុស្ស ៣៣ នាក់ ដែលបានធ្វើបុណ្យរួមគ្នា ។ ម៉្យាងទៀត ឋានតាវត្តិង្សនោះ ជាកន្លែងទីរបស់ព្រះឥន្ទ្រ ព្រោះហេតុនោះ ទើបនៅឋានតាវត្តិង្សមានទេវសភា ១ សម្រាប់ជាទីប្រជុំ នៃពួកទេវតា ទាំងក្នុងឋានតាវត្តិង្ស ទាំងក្នុងឋានចាតុម្មហារាជិកាផង ។

## ៣- ឋានយាមា

ឯឋានសួគ៌ជាន់ទី ៣ បានជាឈ្មោះថា ឋានយាមា នោះ ពីព្រោះទេវតាដែលនៅក្នុងឋានសួគ៌ជាន់ទី ៣ នោះ ជាអ្នកដល់ព្រមដោយទិព្វសុខ ។

## ៤- ឋានតុសិត

ឯឋានសួគ៌ជាន់ទី ៤ បានជាឈ្មោះថា ឋានតុសិត នោះ ពីព្រោះទេវតាដែលនៅក្នុងឋានសួគ៌ជាន់ទី ៤ នោះ ជាអ្នកត្រេកអររីករាយ ។

## ៥- ឋាននិម្មានរតី

ឯឋានសួគ៌ជាន់ទី ៥ បានជាឈ្មោះថា ឋាននិម្មានរតី នោះ ពីព្រោះទេវតា ដែលនៅក្នុងឋានសួគ៌ជាន់ទី ៥ នោះ ជាអ្នកចេះនិម្មិតកាមភោគ គឺការបរិភោគកាមបានតាមសេចក្តីប្រាថ្នា ។

## ៦- ឋានបរនិម្មិតវសវត្តី

ឯឋានសួគ៌ជាន់ទី ៦ បានជាឈ្មោះថា ឋានបរនិម្មិតវសវត្តីនោះ ពីព្រោះទេវតាដែលនៅក្នុងឋានសួគ៌ជាន់ទី ៦ នោះ ជាអ្នកមានសិទ្ធិត្រូវបានទទួលនូវកាមភោគ ដែលទេវតាដទៃនិម្មិតឲ្យ ។

## ៣- អំពីព្រះឥន្ទ្រ

ព្រះឥន្ទ្រ មិនមែនជាទេវរាជ គ្រប់គ្រងលើឋានសួគ៌ទាំង ៦ ជាន់នោះទេ គឺព្រះអង្គគ្រាន់តែជាទេវរាជ លើឋានសួគ៌ ២ , ឯឋានសួគ៌ ៦ ទៀត មានទេវតាគ្រប់គ្រងជាប់មុខ ដូចតទៅនេះ :

១- ព្រះឥន្ទ្រ ជាទេវរាជគ្រប់គ្រងលើឋានតាវត្តិង្ស និងឋានចាតុម្មហារាជិកា ,

២- ព្រះសុយាមទេព ជាទេវរាជគ្រប់គ្រងលើឋានយាមា ,

៣- ព្រះសន្តុសិតទេព ជាទេវរាជគ្រប់គ្រងលើឋានតុសិត ,

៤- ព្រះនិម្មិតទេព ជាទេវរាជគ្រប់គ្រងលើឋាននិម្មានរតី ,

៥- ព្រះវសវត្តិទេព ជាទេវរាជគ្រប់គ្រងលើឋានបរនិម្មិតវសវត្តី

៦- ព្រហ្មជាន ជាទេវកជគ្រប់គ្រងលើចំណែក ១ នៃឋានបរ-និម្មិតវសវត្តី ដែលជាទីអាស្រ័យនៅនៃពួកទេវបុត្តមារនោះ ។

បណ្ដាទេវកជ ដូចមានរាយនាមខាងលើនេះ ឃើញតែព្រះឥន្ទ្រមួយព្រះអង្គទេ ដែលជាទេវកជសក្ដិសិទ្ធិជាពិសេស ហើយជាទីគោរពរបស់ពួកព្រាហ្មណ៍ក តាំងពួកពុទ្ធសាសនិក ក៏តែងតែគោរពទៅកេទេវកជនោះ តាមកាលដ៏គួរម្ដង ៗ ដែរ ។

ព្រះឥន្ទ្រមានជាយាធ ៤ នាកគឺ នាង សុធម្មា នាង សុធម្មា នាង សុចិត្តា និងនាង សុជាតា ព្រមទាំងមានបុត្រធីតា កើតអំពីជាយាទាំង ៤ នាក់នោះ មានចំនួនរាប់រយរាប់ពាន់នាក់ ។

## ៤- អំពីទេវតា និង ទេពអប្សរ

ឯទេវតា និង ទេពអប្សរ ជាសត្វពួកមួយ ដែលត្រូវបានទៅកើតក្នុងឋានសួគ៌ ដោយអំណាចកម្លាំងផលបុណ្យ ដែលខ្លួនបានធ្វើបណ្ដាលឲ្យទៅកើត ។

អាស្រ័យហេតុនោះ ទើបពួកទេវតា និង ពួកទេពអប្សរនោះ ត្រូវបានចាត់ទុកជាសគ្គវាសី និង សគ្គវាសិនី គឺជាអ្នកអាស្រ័យនៅក្នុងឋានសួគ៌ និងជាអ្នកត្រូវបានសោយសម្បត្តិទិព្វនោះឯង ។

ម្យ៉ាងទៀត ពួកទេវតា និងពួកទេពអប្សរមានភ្នែកទិព្វ ត្រចៀកទិព្វ ញាណទិព្វ ព្រមទាំងមានវិមានទិព្វជាទីអាស្រ័យនៅ ។ មិនតែប៉ុណ្ណោះ

ទេពតា និង ទេពអប្សរនោះ ចេះធ្វើដំណើរទៅកាន់ទីណាៗ មានអាកាស ជាដើម បានថែមទៀត ។

មួយវិញទៀត ពួកទេពតា និង ពួកទេពអប្សរនោះ ជាកាមគោគី ពោលគឺជាអ្នកប្រព្រឹត្តកាមសេវនកិច្ច ដូចមានសេចក្តីបញ្ជាក់ត្រង់មាតិកាទី ៤ ខាងចុងនេះស្រាប់ ។

ពួកទេវតា មិនមែនសុទ្ធតែអាស្រ័យនៅ ក្នុងឋានសួគ៌ទាំង ៦ ជាន់នោះទេ បើតាមខ្ញុំដឹង គេអាចចែកទេពនិករនោះ ជា ២ ពួក គឺអាកាសទេវតា ទេវតាដែលឋិតនៅលើអាកាស ទុកជាពួកទី ១ ភុម្មទេវតា ទេវតាដែលអាស្រ័យនៅលើផែនដី ទុកជាពួកទី ២ ។

៦ អាកាសទេវតា បានដល់ទេវតាដែលមានវិមានទិព្វ នៅក្នុងកាមាវចរសួគ៌ ៦ ជាន់ មានចាតុម្មហារាជិកាជាដើមនោះឯង ហើយ ភុម្មទេវតា គឺសំដៅចំពោះ រុក្ខទេវតា គឺទេវតាជាអ្នកថែរក្សាព្រៃព្រឹក្ស និង លោកបាលទេវតា គឺទេវតាជាអ្នកថែរក្សាលោក (ល) ។

ក្នុងបណ្តាអាកាសទេវតានោះ មានទេវតា ២ ពួក ដែលតែងតែចុះមកកាន់ឋានមនុស្ស គឺទេវបុត្តមារនិងវិស្សកម្មទេវបុត្ត តែប៉ុន្តែមនុស្សមើលមិនឃើញ ព្រោះទេវតាជាអមនុស្ស និង ជាអទិស្សមានកាយ ពោលគឺមានខ្លួនប្រាណ តែមនុស្សគេមើលមិនឃើញឡើយ ។

## ៥- អំពីកាមសេវនកិច្ចក្នុងឋានសួគ៌

ទេវតា និងទេពអប្សរជាកាមភោគី គឺជាអ្នកបរិភោគកាមដូចមនុស្សដែរ ក៏ប៉ុន្តែការបរិភោគកាមក្នុងឋានសួគ៌មានលក្ខណៈជាទិព្វ ខុសគ្នានឹងការបរិភោគកាមរបស់មនុស្ស ដូចមានសេចក្តីបញ្ជាក់ខាងក្រោមនេះ ។

ឯកាមសេវនកិច្ច គឺការសេពកាមស្និទ្ធស្នាល រាប់រកគ្នាខាងផ្លូវកាម របស់ទេវតា និង ទេពអប្សរ ក្នុងឋានសួគ៌ទាំង ៦ នោះ មានដំណើរប្រព្រឹត្តទៅខុសផ្សេងគ្នា ដូចតទៅនេះ :

ក្នុងឋានចាតុម្មហារាជិកា និង ឋានតាវត្តិង្សនោះ កាមសេវនកិច្ចតែងប្រព្រឹត្តទៅដោយការរួមបវេណី ។

ក្នុងឋានសួគ៌ ៤ ទៀត កាមសេវនកិច្ចតែងប្រព្រឹត្តទៅដូចតទៅនេះ :

ក្នុងឋានយាមា ដែលជាឋានសួគ៌ជាន់ទី ៣ នោះ ដោយការស្ទាបអង្អែលគ្នា ។

ក្នុងឋានតុសិត ដែលជាឋានសួគ៌ជាន់ទី ៤ ដោយការចាប់ដៃគ្នា ។

ក្នុងឋាននិម្មានរតី ដែលជាឋានសួគ៌ជាន់ទី ៥ ដោយការសម្លឹងមើលគ្នា ។

ក្នុងឋានបរនិម្មិតវសវត្តី ដែលជាឋានសួគ៌ជាន់ទី ៦ ដោយការញញឹមរកគ្នា ។

រីឯការបរិភោគកាម ដូចបានរៀបរាប់ខាងលើនេះ គ្រាន់ជាហេតុនាំ

ឲ្យសន្ធវាត គឺតម្រេកក្នុងការសេពសន្ធវៈសម្រេចឡើងតាមសេចក្តីប្រាថ្នា បានតែប៉ុណ្ណោះ សូម្បីតែការបរិភោគតាមដោយរូបប្រណីតណា ក៏មិនមែនជាហេតុអាចញ៉ាំងទេពអប្សរឲ្យកើតមានគភ៌បានដែរ ពីព្រោះកំណើតនៃទេវតា និងទេពអប្សរ ជាឧបបាតិកៈកំណើត គឺកំណើតដែលឧប្បត្តិកកើតឡើងឯង ដោយអំណាចផលបុណ្យតែប៉ុណ្ណោះ ។

អាស្រ័យហេតុនោះ បានជាមនុស្សដែលត្រូវទៅកើតក្នុងឋានសួគ៌ ដោយអំណាចផលបុណ្យបណ្តាលឲ្យទៅកើតនោះ ត្រូវបានឧប្បត្តិកកើតឡើងឯង ខ្លះនៅលើភ្លៅនៃទេពអប្សរ ឬទេវតា ខ្លះនៅក្នុងទីដេក ខ្លះនៅកណ្តាលវិមានតែម្តង ។

## ៖ - អំពីអាយុក្នុងឋានសួគ៌

អាយុក្នុងឋានសួគ៌ ជាអាយុទិព្វ មានកំណត់កាលវែងណាស់ ស្ទើរតែមិនចង់ជឿ ។

ចំពោះរឿងនេះ សៀវភៅសគ្គកថា បានប្រាប់ដូចតទៅនេះ :

| | | |
|---|---|---|
| ឋានចាតុម្មហារាជិកា | អាយុទិព្វ | ៥០០ ឆ្នាំ |
| ឋានតាវត្តិង្ស | អាយុទិព្វ | ១០០០ ឆ្នាំ |
| ឋានយាមា | អាយុទិព្វ | ២០០០ ឆ្នាំ |
| ឋានតុសិត | អាយុទិព្វ | ៤០០០ ឆ្នាំ |
| ឋាននិម្មានរតី | អាយុទិព្វ | ៨០០០ ឆ្នាំ |

បរនិម្មិតវសវត្តី អាយុទិព្វ ១៦០០០ ឆ្នាំ

បើធៀបអាយុមនុស្សទៅនឹងអាយុទិព្វ ឃើញខុសគ្នាច្រើនណាស់ ដូចតទៅនេះ :

៥០ ឆ្នាំមនុស្ស ស្មើនឹងអាយុទិព្វ ១ ថ្ងៃ ១ យប់ ក្នុងឋានចាតុម្មហារាជិកា

១០០ ឆ្នាំមនុស្ស ស្មើនឹងអាយុទិព្វ ១ ថ្ងៃ ១ យប់ ក្នុងឋានតាវត្តឹង្ស

២០០ ឆ្នាំមនុស្ស ស្មើនឹងអាយុទិព្វ ១ ថ្ងៃ ១ យប់ ក្នុងឋានយាមា

៤០០ ឆ្នាំមនុស្ស ស្មើនឹងអាយុទិព្វ ១ ថ្ងៃ ១ យប់ ក្នុងឋានតុសិត

៨០០ ឆ្នាំមនុស្ស ស្មើនឹងអាយុទិព្វ ១ ថ្ងៃ ១ យប់ ក្នុងឋាននិម្មានរតី

១៦០០ឆ្នាំមនុស្ស ស្មើនឹងអាយុទិព្វ ១ ថ្ងៃ ១ យប់ ក្នុងឋានបរនិម្មិតវសវត្តី ។

បើតាមខ្ញុំយល់ ទេវតាទាំងឡាយ មិនមែនរស់នៅទៅតាមអាយុទិព្វទាំងអស់គ្នានោះទេ ពីព្រោះទេវតាទាំងនោះ ត្រូវច្យុតចុះមកកើតក្នុងឋានមនុស្សវិញ ដោយហេតុណាមួយ ក្នុងបណ្ដាហេតុទាំង ៤ យ៉ាង ដូចមានអធិប្បាយត្រង់ទេពច្យុតិ ខាងមុខនេះស្រាប់ ។

## ៣- អំពីទេពបុត្រ

ត្រង់ចំណុចនេះ ដើម្បីឲ្យអស់សេចក្ដីសង្ស័យ ខ្ញុំសូមបញ្ជាក់ថា ទេវតាទាំងឡាយ កាលបើធ្វើកាលកិរិយាហើយ មិនអាចចាប់បដិសន្ធិ

កើតក្នុងទេវលោកតែម្ដងជាថ្មីទៀតបានឡើយ ពីព្រោះមូលហេតុ នៃកំណើតអ្នកក្នុងទេវលោកនោះ គឺផលបុណ្យដែលបានកសាងសន្សំទុកពីអតីតជាតិតែប៉ុណ្ណោះឯង ។

ដោយហេតុនោះ កាលបើបានទទួលសោយផលបុណ្យ ដែលខ្លួនបានបំពេញ ឲ្យកើតមានឡើងពីអតីតជាតិ អស់កាលណាហើយ ពួកទេវតានោះ ត្រូវតែច្យុតចុះមកកើតជាមនុស្សវិញ ដោយដាច់ខាត ។

រីឯហេតុដែលនាំឲ្យទេវតាច្យុតចុះមកកើតជាមនុស្សវិញមាន ៤ យ៉ាងគឺ

១- ដោយអស់អាយុ,

២- ដោយអស់បុណ្យ,

៣- ដោយអស់អាហារទិព្វ,

៤- ដោយក្រេវក្រោធ, ។

កាលបើហេតុ ៤ យ៉ាង ណាមួយ កើតឡើងហើយ បុព្វនិមិត្ត ៥ ក៏កើតប្រាកដដល់ពួកទេវតា មុនចុតិ ៧ ថ្ងៃ ជាដរាបមិនខានឡើយ ។

រីឯបុព្វនិមិត្ត ៥ នោះគឺ

១- ផ្កាទិព្វស្វិតស្រពោន,

២- សំពត់ទ្រង់មានមន្ទិល,

៣- សេទោ ( ញើស ) ហូរចេញពីក្លៀក,

៤- ពណ៌សម្បុរសៅហ្មង,

៥- ចិត្តធុញទ្រាន់ក្នុងទិព្វាសនៈ ។

## ៨- អំពីវត្តប្រតិបត្តិដើម្បីបើកផ្លូវសួគ៌

វត្តប្រតិបត្តិដើម្បីបើកផ្លូវសួគ៌ បានដល់វត្តប្រតិបត្តិដែលអនុលោមទៅតាមពុទ្ធសាសនីគ្រឹះទី ២ ដែលប្រដៅសត្វថា កុសលស្សូបសម្បទា បានសេចក្តីថា ចូរធ្វើឲ្យដល់ព្រមដោយកុសលទាំងពួង ពីព្រោះកុសលកម្ម ឬ បុញ្ញកម្ម ជាមូលហេតុនៃសុគតិ ដូចបានបញ្ជាក់ខាងដើមនោះស្រាប់ ។

អាស្រ័យហេតុនោះ ការព្យាយាមបំពេញនូវកុសលកម្មបថ ១០ ឬ សុចរិត ១០ ហើយនឹងការព្យាយាមបំពេញនូវបុញ្ញកិរិយាវត្ថុ ១០ មានការបរិច្ចាគទានជាដើម ទុកជាវត្តប្រតិបត្តិសម្រាប់បើកផ្លូវសួគ៌ ដើម្បីឆ្ពោះទៅកាន់ទិព្វសម្បត្តិនោះឯង ។

ឯទិព្វសម្បត្តិ ឬ សគ្គសម្បត្តិនោះ បានដល់សម្បត្តិឋានសួគ៌ ពោលគឺការដល់ព្រមដោយបណ្ណាការធម៌ ១០ យ៉ាង ដូចតទៅនេះ :

១- ទិព្វាយុ គឺអាយុទិព្វ ។ ឯអាយុទិព្វនោះ មានកំណត់កាលវែងណាស់ ដូចមានសេចក្តីបញ្ជាក់ត្រង់មាតិកាទី ៨ ខាងដើមនោះ ។

២- ទិព្វវណ្ណ គឺសម្បុរទិព្វ ។ ឯសម្បុរទិព្វនោះ បានដល់សម្បុរជ្រះថ្លា មានរស្មី អាចធ្វើទីងងឹតឲ្យមានពន្លឺភ្លឺឡើងបាន ។

៣- ទិព្វសុខ គឺសុខទិព្វ ។ ឯសុខទិព្វនោះ បានដល់សុខពិតថេរ ឥតប្រែប្រួល ។

៤- ទិព្វយស គឺយសទិព្វ ។ ឯយសទិព្វនោះ បានដល់សេចក្ដីថ្កើងថ្កាន ប្រកបដោយបរិវារច្រើនកំ បម្រើគ្រប់ពេលវេលា ។

៥- ទិព្វាធិបតេយ្យ គឺអាធិបតេយ្យទិព្វ ។ ឯអាធិបតេយ្យទិព្វនោះ បានដល់ឥស្សរភាព ជាទីគួរឲ្យកោតខ្លាច ឲ្យគោរព ។

៦- ទិព្វរូប គឺរូបទិព្វ ។ ឯរូបទិព្វនោះ បានដល់រូបដែលប្រកបដោយសោភណភាព ប្រិមប្រិយ ជាទីគួរឲ្យសរសើរ ។

៧- ទិព្វសទ្ទ គឺសម្លេងទិព្វ ។ ឯសម្លេងទិព្វនោះ បានដល់សម្លេងពីរោះ ទន់ភ្លន់ ផ្អែមល្ហែម ជាទីគួរឲ្យចង់ស្ដាប់ ។

៨- ទិព្វគន្ធ គឺក្លិនទិព្វ ។ ឯក្លិនទិព្វនោះ បានដល់ក្លិនក្រអូបឈ្ងុយឈ្ងប់ ជាប់នៅជានិច្ច ។

៩- ទិព្វរស គឺរសទិព្វ ។ ឯរសទិព្វនោះ បានដល់ការដឹងសម្ផស្សកាមទិព្វ ។

១០- ទិព្វផោដ្ឋព្វ គឺផោដ្ឋព្វទិព្វ ។ ឯផោដ្ឋព្វទិព្វនោះ បានដល់ការដឹងផោដ្ឋព្វារម្មណ៍ទិព្វ ។

មនុស្សទាំងឡាយដែលបានទៅកើតជាទេវតា ក្នុងកាមាវចរសួគ៌ ដោយកម្លាំងបុណ្យដែលខ្លួនបានធ្វើនោះ តែងបានទទួលបណ្ណាការធម៌១០ យ៉ាងនោះ ទុកដូចជាជំនូន ឬ តង្វាយរបស់បុណ្យ ព្រោះហេតុនោះ

ទើបបណ្ណាការធម៌ ១០ យ៉ាងនោះ បានឈ្មោះថា ជាទិព្វសម្បត្តិ ដោយប្រការដូច្នេះឯង ។

ពួកទេវតា ទទួលសោយនូវទិព្វសម្បត្តិនេះ ដរាបលុះត្រាអស់អាយុ ឬអស់បុណ្យ ទើបត្រូវច្យុតចុះមកចាប់បដិសន្ធិ យកកំណើតជាមនុស្ស នៅក្នុងឋានកណ្ដាលវិញ ដោយដាច់ខាត ដើម្បីកសាងសន្សំទុកជាថ្មីទៀត ។

រួមសេចក្ដីទៅឃើញថា ឋាននរក ឋានមនុស្ស និងឋានសួគ៌ ជាឋានសម្រាប់ឲ្យសត្វដែលធ្វើនូវកម្ម ជាបាបក្ដី ជាបុណ្យក្ដី អន្ទោលយកកំណើតកើតជាសត្វនរក ជាទេវតា ឬជាមនុស្ស ទៅតាមកម្លាំងផលកម្មដែលខ្លួនធ្វើ ព្រោះហេតុនោះ ទើបឋានទាំង ៣ នោះឈ្មោះថា កាមភព ដែលជាភពទី ១ នៃត្រៃភពនោះឯង ។

ចំណែកឯនិព្វានវិញ មិនមែនជាឋាន ឬ ជាភព សម្រាប់ឲ្យសត្វកើតស្លាប់ ទៅតាមយថាកម្មរបស់ខ្លួននោះទេ ផ្ទុយទៅវិញ និព្វានជាលោកុត្តរធម៌ គឺធម៌សម្រាប់តែចម្លងសត្វ ដែលនឿយណាយធុញទ្រាន់ នឹងដំណើរវិលកើតវិលស្លាប់ ក្នុងឋានទាំង ៣ នោះ ឲ្យឆ្លងចេញរួចផុតចាកលោកទាំង ៣ មាននុស្សលោកជាអាទិ ដើម្បីឆ្ពោះទៅកាន់បរមសុខ ដែលជាសុខរួចផុតស្រឡះ ចាកសង្សារទុក្ខ គឺទុក្ខព្រោះដំណើរវិលកើតវិលស្លាប់នោះឯង ។

សេចក្ដីអធិប្បាយអំពីឋានសួគ៌ ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

# ភាគទី ៣ ស្ដីអំពីនិព្វាន

### សេចក្ដីអធិប្បាយ

## ១- អំពីផ្លូវនិព្វាន

ឯផ្លូវនិព្វាននោះ បានដល់លោកុត្តរធម៌ ៨ គឺ មគ្គ ៤ និង ផល ៤ ពីព្រោះ មគ្គ ៤ និង ផល ៤ នោះ ជាផ្លូវប្រតិបត្តិ មានគោលដៅជាក់ច្បាស់ គឺការដុសខាត់ជម្រះចិត្តឲ្យបរិសុទ្ធផូរផង់ ដើម្បីលោកុត្តរចិត្ត ៨ ដួង គឺ មគ្គចិត្ត ៤ និង ផលចិត្ត ៤ ដែលជាប្រភពនៃបរមសុខ គឺសុខដ៏ល្អិតក្រៃលែង ពោលគឺនិព្វាននោះឯង ។

វត្តប្រតិបត្តិដែលមានគោលដៅដូច្នេះ ឃើញស្របទៅនឹងពុទ្ធសាសនា គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ត្រង់បទទី ៣ ដែលថ្លែងថា សចិត្តបរិយោទបនំ បានសេចក្ដីថា ចូរជម្រះចិត្តឲ្យផូរផង់ឡើង ពីព្រោះពុទ្ធសាសនានេះ ពិតជាមានគោលបំណងនឹងដឹកនាំសត្វ ឲ្យឆ្ពោះទៅកាន់លោកុត្តរាភិសម័យ ពោលគឺការត្រាស់ដឹងលោកុត្តរធម៌ មានការត្រាស់ដឹងនិព្វានជាទីបំផុតនោះ ឯង ។

រីឯមគ្គ ៤ ដែលទុកជាផ្លូវនិព្វាននោះគឺ

មគ្គទី ១ ដែលជាផ្លូវនិព្វានឈ្មោះសោតាបត្តិមគ្គ នោះបានដល់ផ្លូវប្រតិបត្តិសម្រាប់លះដោយបញ្ញាខន្ធ នូវសំយោជនៈ ៣ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ព្រមទាំងទិដ្ឋាសវៈ ១ ដើម្បីនាំមកនូវសោតាបត្តិមគ្គចិត្ត ។

មគ្គទី ២ ដែលជាផ្លូវនិព្វានឈ្មោះ សកទាគាមិមគ្គ នោះ បានដល់ផ្លូវប្រតិបត្តិសម្រាប់ញ៉ាំងសំយោជនៈ ២ គឺ កាមរាគៈ និង បដិឃៈ ព្រមទាំង កាមាសវៈ និង តណ្ហា ឲ្យស្ងប់ដោយសមាធិ-ក្ខន្ធ គឺរូបជ្ឈាន ៣ ខាងដើម ជាប្រយោជន៍ដើម្បីសកទាគាមិមគ្គចិត្ត ។

មគ្គទី ៣ ដែលជាផ្លូវនិព្វានឈ្មោះ អនាគាមិមគ្គ នោះ បានដល់ផ្លូវប្រតិបត្តិសម្រាប់លះដោយសមាធិក្ខន្ធ គឺ ដោយរូបជ្ឈានទី ៤ នូវសំយោជនៈ ២ គឺ កាមរាគៈ និង បដិឃៈ ព្រមទាំង កាមាសវៈ និង កាមតណ្ហា ជាសមុច្ឆេទប្បហាន ដើម្បីនាំមកនូវអនាគាមិមគ្គចិត្ត ។

មគ្គទី ៤ ដែលជាផ្លូវនិព្វានឈ្មោះ អរហត្តមគ្គ នោះ បានដល់ផ្លូវប្រតិបត្តិសម្រាប់លះដោយអរូបជ្ឈាន ៤ នូវសំយោជនៈ ៥ ខាងចុង គឺ រូបរាគ អរូបរាគ មានះ ឧទ្ធច្ចៈ និង អវិជ្ជា ព្រមទាំងអាសវៈ ២ គឺ ភវាសវៈ និង អវិជ្ជាសវៈ ហើយនិងតណ្ហា ២ គឺ ភវតណ្ហា និង វិភវតណ្ហា ជាសមុច្ឆេទប្បហាន ដើម្បីនាំមកនូវអរហត្តមគ្គចិត្ត នោះឯង ។

រីឯ ផល ៤ នោះ បានដល់វិមុត្តិដែលកើតឡើងអំពីមគ្គ ៤ ពោលគឺការរួចផុតស្រឡះចាកសំយោជនៈ ១០ អាសវៈ ៤ និង តណ្ហា ៣ រៀងតាមលំដាប់ផល ៤ ដើម្បីនាំមកនូវផលចិត្ត ៤ ដួង ដូចតទៅនេះ :

ផលទី ១ ដែលឈ្មោះថា សោតាបត្តិផល នោះ បានដល់វិមុត្តិ

គឺការរួចផុតស្រឡះចាកសំយោជនៈ ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា និង សីលព្វតបរាមាសៈ ព្រមទាំង ទិដ្ឋាសវៈ ជាសមុច្ឆេទវិមុត្តិ ដើម្បីនាំមកនូវសោតាបត្តិផលចិត្ត ។

ផលទី២ ដែលឈ្មោះថា សកទាគាមិផល នោះ បានដល់វិមុត្តិ គឺការរួចចាកសំយោជនៈ ២ គឺកាមរាគ និងបដិឃៈ ព្រមទាំងកាមាសវៈ និងកាមតណ្ហា ជាបដិប្បស្សទ្ធិវិមុត្តិ ដើម្បីនាំមកនូវសកទាគាមិផលចិត្ត ។

ផលទី ៣ ដែលឈ្មោះថា អនាគាមិផល នោះ បានដល់វិមុត្តិ គឺការរួចផុតស្រឡះចាកសំយោជនៈ២គឺកាមរាគ និងបដិឃៈព្រមទាំងកាមា-សវៈ និងកាមតណ្ហា ជាសមុច្ឆេទវិមុត្តិ ដើម្បីនាំមកនូវអនាគាមិផលចិត្ត ។

ផលទី ៤ ដែលឈ្មោះថា អរហត្តផល នោះ បានដល់វិមុត្តិ គឺការរួចផុតស្រឡះចាកសំយោជនៈ ៥ ខាងចុង គឺរូបរាគ អរូបរាគ មានះ ឧទ្ធច្ចៈ និងអវិជ្ជា ព្រមទាំងអាសវៈ ២ គឺភវាសវៈ និងអវិជ្ជាសវៈ ហើយនឹងតណ្ហា ២ គឺភវតណ្ហា និង វិភវតណ្ហា ជានិស្សរណវិមុត្តិ ដើម្បីនាំមកនូវអរហត្តផលចិត្តនោះឯង ។

រីឯមគ្គចិត្ត ៤ ដួង និងផលចិត្ត ៤ ដួងនោះ ទុកជាលោកុត្តរចិត្ត ប្រព្រឹត្តទៅក្នុងលោកុត្តរភូមិ ពោលគឺចិត្តឆ្លងចេញ រួចផុតពីកាមាវចរភូមិ រូបាវចរភូមិ និង អរូបាវចរភូមិហើយ ។

អរិយបុគ្គល ដែលបានសម្រេច លោកុត្តរចិត្ត គឺ មគ្គចិត្ត ៤ និង

ផលចិត្ត ៤ នោះស្រេចហើយ ឈ្មោះថា បានត្រាស់ដឹងមគ្គ ៤ និងផល ៤ ហើយការត្រាស់ដឹងមគ្គ ៤ និង ផល ៤ ទុកជាហេតុនៃការត្រាស់ដឹងនិព្វាន ជាលំដាប់ទៀត ។

## ២-អំពីនិព្វាន

និព្វានដែលសម្រេចកើតឡើងដោយមគ្គចិត្ត ៤ និងផលចិត្ត ៤ ជាមូលហេតុនោះ ជា អរូបំ ឥតមានរូប ជា អសង្ខតំ ឥតមានបច្ច័យតាក់តែង និងជា អនន្តំ ឥតមានទីបំផុតឡើយ ក៏ប៉ុន្តែនិព្វាននោះ ជាសច្ចិកាតព្វធម៌ គឺធម៌ដែលព្រះអរហន្ត គប្បីធ្វើឲ្យជាក់ច្បាស់ឡើង ទើបព្រះអរហន្តនោះ ឈ្មោះថា បានត្រាស់ដឹងនិព្វានដោយជាប់ខាត ។

រីឯនិព្វាននោះ មានន័យ ៤ យ៉ាងគឺ

១- និព្វានជាវិមោក្ខធម៌ គឺនាំសត្វឲ្យរួចចាកកគាកិក្កិលេស,

២- និព្វានជាមោក្ខធម៌ គឺធម៌នាំសត្វឲ្យរួចចាកទុក្ខ,

៣- និព្វានជាសិវធម៌ គឺធម៌នាំសត្វឲ្យបានដល់នូវសេចក្តីក្សេមគឺបរមសុខ,

៤- និព្វានជាលោកុត្តរធម៌ គឺធម៌នាំសត្វឲ្យឆ្លងចេញរួចផុតចាកលោក ។

រីឯនិព្វាននោះ មាន ២ ប្រការគឺ ឧបាទិសេសនិព្វាន ១ និងអនុបាទិសេសនិព្វាន ១ ដូចមានសេចក្តីអធិប្បាយបញ្ជាក់ តទៅនេះ ៖-

ឧបាទិសេសនិព្វានបានដល់វិមោក្ខធម៌ ៣ ប្រការ មានសុញ្ញតវិមោក្ខជាដើម ហើយអនុបាទិសេសនិព្វាន បានដល់ធម្មជាតៈចេញរួចផុតចាកគ្រឿងចាក់ស្រេះ គឺតណ្ហា ។

ឯឧបាទិសេសនិព្វាននោះ ទុកជាលោកិយនិព្វាន ព្រោះឧបាទិសេសនិព្វាន ជានិព្វានរលត់តែកិលេស នៅសេសសល់ខន្ធ ៥ និងកងទុក្ខ ។ រីឯឧបាទិសេសនិព្វាននេះ តែងបានសម្រេចជាក់ច្បាស់ឡើង ដោយការត្រាស់ដឹងមគ្គ ៤ និងផល ៤ ជាមូលហេតុ ។

ចំណែកឯអនុបាទិសេសនិព្វាននោះ ទុកជាលោកុត្តរនិព្វាន ព្រោះអនុបាទិសេសនិព្វាន ជានិព្វានរលត់ទាំងខន្ធ ៥ ទាំងកងទុក្ខ គ្មានសេសសល់ឡើយ ។ រីឯអនុបាទិសេសនិព្វាននេះ តែងបានសម្រេចជាក់ច្បាស់ឡើង ដោយការត្រាស់ដឹងឧបាទិសេសនិព្វាន ជាមូលហេតុ ។

សរុបសេចក្ដីទៅ ឃើញថា អរិយបុគ្គលដែលបានបំពេញវត្តប្រតិបត្តិ ដើរតាមផ្លូវនិព្វានទាំង ៤ នោះ ឈ្មោះថា បានកាប់គាស់រំលើង ឬកាត់ផ្ដាច់ផ្ដិល នូវឫសកែវនៃតណ្ហា គឺកាទិក្កិលេស អស់ពីខន្ធសន្ដាន ដែលជាហេតុនាំឲ្យអរិយបុគ្គលនោះ បានត្រាស់ដឹងជាបឋម នូវឧបាទិសេសនិព្វាន ពោលគឺបានសម្រេច នូវវិមោក្ខធម៌ ៣ ប្រការ មានសុញ្ញតវិមោក្ខជាដើម ។

រីឯការកាប់គាស់រំលើង ឬកាត់ផ្ដាច់ផ្ដិលនូវឫសកែវនៃតណ្ហាអស់ពីខន្ធសន្ដាននោះ ឈ្មោះថា បានញុំាងផលនៃតណ្ហា គឺឧបាទាន ៤ កម្មភព ៥ និងទុក្ខ ឲ្យផុតរលត់អស់រលីងជាលំដាប់ទៀត ដែលជាហេតុនាំឲ្យព្រះ

របោន្ត បានត្រាស់ដឹង គួរឲ្យអស្ចារ្យ ក្នុងខណៈរំលត់ជីវិតសង្ខារ នូវអនុបាទិសេស-និព្វាន ពេលគឺ បានសម្រេចនូវធម្មជាតចេញផុតចាកតណ្ហា ធ្វើដំណើរឆ្ពោះទៅកាន់សម្បត្តិនិព្វាន គឺបរមសុខនោះ ។

ត្រង់នេះ ដើម្បីឲ្យរឹតតែបានក្បោះក្បាយថែមទៀត ខ្ញុំសូមបញ្ជាក់ថា ការចេញផុតចាកតណ្ហានោះ បានសេចក្តីថា ការចេញផុតស្រឡះចាកវដ្ដៈ គឺដំណើរវិលកើតវិលស្លាប់ ពីព្រោះតណ្ហាជាធម្មជាតិមានកិរិយាធ្វើនូវភពថ្មីជាប្រក្រតី ឬ ជាមេជាងអ្នកតាក់តែងខន្ធ ៥ ឲ្យកើតមានក្នុងភពថ្មីទៀត ជាធម្មតា ។

ម្យ៉ាងទៀត ការចេញចាកតណ្ហា បានន័យថា ការផុតស្រឡះចាកទុក្ខ ពីព្រោះការអស់ទៅនៃតណ្ហា ជាហេតុនាំឲ្យឈ្នះកងទុក្ខគ្រប់យ៉ាង ។

ដោយហេតុថា និព្វានមានលក្ខណសម្បត្តិជាពិសេសដូច្នេះ ទើបនិព្វានឈ្មោះថា លោកុត្តរធម៌ គឺធម៌សម្រាប់ចម្លងសត្វ ឲ្យឆ្លងចេញរួចផុតចាកលោក ដោយប្រការដូច្នេះ ។

## ៣- អំពីនិព្វានសម្បត្តិ

៦និព្វានសម្បត្តិនោះ បានផលការដល់ព្រមដោយបរមសុខ ២ ប្រការ គឺបរមសុខប្រកបដោយកិលេសក្ខយេ ដែលជាផលនៃឧបាទិសេស-សនិព្វាន ឬ កិលេសនិព្វាន និងបរមសុខ ប្រកបដោយទុក្ខក្ខយេ ដែលជាផលនៃអនុបាទិសេសនិព្វាន ឬខន្ធនិព្វាន ។

បណ្ឌិតទាំងឡាយ តែងចាត់ទុកនិព្វានសម្បត្តិ ឬសម្បត្តិនិព្វាន ថាជាកំពូលលើមនុស្សសម្បត្តិ និងទិព្វសម្បត្តិ ពីព្រោះនិព្វានសម្បត្តិនោះ ជានិច្ចធម៌ គឺធម៌ទៀងឋិតថេររកទីបំផុតគ្មាន ព្រមទាំងជាអសង្ខតធម៌ គឺធម៌គ្មានបច្ច័យតាក់តែងឡើយ ។

ម្យ៉ាងទៀត និព្វានសម្បត្តិនោះ មានតេជានុភាពជាពិសេស គឺអាចញុំាងសត្វឲ្យធ្វើដំណើរ ឆ្លងចេញរួចផុតស្រឡះចាកត្រៃលោក ដែលជាហេតុនាំឲ្យសត្វរួចចាកសង្សារទុក្ខ គឺទុក្ខព្រោះដំណើរវិលកើត វិលស្លាប់ រកទីបញ្ចប់គ្មាន ថែមទៀត ។

អាស្រ័យហេតុនោះ បានជាបណ្ឌិតដែលមានសម្មាទិដ្ឋិ រមែងតែប្តេជ្ញាចិត្តប្រាថ្នាចំពោះតែនិព្វានសម្បត្តិ មិនត្រូវការប្រាថ្នានូវសគ្គសម្បត្តិឡើយ ដោយហេតុថាសគ្គសម្បត្តិ នៅលាយឡំដោយបញ្ចពិធកាមគុណ ដែលជាហេតុនាំសត្វឲ្យនៅវិលវល់ ត្រឡប់ទៅមកកាន់ត្រៃភព កើតស្លាប់ ស្លាប់កើត រងទុក្ខវេទនា រកទីបំផុតគ្មាននោះឯង ។

រួមសេចក្តីទៅ ឃើញថា និព្វានសម្បត្តិ ឬសម្បត្តិនិព្វាន ទុកជាសម្បត្តិគួរឲ្យប្រាថ្នា ព្រោះជាសម្បត្តិមានលក្ខណៈប្រសើរ ជាងមនុស្សសម្បត្តិ និង ទិព្វសម្បត្តិពិតមែន ។ អាស្រ័យហេតុនោះ ចំពោះសត្វដែលកំពុងកើតមានសេចក្តីនឿយណាយ ធុញទ្រាន់ នឹងការអន្ទោលកើតស្លាប់ក្នុងឋានមនុស្ស ឋាននរក និង ឋានសួគ៌នោះ គួរចាប់អារម្មណ៍

ទៅរកនិព្វានសម្បត្តិ ពិព្រោះនិព្វានសម្បត្តិនោះ តែងត្រៀមចាំតែចម្លង សត្វពួកនោះ ឲ្យឆ្លងចេញរួចផុតចាកលោក ឆ្ពោះទៅកាន់បរមសុខបាន តាមត្រូវការតែប៉ុណ្ណោះ ។

សេចក្តីអធិប្បាយអំពីនិព្វាន ចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

អ្នកឧកញ៉ា ណា-សាណ អតីតរដ្ឋមន្ត្រីនៅកំពង់ចាម

កុំខ្ជិលកុំល្ងង់ពេក ខំរៀនលេខរៀនអក្សរ
រៀនគ្រប់សព្វធម៌អាថ៌ ប្រាជ្ញាផ្សំនិងគំនិត ។
កំណើតកើតជាមនុស្ស មើលឲ្យធ្លុះពោះធ្លាយជិត
ចេះស្អាត់ប្រាកដពិត គិតការអ្វីបានគ្រប់យ៉ាង ។

បណ្ដាំក្រមង៉ុយ

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែក្លួន
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព.

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ច៉ាង ខាត់ រៀបរៀង*

**អនុ** និ. បន្ទាប់ រង ខាងក្រោយ ។

**អនុ** បុំ. តាមបុគ្គលផ្សេងៗ ។

**អនុកច្ឆម៑** ក្រិ.វិ. តាមស្ទឹង. នៅលើត្រើយ ។

**អនុកថន** នបុំ សេចក្ដីរាយការណ៍ ។

**អនុកនខលម៑** ក្រិ.វិ. នៅលើកនខល (ឈ្មោះកំពង់មួយនៅទន្លេគង្គា) ។

**អនុកម្ប៑** ធាតុ អាណិត, អនុគ្រោះ ។

**អនុកម្បក** គុ. ដែលមានចិត្តអាណិត ។

**អនុកម្បន** នបុំ. សេចក្ដីអាណិត, សេចក្ដីអនុគ្រោះ ។

អនុកម្បា ស្រ្តី សេចក្តីអាណិត, សេចក្តីអនុគ្រោះ ។

អនុកម្បិន គុ. ដែលអាណិត ។

អនុកម្ប្យ គុ. ដែលគប្បីអាណិត ។

អនុករណ នបុំ. ឯនុករណ៍, ការធ្វើតាម, ការធ្វើត្រាប់ ។

អនុកប៌ បុំ. កិរិយារួញ, ជាតរទេះ ។

អនុកប៌ណ នបុំ. កិរិយាយិតធ្លូ ។

អនុកប៌ិន គុ ដែលរួញ ។

អនុកល្ប បុំ. អនុកល្ប, សេចក្តីបង្គាប់បន្ទាប់ ។ គុ. ដែលតាមពាក្យបង្គាប់ ។

អនុកល្បិត គុ. ដែលអនុលោមតាម ។

អនុកាង្ក្ស ធាតុ ប៉ង, ប្រាថ្នា ។

អនុកាង្ក្សិន គុ. ដែលប៉ង, ដែលប្រាថ្នា ។

អនុការ បុំ អនុការ, ការប្រហែលគ្នា, គុ. ដែលប្រហែលគ្នា ។

អនុការិន គុ. ដែលប្រហែលគ្នា, ដែលធ្វើត្រាប់តាម, ដែលធ្វើតត្រូវតាម ។

អនុកាប៌ នបុំ. *អនុការ្យ*; ការងារតទៅ, ការក្នុងអនាគត ។

(នៅមានត)

# ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង

## ដែលមាននៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

លោក ញ៉ុក-ថែម រៀបរៀង

**បំណាងជើង** "សាស្ត្រាទាវឯក (១)"

**អ្នកនិពន្ធ** រកពុំទាន់ឃើញ

**កាលបរិច្ឆេទ** គ្មានបញ្ជាក់ក្នុងអត្ថបទ ។

**របៀបនិពន្ធន៍** ខាងដើម ប្រើកាព្យពាក្យ ៧ ខាងចុង ប្រើបទកាកគតិ និង ពំនោល ។

**ប្រភពរឿង** ក្នុងសម័យលង្វែក (ចលនាខេមរនិយម )

**លក្ខណៈឯកសារ** សាស្ត្រាស្លឹករឹត ជាអក្សរជ្រៀង ១ ខ្សែចប់ ក្នុង ១ ទំព័រមាន ៥ បន្ទាត់ មាន ៣៤ សន្លឹក ។ ឯកសារនេះ ជារបស់ វត្តព្រែកក្រើស ខេត្តកំពត ។

**អត្ថបទផ្តើម** នេះនិងថាថ្ងៃពីនេនទុំ នៅខេត្តបាភ្នំដែនដីស្រែ សង្កាត

---

១ សាស្ត្រាទាវឯក ដែលបានច្បាប់មកអំពីវត្តព្រែកក្រើស ខេត្តកំពត នេះ ជាច្បាប់ដែលភិក្ខុបទុម បានចារចម្លងដាក់វត្ត ក្នុង ព.ស. ២៤៨៦ ។

នៅអត្ថបទផ្តើមរឿងនៃសាស្ត្រាទាវឯកនេះ មានសេចក្តីស្របគ្នា នឹងក្រាំងទាវឯក របស់ពុទ្ធសាសនបណ្ឌិត្យ ប៉ុន្តែដល់ទៅចុងរហូតដល់ចប់ មានន័យប្លែកគ្នាទៅវិញ ។

ក្រាំងទាវឯករបស់ពុទ្ធសាសនបណ្ឌិត្យក្តី សាស្ត្រាទាវឯករបស់វត្តព្រែកក្រើសក្តី គ្មានបញ្ជាក់នាមរបស់កវីនិងកាលបរិច្ឆេទទេ (តាមការយល់ឃើញ ឃើញថា ឯកសារទាំងពីរនេះ ប្រហែលមានចំណាស់ជាងច្បាប់ ទុំទាវ និពន្ធ ដោយព្រះបទុមត្ថេរ ព្រះនាម សោម ? )

សូត្ររៀនចប់អត្ថប្រែ ស្រុកស្រែល្បីគ្រប់សព្វដែនដី ។ បួស
នេននៅវត្តវិហារជ ចិនខ្វារកុះកុំទាំងប្រុសស្រី រៀនសូត្រ
ធម៌អាថិសាស្ត្រាក្តី បទបែបបាលីសឹងចេះព្រម ។ មាននេន
មួយសោតឈ្មោះនេនពេជ្រ រៀនសព្វសេចគ្រេចមានរូបឆោម
វ័ងចំណោះចេះហ៊ានល្មម រូបឆោមមុខល្អយ៉ាងកណ្តាល ។

. . . . . . . . . .

. . . . ។ល។ . . .

អត្ថបទបញ្ចប់ (បទកាកគតិ) រ៉ានេះចិត្តម្នះ ពាលោភារពះ ពុំគោតបេ-
ស្តា អាងតែអាពុក បានជាទកញ៉ា អរជូននោះណា ជា
ស្តេចត្រាញ់ក្រៅ ។ អស់ញាតិណា ១ ដែលម្ចាស់មេត្តា ទុក
ជីវិតនៅ ស្តេចឲ្យចូលជា អ្នកងារវិញទៅ ប៉ុន្មានដែល
នៅ ខេត្តត្បូងឃ្មុំហោង ។

—X—

បំណងជីង "ក្រាំងរាមកេរ្តិ៍ ខ្សែ ១[១]"

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

---

១ ក្រាំងរាមកេរ្តិ៍ ខ្សែ ១ មានលំនាំដើម ដូចសាស្ត្រារាមកេរ្តិ៍ស្លឹករឹត និង សៀវភៅបោះពុម្ព របស់ពុទ្ធសាសនបណ្ឌិត្យដែរ ។

**របៀបនិពន្ធ** ពាក្យកាព្យ បទលោន (សម័យបុរាណ) ។

**ប្រភពរឿង** រាមាយណៈ (រាមកេរ្តិ៍) ។

**លក្ខណៈឯកសារ** ក្រាំងសរសេរដោយទឹកខ្មៅចិន មានគ្របឈើ

ចំនួនសន្លឹក មាន ៨១ សន្លឹក ទំព័រនីមួយ ៗ មាន ៥ បន្ទាត់ ។

ឯកសារនេះ ចុះលេខក្រាំង ១២៧១ ។

**អត្ថបទផ្ដើម** ដងនោះ ព្រះមកុដដ៏ភិរម្យ ប្រសើរដ៏ឧត្ដម ប្រពៃរូពិន

មហាក្សត្រ ។ បំពាក់នូវដញ្ចាំងដុំផិត ស្ដម្ភតារដ៏ពិចិត្រក្រលា

តបៈដុងដោម ។

ក្រលាចម្រើនយោជ សុរិយោធុជដ៏គោងហោម សមិទ្ធិដ៏ស៊ក

ស្ងោម អម្ពប់ត្រសាយសាខា ។ ទឹកធារហូរហួស បន្សាបពិសទូរ

សិលា ព្រមព្រាយលលាយដ៏សោភា ទឹកគង្គាដ៏សាចឡើង ។

. . . . . . ។ល។ . . . .

**អត្ថបទបញ្ចប់** ដូចកលផលបុប្ផាផង ក្រពុំប៉ុបពីទង ស្រពាប់គ្របក

បុស្សបុរ ។ សឹងរីកវែងពោយកេសរ ពង់ពេញគន្ធ ក្បោរប្រែ

ស្មើយល្វើយគន្ធា ។ ក្ដិបបុំចលេចពីទងរ៉ា ខ្ចីចាស់ផលា

ស្រគាលហើយទុំទៀងហោង ។ ក្បោណគាត់ចុះពាកលៃងទង

ដូចកលកំណើតសត្វផង អនោលអន្ទោកកពស្ថាន ។

បំណងជើង "ក្រាំងកាមគេរ្តិ៍ ខ្សែ ២"

អ្នកនិពន្ធ ដូចក្រាំងកាមគេរ្តិ៍ ខ្សែ ១ ។

កាលបរិច្ឆេទ - ដ -

របៀបនិពន្ធន៍ - ដ -

ប្រភពរឿង - ដ -

លក្ខណៈឯកសារ ក្រាំងសរសេរដោយទឹកខ្មៅចិន មានក្របឈើ

ចំនួនសន្លឹក ៧៤ សន្លឹក លេខក្រាំង ១២៧២ ។

អត្ថបទផ្តើម កេរ្តិ៍ពាលកណ្តាលតាស់មរណ៍មាន ជាបរិយោសាន

សម្រេចសម្រាប់សត្វសារិល ។ រូបពន្លកម្ពុជធំបីកន្លែល់ ដូចកល

គម្ពីរមហាមហន្តសមុទ្រ ។ ទោះបព្រះបាទទសរថ មានព្រះ

ជន្មជាកំណត់ មួយសែនគោដិកល្បស្តល់ស្តប់ ។ . .

. . . . ។ល។ . . . .

អត្ថបទបញ្ចប់ ចូរទូលពតិមានអញផង ឥឡូវនេះហោង អសុរកំលួច

អញណា ។ អង្គអញដឹងឯងអាត្មា ទល់ទុក្ខអនិច្ចា មហាអនាថ

ពេកសល់ ។ កុំកើយទោះព្រះបាទស្តេចដល់ ឲ្យព្រះទសពល

នូវព្រះអនុជនរបល័ក្សណ៍ ។ ពីរអង្គពង្សពិស្ណុសិទ្ធិសក្តិ ឲ្យ

ស្តេចពិទក្ខ អសុរដំទ្រើសឬស្សា (១) ។

---

១ អត្ថបទក្រាំងកាមកេរ្តិ៍ ខ្សែ ២ នេះ មានសេចក្តីផ្តើម ចូលទៅក្នុងសៀវភៅរបាះពុម្ពភាគ ២ ត្រង់ទំព័រទី ៤២ បន្ទាត់ទី៨ ឯអត្ថបទបញ្ចប់វិញ បិតនៅក្នុងសៀវភៅបោះពុម្ពភាគ៤ ទំព័រ១២។

បំណាំងជើង "ក្រាំងភមគោត្រ ខ្សែ ៣"

អ្នកនិពន្ធ ដូចក្រាំងភមគោត្រខ្សែ ១ ។

កាលបរិច្ឆេទ -ដ-

របៀបនិពន្ធន៍ -ដ-

ប្រភពរឿង -ដ-

លក្ខណៈឯកសារ ក្រាំងសរសេរដោយទឹកខ្មៅចិន ចំនួនសន្លឹក ៧៦

សន្លឹក និង ១ ទំព័រ លេខក្រាំង ១៦៧៣ ។

អត្ថបទផ្តើម មោហ៍មុះមានះសោះសា លួចលាក់ពាធា ឥឡូវកំនាំះ៧

ហោង ។ ចូរប្រហែស្តង់ទូលបាទផ្តង ឲ្យព្រះអង្គហោង តាមមក

ឲ្យទាន់អញណា ។ នាងផ្តាំព្រៃព្រឹក្សបព្វតា ផ្តាំទេពអង្គា ជ័សីង

នៅភូមិកពហាន ។ . . . . . .

. . . . ។ល។ . . . .

អត្ថបទបញ្ចប់ ពាលីចាប់ព្រហ្មសរថ្វា ទូលទុកសិរសា ហើយក្រាប

ទូលថ្វៃនរិនស្នង ។ បពិត្រអញខ្ញុំត់គត្តង ឥតទោសមួយហោង

នៅព្រះនារាយណ៍ធិបតី ។ ជាប្រុសប្រាកដលោកិយ លេះ

ដូចសាកញី មកធ្វើទូវកលកិច្ចកាច(១) ។

---

១ អត្ថបទផ្តើម នៃក្រាំងភមគោត្រ ខ្សែ ៣ នេះ ឋិតនៅក្នុងសៀវភៅភមគោត្រ ពោះពុម្ពភាគ ៤ ទំព័រ ១២ បន្ទាត់ ១២ ។ ឯអត្ថបទបញ្ចប់ ឋិតនៅក្នុងសៀវភៅបោះពុម្ពភាគ ៥ ទំព័រ ៤២ បន្ទាត់ ៧-៨ ។

បំណងជើង "ក្រាំងភមគោក៍ ខ្សែ ៤"

អ្នកនិពន្ធ ដូចក្រាំងភមគេក៍ខ្សែ ១ ។

កាលបរិច្ឆេទ -ដ-

របៀបនិពន្ធ -ដ-

ប្រភពរឿង -ដ-

លក្ខណៈឯកសារ ក្រាំងសរសេរដោយទឹកខ្មៅចិន មានក្របឈើ ចំនួន សន្លឹក ៣០ សន្លឹក លេខក្រាំង ១២៧៤ ។

អត្ថបទផ្ដើម នេះហៅប្រុសឥតអំណាច ជាប្រុសលេះខ្វាច បម្បាំង កណ្ដាលវណាវគ្គ ។ ចូលចេញមកឲ្យយល់អគ្គ បានជឹង ដើមពន្ធ្យ អម្បូរបុកណាចេស្ដា ។

សំណា ។ ពាលីត្រូវសរសក្ដិថ្លា បាប់សរកេជា- ធិកដទូវដៃស្ដាំទ្រង់ ។ ដៃឆ្វេងកាន់ខាន់កន្ទ្រង វិរេកជាក់អង្គ នាហ៊ានមួយទើបបរហា ។

. . . . . ។ល។ . . . . . . .

អត្ថបទបញ្ចប់ ក្សណស្រីសុជគាទូលយាត់ ក្នុងពត្រីស្វាត់ នោះខ្វាចអសុរ ផងភ្នាក់ ។ ក្រែងព្វដល់ទសមុខយក្ខ ជឹងដើមមានអក្ខ មកចូលក្នុង ប្រាសាទសួគ៌ ។ ទេពីទំទប់អាក់អួល យំភ្នាំងខ្សឹកខ្សួល បន្ទូល បន្ទោសហនុមាន ។ ថាហៃហនុមានហាវហាន បានពតិមាន សំនូវព្រះអង្គមកដល់ ។ ព្រះនុស្លទិព្វថ្លៃមង្គល គឺមោះអញធ្លុំ(១)

១ អត្ថបទផ្ដើមនៃក្រាំង ខ្សែ ៤ នេះ ឋិតនៅក្នុងភមកេរ្តិ៍ បោះពុម្ពភាគ ៥ ទំព័រ ៤២ ។ ឯបញ្ចប់អត្ថបទនេះ ឋិតនៅក្នុងសៀវភៅបោះពុម្ពភាគ ៦ ទំព័ ៣០ បន្ទាត់ . . . . ទៅវិញ ។

បំណងដើង „ក្រាំងរាមកេរ្តិ៍ ខ្សែ ៥"

អ្នកនិពន្ធ ដូចក្រាំងរាមកេរ្តិ៍ខ្សែ ១

កាលបរិច្ឆេទ -ដ-

របៀបនិពន្ធន៍ -ដ-

ប្រភពរឿង -ដ-

លក្ខណៈឯកសារ ក្រាំងសរសេរដោយទឹកខ្មៅចិន មានក្របឈើ ចំនួន

សន្លឹក ២៤ សន្លឹក លេខក្រាំង ១២៧៥ ។

អត្ថបទផ្ដើម មកលបាផ្ដាយសេចក្ដី ។ ពីបាទើបមកដល់ថ្មី មិញតើ

បទដ៏ ក៏បាមិនថ្វាយព្រះទម្រង់ ។ បាមកជ្រើសធ្វើផ្សរផ្សង ស-

សោះអន្ទង ហើយនៃទើបថ្វាយឯក្រោយ ។ . . .

. . . . . ។ល។ . . .

អត្ថបទបញ្ចប់ អញឲ្យមកុដកែវកងករ ដឹមពស្ត្រាពរ រង្វាន់នៃរាជដ៏

ក្រប៊ី ។ ហនុមានឧនសិរស៍ បង្គំនរបតី ទទួលរង្វាន់រាជា ។

អស់មន្ត្រីទូរយោធា គាល់ព្រះរាជា បង្គំប្រណាម្យអភិវាទ[1] ។

—X—

បំណងដើង „ក្រាំងរាមកេរ្តិ៍ ខ្សែ ៦"

---

១ អត្ថបទផ្ដើម នៃក្រាំងរាមកេរ្តិ៍ ខ្សែ ៥ នេះ ប៉ិតនៅក្នុងសៀវភៅបោះពុម្ពភាគ ៦ ទំព័រ៣០ បន្ទាត់ ១០ ។ ឯអត្ថបទបញ្ចប់វិញ ក៏នៅក្នុងសៀវភៅបោះពុម្ពជាមួយគ្នា ទំព័រ៦៣បន្ទាត់ ១០ ។

អ្នកនិពន្ធ ដូចក្រាំងភមកេរ្តិ៍ ខ្សែ ១ ។

កាលបរិច្ឆេទ -ជ-

របៀបនិពន្ធ -ជ-

ប្រភពរឿង -ជ-

លក្ខណៈឯកសារ ក្រាំងសរសេរដោយទឹកខ្មៅចិន ចំនួនសន្លឹក ២៤ មានក្របឈើ លេខក្រាំង ១២៧៦ ។

អត្ថបទផ្តើម កេខុនតម្រួតខុនអាជ្ញា កេខុនក្រឡា- បញ្ជូនរំសេះក្រាក់ ឆារ ។ កេខុនបន្ទាល់មាតាការ ប្រវែងប្រមាណទ្វារ នាដីន គម្ពីរអកប្រាយ ។ ដីនអស់គម្ពីរធិប្បាយ ធ្វើនឈ្មោះត្រើយនាយ ប្រសព្វសមុទ្រយាត្រា ។ . . . . .

. . . . ។ល។ . . . .

អត្ថបទបញ្ចប់ ប្រើយកដៃធ្វេនឯស្រី ទះទៅសិរសី នៃទសមុខបាន បដង ។ នោះសោយចំណាន់ផង ពុំធ្វើឈ្មោះហោង ដំពាក់លុះ ស្លាប់ផងគ្នា ។ ស្រេចហើយហនុមានយាត្រា បេញបរយល់នា ឯក្រៅកំពែងមាសហោង ។

---

១ ក្រាំងភមកេរ្តិ៍ ខ្សែ ៦ មានពីរក្រាំង តែមានសេចក្តីក្រឡូកប្រឡល់ច្រើនអន្លើ គឺ សេចក្តីផ្តើមអត្ថបទ មិនបន្តសេចក្តីពីក្រាំងភមកេរ្តិ៍ ខ្សែ ៥ មកទេ បើប្រៀបធៀបនឹងភមកេរ្តិ៍ បោះពុម្ពខ្សែ ៣ មានរំលងដល់ ៤០ ទំព័រ ពីទំព័ ១ ដល់ ៤០ ។ ឯអត្ថបទបញ្ចប់វិញ ត្រឡប់វិប ទៅរកខាងដើមវិញ ។ វិបត្តិទាំងនេះ ប្រហែលកើតឡើងដោយអ្នកសរសេរចម្លងទេដឹង ? ។

បំណាងដើម "ក្រាំងភមកេរ្តិ៍ ខ្សែ ៦ (ទីពីរ)"

អ្នកនិពន្ធ ដូចក្រាំងភមកេរ្តិ៍ ខ្សែ ១ ។

កាលបរិច្ឆេទ -ដ-

របៀបនិពន្ធ -ដ-

ប្រភពរឿង -ដ-

លក្ខណៈឯកសារ ក្រាំងសរសេរដោយទឹកខ្មៅចិន ចំនួនសន្លឹក ៤៦ មានគ្របឈើ លេខក្រាំង ១២៧៧ ។

អត្ថបទដើម យល់នាងតាំងកៃមួយហោង ចរចាស្នេហ៍ស្នង សំណេះសំណាលទូវគ្នា ។ ជាទេសមុខមហិមា ឥស្សូរសក្តា សម្បត្តិសម្បូរបរិពារ ។ សឹងស្រីសួគ៌ស្រស់ស្រីង្គារ សាន្តសមក្រម-ការ អនេកអស្សុរកញ្ញា ។ . . . . .

. . . . ។ល។ . . .

អត្ថបទបញ្ចប់ អញឲ្យមកុដកែវកងករ ធ្មឹមពស្ត្រាពរ រង្វាន់នៃពជង៌ក្រប៌ ។ ហនុមានទុនសិរសី បង្គំនរបតី ទទួលរង្វាន់ពជា ។ អស់មន្ត្រីទូវយោធា គាល់ព្រះពជា បង្គំប្រណម្យអភិវាទ(១) ។

---

១ អត្ថបទបញ្ចប់ នៃក្រាំងភមកេរ្តិ៍ ខ្សែ ៦ (ទីពីរ) នេះ ដូចគ្នាស្មោះ នឹងអត្ថបទបញ្ចប់នៃក្រាំងភមកេរ្តិ៍ ខ្សែ ៥ ដែរ ។ ដូច្នេះក្រាំង ខ្សែ ៦ ទាំងពីរខ្សែ មានសេចក្តីសាច់រឿងប្រហាក់ប្រហែលច្រើនអន្លើ ។

បំណងជើង "ក្រាំងរាមកេរ្តិ៍ ខ្សែ ៧"

អ្នកនិពន្ធ ដូចក្រាំងរាមកេរ្តិ៍ ខ្សែ ១ ។

របៀបនិពន្ធ -ដ-

កាលបរិច្ឆេទ -ដ-

ប្រភពរឿង -ដ-

លក្ខណៈឯកសារ ក្រាំងសរសេរដោយទឹកខ្មៅចិន មានក្របឈើ មាន ៣៧ សន្លឹក លេខក្រាំង ១២៧៨ ។

អត្ថបទផ្ដើម ក្សណោះអង្គទបង្គករកាយ ទូលបាទដំនារាយណ៍ កណ្ដាលតាហានផងជុំ ។ បពិត្រព្រះបាទខ្ញុំសូមទូល សម្ដែងតេជះ ខ្ញុំ គឺបរមមហាយោធា ។ កុំបីព្រួយហានុមានណា ខ្ញុំសូម អាសា សម្ដេចព្រះនារាយណ៍ធិបតី ។ . . .

. . . . . លៈ . . .

អត្ថបទបញ្ចប់ លុះត្រើយលង្កាភូមិ ពីព្រះចក្រី ក៏រៀបរន្ធះរណរង្គ ។ សឹងត្រៀមសឹងរៀបពលផ្ទង់ ជួតចងគជគង់ គ្រប់អង្គទ័ព បីអធិក ។ ប៉ុនប៉ងទូវប្រទះសាសឹក ហ៊ានហួសឥតក្លឹក ចម្បាំងរណរង្គសោះសា[1] ។

---

១ អត្ថបទផ្ដើម នៃក្រាំងរាមកេរ្តិ៍ ខ្សែ ៧ នេះ ឋិតនៅក្នុងសៀវភៅបោះពុម្ព ត្រង់ទំព័រ ៤៥ បន្ទាត់ ១១ ។ ឯអត្ថបទបញ្ចប់វិញ ស្របគ្នានឹងសៀវភៅបោះពុម្ពដែរ ។

បំណងជើង "ក្រាំង កមកេរ្តិ៍ ខ្មែរ ៨.៩"

អ្នកនិពន្ធ ដូចក្រាំងកមកេរ្តិ៍ ខ្សែ ១ ។

កាលបរិច្ឆេទ -ដ-

របៀបនិពន្ធ -ដ-

ប្រភពរឿង -ដ-

លក្ខណៈឯកសារ ក្រាំងសរសេរដោយទឹកខ្មៅចិន មានក្របឈើ ចំនួន ៥០ សន្លឹក លេខក្រាំង ១២៧៩ ។

អត្ថបទផ្តើម ។ សំណា ។ កពណ៌ទូងគេរឃោសនា ស្រែកស័ព្ទ-គោលា- ហលទាំងកដបុរិទ្ធ ។ ៈនៈឥឡូវថាលក្សណ៍កមិទ្ធ នា-កយណ៍ដ៏ក្រចិទ្ធ នរិទ្ធកមបីទូវលក្សណ៍ ។ . . .

. . . . . ។ល។ . . .

អត្ថបទបញ្ចប់ សម្តេចគាណា ។ ដងនោះ កុម្ភកាណ៌រុកកន់ នាយយក្ខកំណាន់ ទាបានទាំងឆ្វេងស្តាំមក ។ ឲ្យស្រាល់ពលយក្ខរើសរេក ណាបានវៃងមក អាសាកាប់ថ្កាត់ថ្កាយ ។ ឲ្យយកគ្រប់មុខសព្វសាយ ពលយក្ខសម្លាយ បំដោយចមខុនពល ។ ស្រេចហើយកុម្ភកាណ៌មើលយល់ ពិភេកព្រះអនុជផល់(១) ។

---

១ អត្ថបទផ្តើមនៃក្រាំងកមកេរ្តិ៍នេះ ស្របគ្នានឹងសៀវភៅ ភាគ ៨ ដែរ ប៉ុន្តែផល់អត្ថបទបញ្ចប់វិញ ក្រាំងនេះល្អកចូលទៅក្នុងសៀវភៅបោះពុម្ព ភាគ ៩ ត្រង់ទំព័រ ៥–៦ ។

បំណងជើង "ក្រាំង រាមកេរ្តិ៍ ខ្សែ ៩-១០"

អ្នកនិពន្ធ ដូចក្រាំងរាមកេរ្តិ៍ ខ្សែ ១ ។

កាលបរិច្ឆេទ -ដ-

ប្រភេទរឿង -ដ-

របៀបនិពន្ធ -ដ-

លក្ខណៈឯកសារ ក្រាំងសរសេរដោយទឹកខ្មៅចិន ចំនួន ៨៩ សន្លឹក មានគ្របឈើ លេខក្រាំង ១២៨០ ។

អត្ថបទផ្ដើម ក្រដូវកើតក្រៅក្រោធា ។ ថាហៃពិភេកហៅមហា- ទ្រើស ទ្រស្តដេដ្ឋា ប្រែជាសត្រូវវីងឃ្មុំ ។ ពីងអាចក្បត់អញជាបង នាំព្រះរាមធ្វើ សមុទ្រមកបៀតលង្កា ។ អញនូវពិឃាតពង់ឲ្យ មរណា បង់ពីងឯងជា ទុបលល់ចិតលោកហោង ។ . . .

. . . . ។ល។ . . . .

អត្ថបទបញ្ចប់ ត្រាស់ប្រើដេញបរពលមារ នៅក្រៅចក្រពាឡ គឺមូល- ផលាំបក្រតា ។ ក្បិណនោះអសុរលុតលា នៃក្រុងកពណា មហាអសុរដ៏ឥស្សូរ ។ ស្រេចហាំបហោះដល់ក្បិណចូល អញ្ចើញ ក្រុងមូល ផលាំដ៏បរពលមារ(១) ។

---

១ ក្រាំងរាមកេរ្តិ៍ ខ្សែ ៩,១០ នេះ ឋិតនៅក្នុងសៀវភៅរាមកេរ្តិ៍បោះពុម្ពភាគ ៩ ត្រង់ទំព័រ ៦ បន្ទាត់ ៥ រហូតដល់ចប់ភាគ ៩ និងសៀវភៅភាគទី ១០ រហូតដល់ចប់ដែរ ។

បំណងជើង "សាស្ត្រា សុភោគ(១)"

អ្នកនិពន្ធ ចៅពញាកក្ដីសង្គ្រាម (បាល) ។

កាលបរិច្ឆេទ គ្មានបញ្ជាក់កន្លងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាព្យ(បទកាកគតិ-ពំនោល-ព្រហ្មគីត-កុជន្តលីលា)

ប្រភេទរឿង ហាសិបជាតក៍ ឬ បញ្ញាសជាតក ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹតមាន ៤ ខ្សែប់ ។ ខ្សែទី ១ មាន ១៩ សន្លឹក, ទី ២ មាន ២៦ សន្លឹក, ទី ៣ មាន ៣០ សន្លឹក ទី៤ មាន២៦ សន្លឹក ។ ឯកសារនេះ ចុះលេខសាស្ត្រា ១៣៧៥។

អត្ថបទផ្ដើម នេះបទកាកគតិ ។ អញខ្ញុំនេះណា នូនអង្គនមស្ការ

៴ លុតលើកកំបង់ ថ្វាត់ថ្វាយបង្គំ ប្រណម្យនោះត្រង់ ព្រះពុទ្ធព្រះ

សង្ឃ អម្បាលខ្សាច់ហោង ។ ទើបខ្ញុំបង្គំ ព្រះឥន្ទព្រះព្រហ្ម

ជាធំគន្លង នូវអស់ទេព្តា គាពករផង ត្បិតខ្ញុំបំណង ប៉ុនប៉ង-

ប្រាថ្នា ។ ខ្ញុំនឹងសរសេរ តាមដោយដំណើរ ពីព្រះករុណា

កាលយោនយកជាតិ កន្លងវដ្តសង្សារ សូមអស់ទេព្តា ករុណា

ខ្ញុំផង ។ . . . . . . . . .

. . . . . ។ល។ . . . .

---

១ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានថ្លាប់មកអំពីវត្តប្រជុំនទី ហើយបារចម្លងទុកកាលពី គ.ស. ១៩៤៣ ។

**អត្ថបទបញ្ចប់** វែងនាងលំអង បុប្ផាហោងថៃសោភា ជាអគ្គអគ្គជាយា ពុំឃ្លាតឃ្លាជាកន្ទៀ ។ បេរិលវីងយោនយក ជាតិនោះមកក្នុង ភពត្រៃ នាមនាងពិម្ពាថៃ ភិក្ខុនីថេរីហោង ។ រចៅពុទ្ធសេន កជនវេទ្រជាបុត្រច្បង បេរិលវីងមកហោង ពុំឃ្លាតឃ្លាជា ពហុល ។ វីនាងនាថបុត្រី កុមារីទិមិល សំណាងសាងជួបជល់ នឹងកុសលដល់និព្វាន ។ បេរិលវីងយោនយក ជាតិនោះមក គេជះទាន សំណាងសាងមកមាន ឈ្មោះឧប្បលពណ្ណិថេរី ។ វែងព្រះតាបស មានសប្បុរសសេរីសក្យត្រី បេរិលវីងមកខ្ញុំ ជា ព្រះស្រីអគ្គសារីបុត្រ ។ ឯអគ្គព្រះតាបស នៅជ្រោយកោះចាំង សមុទ្រ បេរិលវីងចំហុត ជាព្រះមោគ្គល្លានោ ។ ដំណើរ សរសើរសព្ទ ពាក្យពេចន៍ចប់រឿងពុទ្ធោ ធម្មោសង្ឃោយោ ជាសូរបេចចប់ម្ល៉េះហោង ។

—X—

**បំណងដើង** «សាស្ត្រា ចៅមាស» (១) ។

**អ្នកនិពន្ធ** សុន្ទរពៃនត្យ ។

---

(១) សាស្ត្រាចៅមាស ខ្សែ ១ គ្មានថ្លែងអំពីរឿងរ៉ាវរបស់ចៅមាសៈ៖ · ក្នុងខ្សែនេះ កវីបានទូន្មានឲ្យប្រព្រឹត្តតាមវិន័យព្រះពុទ្ធ ធ្វើអត្ថាធិប្បាយអំពី អនិច្ចំ ទុក្ខំ អនត្តា តាមគោលពុទ្ធនិយម និងច្បាប់សីលធម៌ ៣ប្រការគឺ សច្ចំ ខន្តិ និង កតញ្ញូ ។ ឯខ្សែ ២ ដល់ខ្សែ៤ ទើបកវីរៀបរាប់អំពីរឿងរ៉ាវរបស់ចៅមាស ដោយពិស្តារ ។ កំណាព្យមានលក្ខណៈល្អគួរសម ។

**កាលបរិច្ឆេទ** ថ្ងៃអង្គារ ១ កើត ខែពិសាខ ឆ្នាំច សម្រឹទ្ធិស័ក ព.ស. ២៤៣០ វស្សា (គ.ស. ១៨៨៧) ។

**របៀបនិពន្ធ** ពាក្យកាព្យ (បទកាកគតិ-ពំនោល ព្រហ្មគីត កុជង្គលីលា)

**ប្រភេទរឿង** ហាសិបជាតក ។

**លក្ខណៈឯកសារ** សាស្ត្រាស្លឹករឹត ៥ ខ្សែចប់ ។ ខ្សែទី ១ មាន ២៥ សន្លឹក, ទី ២ មាន ៤០ សន្លឹក, ទី ៣ មាន ៣៧ សន្លឹក, ទី ៤ មាន ៣១ សន្លឹក, ទី ៥ មាន ២១ សន្លឹក ។ ឯកសារនេះពុទ្ធសាសនបណ្ឌិត្យ បានច្បាប់អំពីវត្តហារ ខេត្តកណ្តាល យកមកចម្លង កាលពី គ.ស. ១៩៤៣ ចុះលេខសាស្ត្រា ១៣៧០ ។

**អត្ថបទផ្តើម** នមោតស្សំ ភគវន្តំ អរហតោ សម្មាសម្ពុទ្ធស្សវេព លោកនាថោ តំលោកានំ ។ នមោវខ្ញុំ ក្រាយថ្វាត់បង្គំ ព្រះសម្ពុទ្ធំ ព្រះអង្គជាមកុដ អង្គឧត្តម ប្រោសសត្វទាំង ត្រៃភពកំណត់ ។ សកពជគ្រប់គ្រាន់ គ្រប់បានពីរពាន់ បួនរយទៀតពាត់ សាមសិបវស្សា គណនាដោយបទ ឆ្នាំចនក្សត្រ សម្រឹទ្ធិសកា ។ វិសាខមាសេ កុម្ភារេ មួយកើតឯណា ខ្ញុំនៅត្រេកត្រិះ ស្រេរិះកាព្យា ជាបទកាកា- គតិដោយសុចរិត ។ អហំនាមា

នាមខ្ញុំឯងណា សុន្ទរពិនិត្យ កែកត់ចរិយា មនោសីលសុទ្ធ

ខ្ញុំនៅរិះគិត កាព្យកិច្ចបរិយាយ ។ . . . .

. . . . ។ល។ . . . .

**អត្ថបទបញ្ចប់** និទាននេះ អញខ្ញុំនៅរិះ តាមដោយនូវអាថ៌ ហៅព្រះ

ត្រៃលក្ខណ៍ ជៀងជាក់វិត្ថារ នេះគឺអាចារ្យ តែងចង់ដោយដាន ។

ខ្ញុំថ្លែងតាមបទ តាមបាប់ប្រាកដ អាចារ្យនិទាន បោះបីខុសត្រូវ

ម្ដេចគួរសូមទាន សូមទោសប្រោសប្រាណ អភ័យទោសា ។

ខ្ញុំថ្លែងសេចក្ដី អស់អាថ៌នេះខ្វី តែងចប់ហើយណា និទាន

ពៅមាស ឧកាសថ្លៃថ្លា សូរេចហើយណា និដ្ឋិតចប់ហោង ។

—X—

**បំណងជើង** «សាស្ត្រា ព្រះសូមុត្រ»

**អ្នកនិពន្ធ** អ្នកឧកញ៉ាព្រះឃ្លាំង "ឧង"។

**កាលបរិច្ឆេទ** គ្មានបញ្ជាក់ក្នុងអត្ថបទ ។

**របៀបនិពន្ធ** កាព្យពាក្យ ៧ និងពាក្យ ៩-១០ ។

**ប្រភពរឿង** ហាសិបជាតក ឬបញ្ញាសជាតក ។

---

១ ឈ្មោះចំណងជើងរឿង ច្បាប់ខ្លះដាក់ថា "ព្រះសមុទ្រ" ច្បាប់ខ្លះដាក់ថា "ព្រះសូមុត្រ" ឬមួយជា "ព្រះសូបុត្រ" ទេដឹង? ដោយមានន័យថា បុត្ររបស់នាងសុមាលី ។ ផ្ទៃរឿងមានលក្ខណៈជាបលនាព្រហ្មនិយម ប៉ុន្តែកវីបានបញ្ជាក់ថា ជារឿងជាតកមួយក្នុងបញ្ញាសជាតក ដោយបញ្ចប់រឿង ដោយការសជាតិ ដូចជាជាតកនានាដែរ ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ៦ ខ្សែចប់ដុំជាតក់ ។ ខ្សែទី ១ មាន ៥៨ សន្លឹក, ទី ២ មាន ៦០ សន្លឹក, ទី៣ មាន៥២ សន្លឹក, ទី ៤ មាន ៥៤ សន្លឹក, ទី៥មាន ៦១ សន្លឹក, ទី៦ មាន ៦៤ សន្លឹក បូករួម ៣៤៩ សន្លឹក ។ លេខសាស្ត្រា ១៣៧៣ ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានចម្លងអំពី វត្តប្រជុំនទី យកមកតារចម្លងកាលពី ព.ស.២៤៨៦ ។

អត្ថបទផ្តើម សព្វសព្វតេក្ខសីលា យោជនាគាថានិបាត ខ្ញុំនាមកញ្ញា ឥន្ទ្រព្រះយ៉ាំង ឈ្មោះននតែងតាំងតកាព្យ ។ កាព្យកិច្ចលើក មុន តបទពាក្យ មានបួនប្រាកដប្រាំពីរឃ្លា ពាំនោលព្រហ្មគីត សមសោភា ថាយមហាក្សត្រាម្ចាស់ផែនដី ។ មហាពជនាមា ព្រះអង្គឌួង គ្រប់គ្រងកម្ពុជាម្ចាស់សិរសី ព្រះអង្គពុំទ្រង់សព្វព្រះ ទ័យ ឲ្យតែសេចក្តីជាថ្មីទៀត ។ ទ្រង់សព្វព្រះទ័យពាក្យប្រាំ ពីរ បង្វែរឃ្លាបួនបួនបង្អៀត ហេតុនោះអញខ្ញុំខំប្រឹងធ្វៀត លើក ទៀតដាក់ទុកទំនុកម្ចាស់ ។ ក្រែងជួនដាក់ជ្រួសហួសសេចក្តី វែងខ្លីកាព្យខាតឃ្លាល្បះ ត្បិតខ្លួនខ្ញុំខ្លៅឆៅខ្លាំងណាស់ ក្រែង ខុះជួសប៉ះប៉ពេញផង ។ . . . . .

. . . . ។ល។ . . . .

អត្ថបទបញ្ចប់ អហំឯតឹអង្គអញ បានត្រាស់នេះមិញមិននរណា កិច្ច

ហើយកាលនោះហៅអស្ចារ្យ គណនាពប់ជាតិកោដិកប្បផង ។

ឯអស់ផៅពង្សត្រូវពង្ស ផ្លាស់ជាតិពល់គ្នា សាក្យពជហោង ចូរ

អស់ព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតផង គ្រាប់ត្រង់ស្រង់សេអស់គាថា ។

អស់អាថិបរិយាយបទបញ្ហា តាមដោយកថានេះឯងនៃ បរិបូណ៌

បទអស់សត្វសេចក្ដី ស្ងួរេបហើយនៃចប់ម្ល៉េះហោង ។

—X—

បំណងជើង „សាស្ត្រា ពលក្ខន្ធ(១)„

អ្នកនិពន្ធ បណ្ឌិតខៀវ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់កន្លងអត្ថបទ ។

របៀបនិពន្ធន៍ កាព្យពាក្យ ៧ ។

ប្រភពរឿង រឿងព្រេង ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ៤ ខ្សែចប់ ។ ខ្សែទី១ មាន ២៦ សន្លឹក, ទី ២ មាន ២៦ សន្លឹក, ទី ៣ មាន ២៤ សន្លឹក, ទី ៤ មាន ២៨ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមក អំពីវត្តហារ ខេត្តកណ្ដាល គ.ស. ១៩៤៣ ។ ចុះលេខ

---

១ សាស្ត្រាពលក្ខន្ធនេះ ផ្ទៃរឿងពោរពេញទៅដោយស្ថានភាពកំសត់ ព្រាត់ប្រាស លទ្ធិកម្ម-ផល ឥទ្ធិពល មន្តអាគម និងអច្ឆរិយៈ ។ អ្នកនិពន្ធ បានបញ្ចប់រឿងត្រឹមខ្សែ ៤ នេះ តែអ្នកចារបម្លង ថានៅមានខ្សែ ៥ តទៅទៀត ហើយបញ្ជាក់ថា បានចារចប់នៅថ្ងៃអង្គារ ១២ រោច ខែជេស្ឋ ឆ្នាំមមែ បញ្ចស័ក គ.ស. ១៩៤៣ ។

សាស្ត្រា ១៣៧១ ។

អត្ថបទផ្តើម គោរពនានិទ្ធក្រស្តី- ទីធរប្រសិទ្ធប្រសើរថ្លៃ ថាថ្ងៃនៃចន្ទ ជាសេចក្តី វិន័យនាមខ្ញុំដែលអ្នកតែង ។ ទៀតខ្ញុំបង្គំឆ្ពោះទៅគ្រន់ ព្រះពុទ្ធអង្គជាគម្ពែង នូវគុណព្រះធម៌បវរស្អែង សូមជួយជ្រោម-ជ្រែងបន្ទោទុក្ខ ។ ខ្ញុំសូមបង្គំគុណព្រះសង្ឃ ប្រសើរសឹងទ្រង់ សីលសាន្តសុខ ឲ្យរួចពីភ័យចង្រៃទុក្ខ ពីនេះទៅមុខឲ្យសុខជា ។

. . . . . ។ល។ . . . . .

អត្ថបទបញ្ចប់ បណ្ឌិតទៀតខ្ញុំក្លសម្រេច សជាតិព្រះស្តេចតាមវារៈ ហើយខ្ញុំបញ្ចប់ឲ្យបិតថេរ ទុកគប់ណោរអម្ពុជការ ។ ខ្ញុំសូមនមស្ស-ការពេ ប្រាជ្ញខ្ញុំសេដ្ឋោចិត្តវិសាល ខ្ញុំលើកបញ្ចប់រឿងកុបាល ពលក្ខន្ធវិសាលខែ ៤ ស្រេច ។ ខ្ញុំសូមកុសលជូនទៅលោក មាតាអធិយោគបិតាផ្តាច់ សូមលាភសូមលាភម្តៅរបង្គិច ខ្ញុំសូមសម្រេចបរិបូណ៌ហោង ។

—X—

បំណងជើង "សាស្ត្រា លក្ខណាវង្ស"

អ្នកនិពន្ធ រកមិនទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ហាក់ក្នុងអត្ថបទ

របៀបនិពន្ធ កាព្យពាក្យ ៧ (បទល្បោន)

ប្រភពរឿង . . . . . ?

លក្ខណៈឯកសារ សាស្ត្រាស៊ីករិត មាន ១៥ ខ្សែចប់ ។ ឯកសារ

នេះ ពុទ្ធសាសនបណ្ឌិត្យ បានចម្លងពីវត្តសត្បូរ ស្រុកស្អាង

ខេត្តកណ្ដាល យកមកចារចម្លង កាលពី គ.ស. ១៩៤៣ ចុះ

លេខសាស្ត្រា ៦៧៥ ។

អត្ថបទផ្ដើម ទើបថ្លែងតាមរឿងនិទាន មុនមានបរមវង្សពង្សក្សត្រា

ព្រះបាទព្រហ្មទត្តទ្រង់ឫទ្ធា សោយរាជ្យគ្រងពារាណសី ។

ស្ដេចមានអគ្គឯកនោមនាយា នាមនាងអម្ពាចមមហេសី ។

ជាធំលើសអស់ស្នំសាវស្រី ប្រាំបីហ្មឺនមូលជាបរិពារ ។

អក់រយាយជាស់ទុំអ្នកម្នាងស្នំ សាវឡឹកមេទំស្រីស្រីឝ្គារ

មានរាជចតុរង្គពលយោធា ប្រជារាស្ត្រច្រើនពន់ប្រមាណ ។

. . . . . ។ល។ . . . . .

អត្ថបទបញ្ចប់ វីឯរាជបុត្របួនអង្គា ស្ដេចតែងលីលាមកពារាណសី

សួរអង្គមាតាបិតាទ្វី សាន្ដសុខឥតបីគ្រប់នគរ ។ ស្ដេចសោយ

រាជ្យយូរជាអម្ចង់ យូរទៅព្រះអង្គអស់ជន្មា បានទៅបិតបានទៅ

សួគ៌ា ព្រមទាំងបុត្រក្សត្រទូវមហេសី ។ បានជាទេវបុត្រចំហុត

សល់ នៅសួគ៌ាដល់និព្វានទៃ ឥតមានកង្វល់ពេគាភ័យ ហួស

ទៅដល់នៃនិព្វានហោង ។

(នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

## ភាគ ៧

### (ក)

លោក ឌ. តាម ស្រាវជ្រាវ និង រៀបរៀង

វគ្គ ៧ នេះ និយាយ តាំងតែអំពីព្រះបាទទធរដ្ឋឡើងសោយរាជសម្បត្តិ ហើយព្រះបាទអជបាល អារសាច់ប្ដីងប្ដូរឲ្យតាយព្រានព្រៃសងសាច់ម្រឹគា រហូតដល់ប្រទូតទ័នខុនយក្សឡើងទៅដេញទេវានិងទេពធីតាកញ្ញាស្រីសួគ៌ ហើយព្រះបាទទធរដ្ឋឲ្យទៅនិមន្ត មហាឥសីវនិមន្តមកគិតតាំងពិធីបង្កើតកូនហោង ។

*លុះអស់មន្ត្រីសេនីយ៍សេនា ចាត់ចែងតែងការនោះ រៀបស្រេចហើយ ក៏នាំគ្នាទៅរៀបប្រាសាទស្អាតល្អ បិទបាំងវាំងននមាស ពាសទាំងពិតាន ហើយក៏ធ្យានរៀបអាសនៈក្រាលពូក ត្រៃត្រព្រំ ទៀមចំ ចងទាំងរំហោល កម្រងផ្កា នូវមហាស្វេតច្ឆត្រ ដោតធាយបើកបាំងពីលើបល្ល័ង្ក ហើយ ក្រាលទាំងស្បែកគជសីហ៍ ឃ្នាតខ្និរៀបទាំងទឹកស័ង្ខ ទុកតាមទីអណ្ដាប់ សម្រាប់នៅទីបញ្ចា នៅនាមុខព្រះលាន ធ្វើប្រាំជាន់ខ្ពស់ក្រៃឈ ហើយ មានទាំងឆ័ត្រជ័យ សុទ្ធសឹងតែកែវ និងឆ័ត្រត្រួតមាសប្រាក់ មានរស្មី ភ្លឺប្រាលត្រកាលល្អ ក៏រៀបស្រេចតាមឱង្ការស្ដេចបង្គាប់នោះហោង ៗ រួចហើយ ក៏បង្គាប់ទៅក្រសួងធម្មការ ឲ្យទៅនិមន្តមហាឥសី នៅទីព្រៃ ហិមវ័ន្តអរញ្ញា ទ្រង់នាមាឈ្មោះព្រះវសិដ្ឋ ព្រះស្វាមិត្រមក ៗ*

*គ្រានោះ ពួកសង្ឃការីស្ដាប់ហើយ ពុំលង់ឡើយក៏នាំគ្នាត្រាច់ទៅ កាន់ទីអាស្រមបរមសាលា ៗ ដល់ហើយក៏ចូលទៅនមស្សការបង្គំទូល*

ពិតថា សម្តេចព្រះទ្រង់បុត្រ អយ្យុធ្យាធានី ឲ្យនិមន្តលោកតាទាំងពីរ ទៅ ត្បិតអង្គព្រះអង្គចមទៅ នឹងអភិសេកសម្ពោធព្រះរាជនុរស និងរាជ-ធីតាទាំងបីអង្គ ឲ្យសោយរាជសម្បត្តិ ជាក្សត្រគ្រប់គ្រងពិនមោលី បមធានី ហោង សូមបានជ្រាបសេចក្តី ។

កាលនោះ ព្រះឥសីវាសិទ្ធិ ព្រះស្វាមិត្របានស្តាប់ហើយ ក៏ប្រាប់ទៅបណ្តាមហាឥសីគណៈ ព្រះយោគីទាំងពួង តាមកំណត់ថ្ងៃខែឲ្យបានដឹងគ្រប់ៗ គ្នាហោង ។ លុះដល់កំណត់ហើយ ក៏នាំគ្នាគ្រងគ្រឿងបរិក្ខារតាមភេទតាបសឥសី ស្រេចហើយក៏ឃ្លាតខ្លួននាំឲ្យលីលា ទៅកាន់ព្រះនគរហោង ។ លុះដល់ហើយឥសី ក៏និមន្តឡើងទៅគង់លើប្រាសាទរាជ-មន្ទីរ ទើបព្រះមុនីក៏តាំងសូត្រសៃយវេទ តាមភេទពិធីគម្ពីរព្រហ្ម ។

គ្រានោះ រីឯអង្គព្រះបាទអជបាលធិបតី លុះអរុណរះរង្សី រស្មីស្វាងកាលណាហើយ ព្រះគ្រាណគ្រើយ ក៏ទ្រង់ត្រាស់ប្រាប់ទៅព្រះរាជ-បុត្រា និងរាជធីតាទាំងបីព្រះអង្គ ឲ្យស្រង់រាជម្រះឥន្ទ្រិយ កុំឲ្យល្ងង់វៃវរគនា ។

កាលនោះ រីក្សត្រទាំង ៤ អង្គា បានស្តាប់ព្រះរាជតម្រាស់ត្រាស់ប្រាប់ដូច្នោះហើយ ពុំលង់ឡើយ ក៏ស្តេចទាំង ៤ អង្គ យាងស្រង់ព្រះគង្គាហោង ។ រីអស់ពួកក្មាក់ងាររផង ក៏តាំងមួលខ្មៅនៅព្រះពាងកាងមាសបញ្ចូញព្រះរាជមានក្លិនក្រអូប សុទ្ធតែសេគន្ធា មាលាក្រចេះចួងច័ន្ទ

មាន់ហាម ល្វើយល្វេង ស្រង់ហើយក៏ទ្រង់តែងគ្រឿងរុងរឿង អលង្ការសែនមហាល្អដ៏ពិចិត្រស្អិតស្អាងគ្រប់ ៗ ព្រះអង្គ ស្រេចហើយកាលណាព្រះជនកជននីទាំងពីរក្សត្រ ទ្រង់ទស្សនាទតឃើញ ព្រះរាជធីតានិងព្រះរាជនុរសា មានលក្ខណាឆើតស្រស់ប្រពៃថ្ងៃថ្លាល្អ ៗ សមគ្នា ស្ដេចក៏មានព្រះទយាត្រេកអរណាស់ ហើយស្ដេចក៏យាងយាសនាំរាជនុរសទាំង ៤ ក្សត្រ ចុះចាកពីប្រាសាទស្ថាន លុះបានមកដល់មណ្ឌលទីហើយ ទើបស្ដេចទ្រង់ផ្លាស់គ្រឿងប្រដាប់ព្រះអង្គ ឲ្យក្សត្រទាំង ៤ អង្គ ឲ្យទ្រង់ខោម-ពស្ត្រដ៏មានសម្បុរស្រស់ល្អ រីសំពត់ខោមពស្ត្រនោះ គឺសំពត់ត្បាញធ្វើដោយសំបកសរសៃល្អប្រសើរ ឲ្យស្លៀកស្រេច ស្ដេចក៏ទ្រង់ដឹកដៃរាជនុរសទាំង ៤ ព្រះអង្គឡើងគង់លើសុវណ្ណបញ្ចា ទើបអង្គព្រះបិតាត្រាស់ប្រាប់ទៅព្រាហ្មណ៍បុរោហិតរាជហោរា ឲ្យស្រោចទឹកស័ង្ខនិងប្រសិទ្ធិរសដ៏ក្រអូបក្រអែបដោយនូវគ្រឿងគន្ធមាលាហើយ រីមហាឥសីទាំងពួងនូវព្រាហ្មណ៍បុរោហិតសូត្រស្តុតិជ័យព្រះ ឲ្យពរសិរីសុវត្ថិមង្គលតាមគម្ពីរសៃយសាស្ត្រព្រម ៗ គ្នា ៗ លុះស្រេចមុទ្ធាភិសេកស្រង់ទឹកហើយ ទើបព្រះបាទអជបាលធិបតីនាថ ក៏នាំរាជនុរសាទាំង ៤ ឡើងលើប្រាសាទកែវសុរ្យកាន្តហើយក៏ឲ្យគង់លើបល្ល័ង្ករតនា ក្រោមស្វេត្រឆ័ត្រទាំងបីរាជធីតាអគ្គយាជានោះ ឲ្យអង្គុយតាមអណ្ដាប់គ្នា គ្រានោះ រីអស់ពួកគ្នាក់ងារព្រះភូសា ទើបមន្ត្រីថ្វាយគ្រឿងប្រដាប់ ទ្រង់ប្រាប្តានិងបញ្ចមហាកកុធ-

គណ្ឋា ៗ ភ្នាក់ងារពួកគ្រឿងអស្ចារ្យ ក៏ថ្វាយអស្ចារ្យទៅព្រះអង្គហោង ៗ ពួកព្រាហ្មណ៍រាជបុរោហិត ក៏ដដុះរលាស់ទឹកសម្ប្រថ្វាយ ហើយផុំត្រែស័ង្ខលាន់ព្ទាំងរាត្រី ៗ លុះបានឫក្សពារពេលល្អ ក៏ហោរាឲ្យបើកបាយសីហើយគោះគងទូងស្គរកេរបើដង ហើយបុរោហិតជងអុជទៀនបង្វិលពពិលពីឆ្វេងទៅខាងស្តាំ តាមអណ្តាប់គ្នាទៅវិញទៅមក គ្រប់ព្រះរាជវង្សានុវង្ស ទ្រង់បង្វិលពពិលវិលគ្រប់ ៧ ជុំ ព្រឹទ្ធាជាធំក៏លត់ទៀនជ័យ ចើមថ្វាសបក់ផ្សែងគ្រាប់ទៅលើក្សត្រទាំង ៤ ព្រះអង្គ ៗ

កាលនោះ រីស្តេចព្រះហរិវង្សបិតុរង្គធិរាជ អាចប្រគល់ឲ្យសោយរាជសម្បត្តិ ហើយព្រះអវតារទ្រង់សន្មតព្រះនាម ជាព្រះបាទទធរដ្ឋសុរិវង្សពង្សនារាយណ៍ជ័យបុទ្ធា ៗ ហើយទើបរាជាស្តេចឲ្យពរសុវត្ថិសិរីមង្គលកុំឲ្យមានរោគាព្យាធិ ៗ របណ្តាពួកពាឡបច្ចាមិត្រតិរ័យ ឲ្យបាក់បបខ្ទបខ្ទាចបារមីបុទ្ធទេស្តាគ្រប់ទសទិសា ទីងបានជាទីពឹងពំនឹងពំ-នាក់អាស្រ័យត្រៃលោកទាំងពួង នូវអស់ប្រជាជនជី មួយទៀតឲ្យអ្នកមានវុឌ្ឍិទីឃាយុចម្រើន ១០០ សែនឆ្នាំហោង ៗ រីអស់ពួកមហាឥសីផងក៏ថ្វាយព្រះពរស្រេចហើយ ក៏លាវិលទៅកាន់ទីអាស្រមកុដិវិញហោង ៗ

កាលនោះ រីព្រះបាទអជបាលបុទ្ធិព្យង លុះប្រគល់រាជសម្បត្តិឲ្យឱរសគ្រងស្នងសោយរាជសម្បត្តិស្រេចហើយ ព្រះអង្គក៏ទ្រង់បរិច្ចាគទានកែវកងចិញ្ចៀនមាសប្រាក់ សំពត់អាវ នូវគ្រឿងទាំងពួងសព្វសារពើ

ឲ្យទៅពួកពលមន្ត្រីសេនីយ៍សេនាប្រជាជន ស្រេចហើយ ព្រះអង្គនោះ ក៏ទ្រង់សីលទ្រង់សត្យ សុចរិតទសពិធរាជធម៌ទាំង ១០ ប្រការ ប្រោសចាតុបុស្សា មិច្ឆាទិដ្ឋិ ព្រះអង្គទ្រង់ឧបេក្ខាញាណ កាន់ទៀងត្រង់តាមព្រះពុទ្ធដីកាហោង ។ មានថ្ងៃមួយនោះផង អង្គសម្តេចព្រះទ្រង់ពុទ្ធិគិតចង់ទៅប្រពាតសួនឧទ្យានកំសាន្តព្រះទ័យ ទតមើលរុក្ខជាតិ ក្នុងនាថគិត ស្រេចកឹះស្តេចទ្រង់គ្រឿងប្រដាប់ ស្រេចហើយស្តេចចេញកាន់ព្រះរាជរោងជ័យ ហើយក្នុងទីយក៏ទ្រង់ត្រាស់បង្គាប់ ប្រាប់ទៅសេនីមន្ត្រីជាធំថា ចូរអ្នកចាត់ចែងយោធា រេហ៍ពលពង្ស ទូវរាជរថ ទ្រង់យានជំនិះឲ្យស្រេច ជ្រិតអញនឹងចង់ត្រាច់ទៅប្រពាតសួនឧទ្យានមាលា ។ គ្រានោះ រីមហាមាត្យជាធំ លើកដៃបង្គំទទួលព្រះឧង្ការហើយ ក៏នាំគ្នាតាំងកេណ្ឌកងពួកពលចតុរង្គយោធា តាមដោយក្បួនក្រសាលព្រឹក្សាទីទៃៗហោង ។ រៀបកងមុខសុទ្ធតែពួកកៅវីរ កាន់គ្រប់ដំរីសេះ ៤.០០០ ពលបន្ទាប់នោះដៃសុទ្ធសឹងកាន់កង្វេរ ជិះគជសារ ៣.០០០ រៀបជាគូ ៗ តាមអណ្តាប់ ៗ ចុះបន្ទាប់មកទៀត ក៏រៀបទាហានខមាឡាយុ ១០ កងទាំងអស់ ១០.០០០ ច្បាយហោង ចុះមកទៀតផងក៏រៀបរាជរថ ២.០០០ ដៃកាន់កៅទណ្ឌជ័យ ហើយត្រៀមទាំងរាជរថកែវចរណៃមណីធេតឆាយរង់ចាំស្តេចយាត្រាហោង ។

កាលនោះ រីអង្គសម្តេចព្រះទ្រង់ពុទ្ធិប្បងនោះ លុះព្រឹកព្រាងស្វាង

អរុណោទ័យហើយ  ក្បួនទ័ពក៏ទ្រង់គ្រឿងប្រដាប់ប្រដាគ្រប់អលង្ការស្រេចហើយ ព្រះអង្គស្តេចទ្រង់យានគង់លើពាជីរថកែវសុវណ្ណគន្ធ ហើយស្តេចឲ្យលើកពលទាហានធ្យានយាត្រា ទៅត្រើកគ្រែងនូវស័ព្ទក្ងែងស្គរដូរ្យដន្ត្រីស្រឡៃត្រែសង្ខគាំងគង់ កោលាហលទាំងមណ្ឌលធាត្រីហោង ។

យើងនឹងស្ទុះទំនង នឹងនិយាយពីព្រានព្រៃមួយនោះ ឈ្មោះនៃចរេក ជាអ្នកកេតត្រុកព្រៃហិមពាន្ត រេកដាក់អន្ទាក់បង្កាត់សត្វអម្រឹគីអម្រឹគា ជិតមាត់ផ្លូវព្រៃជាយត្រពាំងហើយ ព្រាននោះ អង្គុយពួន ចាំមើលហ្វូងសត្វប្រើសកាន់មាំងទាំងឡាយនៅកន្ទៃព្រៃធំ លុះអង្គុយសម្ងំយូរបន្តិចទៅ ក៏ឃើញហ្វូងសត្វគ្រាប់ដើរកាត់ ប្រូលប្រសស្រោកមកដូច្នោះហើយ ព្រានក៏សែនត្រេកអរណាស់ ក៏ក្រោកដោយរហ័សទៅស្ទាកពីមុខចាំ ៎សត្វនោះក៏ស្ទុះគេចរត់ វៀះជៀសចេញទៅដោយភ័យភិត មិនគិតមុខក្រោយសោះឡើយ សត្វទ្រាយ ១ ក៏ត្រូវអន្ទាក់ជាប់កន្ត្រាក់ខ្វ.ល់ៗ ស្ទុះស្ទុលនៅជាយព្រៃមាត់ត្រពាំងនោះ លុះព្រានព្រៃនៃចរេក មកមើលឃើញទ្រាយ ១ ត្រូវអន្ទាក់ដូច្នោះ ក៏ស្ទុះរត់ទៅចាប់ដោះយក ក៏ចោចល្វើមកចងជាប់ស្រេចហើយ ពុំលង់ឡើយក៏លើកឡើងពុនដើរទៅផ្ទះអាត្មា ។

កាលនោះ អង្គព្រះបាទអជបាលធិបតី ស្តេចគង់លើពាជីបក្រីក៏ទ្រង់ទតទស្សនា ទៅឃើញនាយព្រានព្រៃពុនសត្វទ្រាយ ១ មកតែកគោកដូច្នោះហើយ ព្រះគ្រាណត្រើយស្តេចក៏ទ្រង់មានព្រះទ័យនោះ

អាណិតសត្វណាស់ ទើបស្ដេចត្រាស់ប្រាប់ប្រើរាជអាមាត្យទៅហៅនាយព្រានមកឯណោះឆាប់ ៗ ។

គ្រានោះ ពួកក្រុមតម្រួតបានស្ដាប់ព្រះតម្រាស់ត្រាស់ប្រើហើយ ក៏នាំគ្នាទៅហៅខ្លួនព្រានព្រៃ លុះដល់ហើយនៃ ក៏ថ្លែងព្រះឧង្ការប្រាប់ថា សម្ដេចព្រះមហាករុណាជាម្ចាស់ ស្ដេចត្រាស់ឲ្យហៅទៅឆាប់ ៗ ។

គ្រានោះ នាយព្រានព្រៃបានស្ដាប់នាយតម្រួតថា ស្ដេចមានព្រះឧង្ការឲ្យហៅអាត្មា ក៏សែនភ័យតក្កមា ញ័រជើងដៃ ថ្នែគិតអារម្មណ៍ខ្លាចមិនអាចនៅបានឡើយ ហើយក៏មកជាមួយរាជបម្រើ លុះបណ្ដើរនាយព្រានព្រៃមកដល់មុខព្រះរាជរថហើយ ក៏ក្រាបថ្វាយបង្គំចាំស្ដាប់ព្រះឧង្ការ ព្រានសែនមហាក្រែងបុទ្ធអំណាចខ្លាចស្មើរនឹងបាត់ស្មារតី ៗ ទើបអង្គព្រះបាទអជបាលធិបតីចក្រី ក៏ទ្រង់ត្រាស់សួរថា ម្នាលនាយព្រានអរញ្ញាហិមវន្តពនាវេសក៍ សត្វព្រាយនេះដែ អ្នកពុនតែកគោកយកមកនោះ តើឯងនឹងកាប់សម្លាប់វា ឬដូចម្ដេច ឬឯងមានកិច្ចយកទៅធ្វើដោយប្រការអ្វី ? ចូរឯងស្ដីប្រាប់មកអញស្ដាប់ឆាប់ ៗ ឥឡូវនេះហោង ។

គ្រានោះ ព្រានវនចរកនោះ លុះបានស្ដាប់ព្រះរាជតម្រាស់ត្រាស់សួរដូច្នោះហើយ ពុំលង់ឡើយក៏លើកដៃក្រាបថ្វាយបង្គំទូលថា ឯទូលបង្គំខ្ញុំព្រះករុណានេះជាតិជាព្រានព្រៃ នឹងត្រូវការសត្វរស់នោះក៏ទេ តែយកទៅដល់ផ្ទះកាលណាហើយ គង់តែប្រហារជីវិតវា គ្រាន់នឹងបានចិញ្ចឹមអាត្មាតទៅ ។

កាលណោះ ព្រះបាទអជបាលចមហៅ ស្តេចបានស្តាប់នាយព្រានព្រៃក្រាបទូលព្រះអង្គ ស្តេចក៏ទ្រង់មានព្រះទ័យនោះសែនសង្វេគ គិតទៅក៏មានមេត្តាអាសូរសត្វព្រាយនោះខ្លាំងណាស់ ទើបស្តេចត្រាស់ថា នែនាយព្រានអើយ ខ្លួនអញនេះ ក៏គិតមកជានិច្ចយូរហើយ ព្រានអើយ ចិត្តអញនេះ នឹងបង់ឲ្យមានជីវិត ឥឡូវនេះ ក៏ត្រូវសមនឹងគំនិតពិតដូចក្តីប្រាថ្នា អញនឹងអារសាច់អញប្តូរនឹងសាច់ព្រាយ ដែលជារបស់ខ្លួនឯងនោះឲ្យវិញ តើព្រានឯងព្រមឬទេ ? ចូរឯងឆ្លើយប្រាប់មកអញនឹងស្តាប់មើល ៗ ទើបនាយព្រាននោះ ក៏ក្រាបបង្គំទូលតបទៅវិញថា ដែលស្តេចមានព្រះឧង្ការនោះ ជាទៀងពិតឬទេ ? ទូលបង្គំជាខ្ញុំពុំអាចហ៊ានទទឹងរឹងទាស់ព្រះទ័យ វិស័យព្រានមិនមានរើសរកថាសាច់សត្វឬសាច់មនុស្សឲ្យតែអាស្រ័យបានជាអាហារ ដែលទ្រង់មានព្រះឧង្ការថា ព្រះរាជទានមំសារបស់ព្រះអង្គឲ្យជាទាន តាមតែប្រោសប្រោណមេត្តាតាមសព្វព្រះទ័យ ៗ ទើបអង្គព្រះកូរន័យបានទ្រង់ស្តាប់ពាក្យព្រានព្រៃ ទូលថាដូច្នោះហើយ ព្រះអង្គក៏មានព្រះឧង្ការថា ម្នាលនាយព្រានអើយ អញនេះ តែមានវាចាថាចេញហើយយ៉ាងណាក៏ប្រាកដពិត អញមិនគិតក្បត់មុសាវាទទៀតទេ អញគ្មានអាល័យជីវជីវិតសោះឡើយ ហើយអញជួយប្តូរជីវិតនឹងសត្វព្រាយមិនឲ្យអន្តរាយជីវិតវាទេ ត្រាស់ហើយទើបព្រះពន្សពុទ្ធស្តេចត្រាស់បង្គាប់ប្រាប់ប្រើសេនា ឯងចូលយកសត្វម្រឹគា

របស់នាយព្រានមកថ្លឹងមើលឲ្យច្បាស់ថ្វាកង កំណត់ទម្ងន់បានប៉ុន្មាន នាឡិ ។ ទើបសេនាបានស្តាប់ឱង្ការព្រះកុមាលហើយ ពុំលង់ឡើយ ក៏ចាប់យកសត្វព្រាយនោះមកថ្លឹងមើលទម្ងន់ស្រេចហើយ ក៏ក្រាបបង្គំទូលថ្វាយថា រីទម្ងន់សត្វនោះណា បានពាក់កណ្ដាលកាតព្រាជ្ជជញ្ជីងជាក់ទាំងមំសៈ និងអដ្ឋិនោះហោង សូមទានជ្រាប ។

គ្រានោះ រីអង្គព្រះទ្រង់អានុភាពចេស្តា ទើបមានឱង្ការថា ឲ្យស្រាយសត្វព្រាយពីចំណងស្រេចហើយ ទើបព្រះត្រាណត្រើយ ទ្រង់ជ្រួចទឹកស្នោទក ជាទិព្វញាណសាក្សី ចូរអ្នកបម្រើនសិរីសុវត្ថិមង្គលា ទីឃាយុយឺនតទៅ ត្រាស់ហើយអង្គព្រះចមបៅ ក៏ឲ្យលែងសត្វព្រាយនោះទៅ លុះលែងស្រេចហើយ ស្ដេចក៏ទ្រង់កាន់ព្រះខ័ន ទ្រង់ប្រកាស នឹងហ្វូងទេវតាបង់ទាំងឡាយ នូវសព្ទកសីថា ហេតុតែគេជះបារមីខ្ញុំបានជួយសង្គ្រោះជោជីវិតសត្វ ឥឡូវនេះ ខ្ញុំនឹងកាត់អាសាច់ខ្ញុំសុំជំនួសសាច់ព្រាយឲ្យទៅនាយព្រាន ។ រីជីវិតប្រាណខ្ញុំនេះ សូមកុំអាលឲ្យខ្ញុំអស់ព្រះជន្ម ដោយគេជះពោធិសម្ភារដែលខ្ញុំបានបរិច្ចាគទានឲ្យនាយព្រានព្រៃ សូមកុំឲ្យខ្ញុំមានក្តីឈឺវេទនា ស្ដេចទ្រង់សច្ចាអធិដ្ឋានស្រេចហើយ ព្រះអង្គក៏ទ្រង់អារសាច់ព្រះអង្គ ឲ្យស្មើនឹងសាច់ព្រាយ ឲ្យនាយព្រាន ហេតុតែបុណ្យអំណាចស្ដេចផ្សងសច្ចា លុះស្ដេចអារសាច់ព្រះអង្គនោះក៏គ្មានឈឺសោះឡើយ ហើយព្រះអង្គអារមំសាព្រះអង្គនោះអស់

អំពីកាយព្រះអង្គ ៗ មិនអាចទីងតម្រង់ព្រះអង្គកាយនោះបានឡើយ ព្រះគុណអើយ ស្តេចក៏ទ្រង់សុវណ្ណគតក្នុងខណៈនោះ មួយរំពេច ។ ស្តេចក៏យាងទៅសោយសម្បត្តិសិតសួគ៌ាហោង ។

គ្រានោះ ទឹងសម្តែងពីអង្គព្រះឥសូរក្សរទ័យថ្ងៃនោះ ព្រះអង្គគង់លើអាសនវង្ស ចក្រទ្រង់ក្តៅក្តួលដូចភ្លើងឆេះ ទើបអង្គព្រះចមមគុទ្ទេសក៍ទ្រង់បើកទិព្វចក្ខុ ទស្សនាមើលមកស្ថានមនុស្សលោកនាយឃើញវង្សព្រះនាពយណ៍កាឡា គឺមហាព្រះបាទអជបាលសុរិយវង្ស អារសាបអង្គជំនួសសងសាបព្រាយ ឲ្យនាយព្រានព្រៃទាល់តែក្សណក្ស័យជីវិតលើកដវថា អង្គព្រះឥស្សរាធិបតី ស្តេចទ្រង់ជ្រាបសេចក្តីហើយព្រះអង្គក៏ទ្រង់ត្រេកអរណាស់ ទើបស្តេចនាំអស់បណ្តាពួកទេពទេវ ជាបរិវារ ហើយក៏ចុះមកមីមា លុះដល់កដវថាព្រះបាទអជបាល ហើយក៏ពយកព្រះសព ហោះទៅទុកនៅឯស្ថានទីគិរីកៃលាសហោង ។

កាលនោះ រីអង្គព្រះបាទទធរដ្ឋសេដ្ឋា លុះឃើញព្រះបិតាស្តេច
៤ ទិវង្គតទៅហើយ ពុំលង់ឡើយ ស្តេចក៏ធ្វើបុណ្យឲ្យទានស្រេចហើយ ព្រះអង្គទ្រង់គ្រប់គ្រងរាជសម្បត្តិ ទំនុកបម្រុងក្នុងលោកា ខេត្តខណ្ឌសីមាអាណាចក្រ អនិត្យអនេក ជាឯកអង្គក្សត្រ ព្រះអង្គទ្រង់មានតេជានុភាពបុទ្ធវឌ្ឍិពុទ្ធាយខ្មខ្មាត្រគ្រប់ទិសា ទាំងព្រាហ្មណ៍ព្រឹទ្ធា បុរោហិតា អាមាត្យមុខមន្ត្រី កវីកជបណ្ឌិត ប្រជាជន ក៏សុខក្សេមក្សាន្ត ព្រោះព្រះអាវគារ

ស្តេចទ្រង់ប្រព្រឹត្ត ទសពិធរាជធម៌តាំង ១០ ប្រការ ដូចត្រៃកែវអលង្ការ បើកបាំងពីលើមោលី ៗ ទីក្រុងក្សត្រតាំងពួងក្រសួងនាំសួយសារជម្ពូរ ផ្កាមាសប្រាក់យកមកថ្វាយ គ្រប់ ១ ស្បា ៗ មួយទៀត ស្រីស្នំក្រម ការនោះ ក៏ជ្រើសរើសរកយកតែរូបល្អ ១ ដូចទេពអប្សរមកថ្វាយតែកល់ឆ្នាំ ហោង ៗ លុះសម័យថ្ងៃមួយនោះ ព្រះអង្គទ្រង់រំពឹងក្នុងព្រះចិន្តា ស្តេច ក៏បង់យាត្រាទៅប្រពាតសួនឧទ្យាន គិតហើយ ព្រះអង្គការស្តេចទ្រង់ គ្រឿងរុងរឿងស្រេច ស្តេចចេញកាន់ចុងព្រះរាជរោងជ័យ ទើបអង្គព្រះ ក្សត្រិយមានព្រះឱង្ការ ប្រាប់បង្គាប់ទៅសេនាអាមាត្យជាធំថា ចូរអ្នក រៀបយោធាពលពន្លប្រគុំរង្គសេនីយ៍ អញនឹងចេញទៅក្រសាលព្រៃសួន ឧទ្យាន ៗ

គ្រានោះ វិធុនអាមាត្យបានស្តាប់ព្រះឱង្ការដូច្នោះហើយ ពុំលង់ ឡើយ ក៏ថ្វាយបង្គំលាវិថយចេញមក ក៏តាំងរើសរកយកសេនាទាហាន ចាត់ជាក្បួនហែ ដើមខ្សែនោះឲ្យពាក់អាវពណ៌ស៊ីចន់ ដៃកាន់កៅទណ្ឌ និងទង់ពណ៌ក្រហមស្រស់ បន្ទាប់ទៀតនោះ ឲ្យកាន់ពណ៌ខៀវពាក់អាវ ស៊ីមួង ស្ពាយដាវចំហៀងស្នា មួយកងទៀតណា ដៃកាន់លំពែង ពាក់អាវបៃតង កាន់ដងទង់ផ្កាមាស ពួកមួយទៀត ក៏ផ្លាស់ឲ្យកាន់ទង់ លឿង ឃុំពលតាំងពួង ពាក់អាវស៊ីសេត ៗ លុះចាត់រួចស្រេច ក៏ត្រៀម ចាំស្តេចយាត្រា ៗ

កាលនោះ ឥន្ទ្រព្រះចមកពមកុដលោកា ស្ដេចមានវាចាត្រាស់ប្រាប់ទៅព្រះអគ្គមហេសីទាំងបី ឲ្យស្រង់ទឹកតែងកាយ ស្រេចហើយក៏ស្ដេចកែក្រាយនាំពជទេពលីលាមកឡើងព្រះពជរថ ស្ដេចក៏គៀនសេនីយ៍ឲ្យបរយាត្រ ត្រាច់ទៅសំដៅតាមមាគ៌ាហាន លុះបានដល់សួនមាលី ស្ដេចក៏បញ្ឈប់យោធីទ័ពជ័យ ក្វៃទ័យក៏ស្ដេចបបួលព្រះពជមហេសី ចុះពីពជរថទ្វី ឃ្មាគយាត្រាទាំង ៤ អង្គ ទ្រង់ត្រាច់ប្រពាតទតរុក្ខជាតិលេងកំសាន្តព្រះទយា រីឯព្រឹក្សសួននោះចំពោះ ទ្រង់ផ្លែផ្កាផលាចាស់ខ្ចីទុំស្រគាលផាលជ័ជាស់ពាសពេញទាំងសួនឧទ្យាន ខ្លះក៏រើបតែមានផ្ការីកស្គុសស្គាយក្រអូបផ្សព្វផ្សាយខ្ចាយសេគន្ធានោះផ្សេង ៗ ស្ដេចក៏ទតកំសាន្តសប្បាយ ៗ

នឹងសម្ដែងថ្លែងនិយាយពីប្រទូតទ័ណ្ឌយក្ស អសុរកស្ថិតស្ថានវិមានក្នុងគុហាកែវមនីរតនា គុហានោះហៅសុរ្យកាន្តបពិតបព្វតា អសុរក៏ល្បីព្រះខ្ទឹរឿងឫទ្ធិខ្លាំងពូកែក្លៀវក្លាហាន មានតេជះមហិមាខ្ពុទ័រសេព្វទិសទិសមានថ្ងៃមួយនោះ អសុរីខ្ទីហោះផ្លោះផ្លោងចង់ល្បងឫទ្ធិ វិទ្យាធរកិន្នរនាគគន្ធព្វកុម្ភ័ណ្ឌ សុបណ្ណគ្រុឌាមហាឥសី នៅក្នុងអំណាចអសុរីខ្ទុនយក្សមិនមានអ្នកណា អាចក្លាហានតឫទ្ធិឡើយ ហើយក្រុងប្រទូតទ័ណ្ឌយក្សនោះពចិត្តលោភលន់ពន់ពេកប្រមាណ អហង្ការក្លាហានកម្រើកឫទ្ធិពគិតចង់បានសម្បត្តិស្ថានទេព ប្រាថ្នាចង់សេពសមមនោរម្យនឹងពួកស្រីទេពអប្សរបរកេញ្ញា អសុរកគិតស្រេចក៏សម្ដែងឫទ្ធានុភាពហោះឡើងទៅតតាំងច្បាំង

នឹងសម្តេចមយុរា ឲ្យបានដូចក្តីប្រាថ្នាហោង ។ លុះអសុរីប្ចុទ្ទិចប្បងហោះ
ដល់ស្ថានទេវនៅជាន់តាវត្តិង្ស ហើយរាក៏គ្រឡេកឃើញពួកទេពទេរា
នឹងហ្វូងទេពកញ្ញា អសុរាក៏រឹងរឹតតែបណ្តាលដួងចិត្តនោះចង់រួមប្រតិព័ទ្ធ
ពេកសល់ អសុរាកំហល់មោហោហមួមៅក្តៅឈួលសញ្ញី ក៏គ្រវីគ្រវាស
សរសេលប្ជ័យរស្មីភ្លឺស្វាងផ្លេក ៗ ដូចភ្លើងកល្បកប្ប ក្រឡាប់ខាំមាត់
សង្កត់ធ្មេញដេញសំពងរាយទេរា ។

គ្រានោះ រីទេវបុត្រទាំងអស់ពួកទេពទេរា លុះឃើញប្រទូតទ័ណ្ឌអសុរា
សម្តែងឫទ្ធានុភាពដេញដូច្នោះហើយ ពុំលង់ឡើយក៏ភ័យភិតតក្កមា ស្មារតី
ភាំងភ្លេច ហាក់ទឹងជាប់ខ្យល់ស្លាប់ នាងទេពធីតាខ្លះ ក៏រត់ប្រញាប់ទៅ
ទីដទៃ ខ្លះក៏ភិតភ័យបិទភ្នែក បិទមុខ ខ្លាចអំណាចនាំគ្នារត់ទៅអឹកអធឹក
កោលាហលចលាចលពាំងស្ថានសួគ៌ស្រី ។

គ្រានោះ ប្រទូតទ័ណ្ឌអសុរីក៏ហោះដេញដិតប្រកិតតាមមកដល់ទី
លតាវ័ន ។

កាលនោះ រីពួកទេវបុត្រទាំងពួកទេពធីតាគេចវេះពីអសុរាកុម្ភ័ណ្ឌ
យក្សា ទៅខ្លះក៏ដឹកដៃគ្នាហោះរត់ទៅគាល់សម្តេចព្រះឥន្ទ្រាធិរាជ ហើយ
ទូលតាមហេតុការណ៍ ។

គ្រានោះ សម្តេចមយុរាបានស្តាប់សេចក្តី ថាអសុរីប្រទូតទ័ណ្ឌ
រាមកដេញកំបាត់កំចាយ ធ្វើបាបអស់ទេវបុត្រទាំងទេពធីតាដូច្នេះ ព្រះអង្គ

ទ្រង់គិតពិគ្រោះពិចារណាថា បើអង្គអញនេះ នឹងប្រើខ័នថ្លាទៅប្រហារ ជីវិតអសុរី ឲ្យស្លាប់ក៏បាន តែថាមិនគួរនឹងការសោះឡើយ ហើយអញ ជាកំពូលពិនលើទេពទេវ នឹងបំផ្លាញឲ្យមរណាពុំបាន បើដូច្នេះមានតែ ឲ្យទៅអញ្ជើញព្រះបាទទទធរដ្ឋ ដ៏មានបុទ្ធិក្លៀវក្លាហាន ជាពង្សវង្សព្រះ អវតារឲ្យធ្យានមកបំផ្លាញវា ទើបនឹងល្បីព្ទទូទ័រទាំងព្រះកេរ្តិ៍យសឈ្មោះ នាមទុកតទៅ លុះគិតហើយ ទើបប្រាប់ទៅមាតុលីទេវបុត្រថា ចូរទឹម រាជរថមហាវិសេស ចុះទៅអញ្ជើញព្រះបាទទទធរដ្ឋ ឲ្យស្តេចមកប្រហារ ជីវិតអសុរកាច់ ៗ ។

វិព្រះមាតុលីសោត បានស្តាប់ហើយក៏បររាជរថហោះចុះមកមួយ រំពេចឯសួនឧទ្យាន លុះបានមកដល់ហើយ ក៏ឃើញអង្គព្រះបាទទទធរដ្ឋ ស្តេចកំពុងតែទតរុក្ខជាតិ ប្រពាតសួនឧទ្យាន មាតុលីក៏ធ្យានចូលទៅ ទូលថា អង្គសម្តេចមយកទេវិន្ទ្រ ឲ្យមកអញ្ជើញព្រះអង្គស្តេចទៅ បង្ក្រាបអសុរឃោរឃៅ ឈ្មោះប្រទូតទ័ណ្ឌយក្ស ។

កាលនោះ វិអង្គព្រះហរិរក្សចក្រពង្សរុងរឿងតេជះ ស្តេចបានបែង ហេតុព្រះមាតុលីទេវបុត្រទូលដូច្នោះហើយ ព្រះអង្គក៏មានព្រះទ័យនោះ ត្រេកអរណាស់ ទើបស្តេចត្រាស់ទៅនឹងអគ្គមហេសីទាំង ៣ ថា ម្នាល កែវកនិដ្ឋាដ៏ចម្រើនអើយ អូនអើយចូរទៅអញ្ជើញវិលទៅកាពកជបុរី ត្បិត បងនឹងឡើងទៅបង្ក្រាប ប្រាបអសុរបច្ចាមិត្រ ឯស្ថានទេវបុត្តិសួគ៌ានាយ ។

កាលនោះ នាងដោមឆាយកែកេសី បានស្ដាប់ត្រាស់ព្រះស្វាមី ហើយ នាងក៏នឹកអរ ទើបព្រះនាងទូលតបវិញថា សូមសម្ដេចព្រះភស្ដាមេត្តាប្រោស សន្ដោសយកខ្ញុំម្ចាស់ទៅផង នឹងបានមើលស្ថានសួគ៌ម្ដង តើដូចម៉េច សប្បាយយ៉ាងណា? មិនដែលឃើញទីងនេត្រាសោះឡើយ ទូលព្រះស្វាមីអោយតាមតែប្រណី ។

កាលនោះ ទើបអង្គព្រះចក្រី ស្ដេចបានស្ដាប់នាងកែកេសីស្នេហ៍ស្និទ្ធ ព្រះអង្គទ្រង់នឹកអាណិតនាងណាស់ ទើបត្រាស់ទៅនឹងនាងទាំង ២ ថា ម្នាលដួងជីវាទាំងពីរនាក់ វរលក្ខណ៍ចូលវិលទៅវិញចុះ កុំតូចចិត្ត ព្រោះត្បិតបងអ្នកនេះ នឹងឡើងទៅស្ថានទេវិន្ទ ច្បាំងនឹងអសុរិន្ទយក្សា ព្រះអង្គបក្រាថាតែម៉ោះ ក៏ស្ដេចដឹកដៃនាងកែកេសី ឡើងទិព្វលើរាជរថា ។ រថអេយរាជរថសម្ដេចអង្គមយក់ មានរស្មីភ្លឺថ្លាដូចកែវមណីរតន៍យល់យង់ ទឹមនឹងអង្គពាជីទេវបុត្របំផុតបុទ្ធិបេស្ដ ព្រះមាតុលីទេវជាសារថី នាងកែកេសីនោះ អង្គុយពីខាងក្រោយ អណ្ដែតលឿនលយ ដោយមេឃានភាល័យ ធ្ងន់ផ្ទុខពូមហាសាគរធំ កន្ទង់ទាំងភ្នំសត្តបរិភ័ណ្ឌ ទេវទ៏កំគៀនមនោម័យ ឲ្យវៃធាប់ប្រញាប់ឲ្យ ពាន់ក្រុមណ្ឌអស្រុក ត្បិតវាកំពុងតែនៅទតស្រួនមាលី លុះបរមកដល់ទីស្ថានតាវត្តិង្ស ១ រំពេច ដូចចិត្ត ដោយឫទ្ធិអំណាចបេស្ដាពលាហកទេព ។

កាលនោះ ក្រុងប្រទូតវ៉ណ្ណអសុរ កំពុងទតសួនបុប្ផាមាលីមាលា អសុរឫទ្ធិក៏បែរក្រឡេកមើលទៅ ឃើញមានមនុស្សានោះជិះលើរាជរថ ហោះសំដៅមកជួបប្រទះចំពោះ មានទាំងអគ្គមហេសីគង់កន្លែងរាជរថាសែនមហាចម្លែក ប្លែកលើសទេវបុត្រទេវតាទាំងឡាយ អសុរឆ្ងល់ឆ្ងាយសេចក្តីណាស់ ទើបត្រាស់ស្រែកទៅថា នែវ៉ើយអ្នកណាក៏គ្មានបានមានឫទ្ធិអានុភាពហ៊ានហោះមកពីមុខអញ មិនក្រែងខ្លាចអំណាចបារមី ឯងតើនាមឈ្មោះអ្វី ពូជពង្សវង្សត្រកូលឯងនៅឯណា ហៅបានគ្មានប្រាជ្ញាមកកេស្លាប់ក្ស័យនឹងដៃអញពុំលែងឡើយណា ៗ

កាលនោះ អង្គសម្តេចព្រះហរិរក្សចក្រា ស្តាប់ហើយ ស្តេចក៏មានវាចាឆ្លើយតបទៅវិញថា នែវ៉ើយ ! អសុរ អញនេះឈ្មោះព្រះបាទធរវង្សនារាយណ៍បុត្រា ដ៏ទ្រង់មានសក្តាតេជះ តបះរិទ្ធិដូចភ្លើងក្រុតសម្តេចព្រះចមកុដកោសីយ៍ ឲ្យយករាជរថីទៅទទួលយកអញ មកប្រហារជីវិតអាឯង ដែលមានចិត្តទុច្ចរិតឫស្សាព្យាបាទទេវិន នៃអាកុម្ភ័ណ្ឌ អាឯងកុំអាលអួតអាងកាងក្រេវ ថាឯងពូកែវិសេសខ្លាំងអហង្ការ គង់តែនឹងឃើញបេស្តាក្នុងគ្រាឥឡូវនេះហោង ៗ

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា ង្វ-គាង ប្រែរៀបរៀង

(ភាគ៣)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ
យូរ-អ៊ុន

តាំងពីព្រះចៅឡៅពី ចេញសំបុត្រទៅតាំង ក្វាន អ៊ូ ជាទាហានខ្លាំងឯក ហើយឲ្យលើកទ័ពទៅវាយយកស្រុក អ៊ួនសៀ រហូតដល់ពេទ្យ ហ្វាតោ វះដៃ ក្វាន អ៊ូ ដែលត្រូវព្រួញ ។

ព្រះចៅឡៅពី ដែលឈរនៅស្រុកហាន់តុងនោះ ក៏បង្គាប់ អ៊ុយអៀន ឲ្យលើកទាហានទៅឈររក្សាស្រុកសែលឿន ត្រួតត្រាមិនឲ្យធ្វេសប្រហែសខ្លួន ព្រះចៅឡៅពីក៏លើកទ័ពត្រឡប់ទៅស្រុកសែឈួនវិញ ឲ្យសាងកំពង់កំពែង ចាត់ចែងស្ថាបនាប្រាសាទដំណាក់គ្រប់បរិបូណ៌ ហើយឲ្យនាមស្រុកនោះជាថ្មីហៅថា ស្រុកសេងតោ ហើយឲ្យប្រុងប្រៀបរៀបបម្រុងសេនាយោធាទិករ នូវគ្រឿងសស្ត្រាវុធ ដែលទំនើបត្រៀម ឲ្យមានព្រមគ្រប់ប្រដាប់ ។

ឯបម្រើដែលចេញទៅគយល្បាត បានស៊ើបដំណឹងដឹងថា ចូចូ និង ស៊ុនគួន គិតគប់គ្នានឹងលើកទ័ពទៅវាយយកស្រុកកេងជីវ ក៏ចូលទៅទូលព្រះចៅឡៅពី ។ ជ្រាបសេចក្ដី ក៏ប្រឹក្សានឹងខុងបេងថា ដែលចូចូនឹងលើក

ទ័ពទៅវាយស្រុកគេងជ័រនោះ នឹងជាដំណើរពិត ឬ ប្រការម្ដេច ៗ

ខុនបេងថា ទូលបង្គំគិតឃើញថា បច្ចុមុខជាលើកទៅមែន ព្រោះវេលានេះ ស៊ុនគួន ជាពួកមួយនឹងគ្នា ហើយមានមនុស្សល្អជាទីប្រឹក្សាច្រើន ញុះឲ្យបច្ចុប្រើពោយ៉ិនទៅវាយយកស្រុកគេងជ័រជាប្រាកដ; ព្រះចៅឡៅពីសួរថា បើដូច្នោះឃើញនឹងគិតប្រការម្ដេច? ខុនបេងថា គួរឃើញនឹងប្រើបម្រើឲ្យនាំសំបុត្រទៅតាំងគួនអ៊ូ ឲ្យឡើងជាតាហានខាងឯក ហើយឲ្យលើកទ័ពស្រួតទៅវាយយកស្រុកអ៊ួនសៀ ឲ្យបានជាមុន មុខជាសត្រូវនឹងបរាជ័យគោតញញើតដៃ ៗ ព្រះចៅឡៅពីឮដូច្នោះ ក៏យល់ឃើញផង ទើបប្រើ ប៊ីស៊ី ឲ្យកាន់សំបុត្រទៅស្រុកគេងជ័រ តាមពាក្យខុនបេងថា ៗ

គួនអ៊ូដឹងថាប៊ីស៊ីមក ក៏ឲ្យបម្រើចេញទៅទទួលនាំចូលទៅអង្គុយកន្លែងទីដំសមគួរ គោរពតាមទំនៀមហើយសួរថា អ្នកមកមានការអ្វី? ប៊ីស៊ីប្រាប់ថា ព្រះចៅឡៅពីប្រើខ្ញុំឲ្យនាំត្រាតាំងមកតាំងលោក ឲ្យឡើងជាតាហានខាងឯក ៗ គួនអ៊ូសួរថា វេតាហានខាងទាំង ៤ នោះ តើតាំងនរណាខ្លះ? ប៊ីស៊ីថា គឺលោក ១, ទៀវហ៊ុយ ១, ជូឡុង ១, ម៉ាឈៀវ ១, ហងតុង ១ ៗ

គួនអ៊ូឮដូច្នោះ ក៏ខឹងណាស់ថា ទៀវហ៊ុយ ជាប្អូនរបស់ខ្ញុំ ជូឡុងសោតក៏បានតាមបងរបស់ខ្ញុំមកយូរហើយ បីដូចជាប្អូនរបស់ខ្ញុំដែរ, ឯម៉ាឈៀវដែលទើបមកចុះគេក៏មានពូជត្រកូលខ្ពស់ គួរណាស់នឹងតាំងឲ្យស្មើគ្នានឹងខ្ញុំ ៗ ក៏ឥតថាទេ ចុះដូចហងតុងនោះ ជាពូជពលតាហានជាតិតាបថោក ហើយជាមនុស្សចាស់ជរាហួសការ មិនគួរនឹងតាំងឲ្យស្មើមុខនឹងអស់

យើងនោះ ដែលមានត្រាតាំងៗ ខ្ញុំវេលានេះ ខ្ញុំមិនបានទទួលទេ ។

ប៊ីស៊ីអស់សំណើច ហើយថា ដែលអ្នកមកខឹងហើយតាំងនិយាយដូច្នេះ មិនត្រូវសោះ ប្រវេណីជាន់ចាស់ក៏មានមកជាធម្មតា ដូចកាលគ្រាសៀវហោ និង ចោធាំ ដែលធ្វើរាជការនឹងព្រះចៅហាន់កោវោនោះ ក៏ជាទីគាប់ព្រះអធ្យាស្រ័យ លុះកន្លងមក ហាន់ស៊ិន ដែលជាពួកព្រះចៅឈប៉ាអងៗ មិនសព្វព្រះទ័យរាប់អាន យល់ថាជាមនុស្សត្រកូលទាប ហាន់ស៊ិន តូចចិត្តតែទៅនៅធ្វើរាជការ ខាងព្រះចៅហាន់កោវោ លើកទ័ពទៅវាយយកស្រុកខាងព្រះចៅឈប៉ាអងបាន ព្រះចៅ ហាន់កោវោ ក៏ឲ្យបំណាច់រង្វាន់ ហើយតាំងជានាម៉ឺនធំមានយសសក្តិខ្ពស់ប្រសើរ ឲ្យទៅឈរនៅស្រុកចេ មានយសសក្តិធំជាងសៀវហោ និង ចោធាំ ដែលជាខ្ញុំរាជការចាស់នោះទៅទៀត; សៀវហោ , ចោធាំ ក៏មិនបានមានចិត្តគិតឥច្ឆាព្យាបាទគ្នា យ៉ាងដូចជាលោកនិងព្រះចៅឡៅពី ក៏បានបដិញាណស្បថជាគ្នាជាបងប្អូន ខ្ញុំនលោកក៏ដូចព្រះចៅឡៅពី ដែលមានត្រាតាំងមកនេះ គួរតែលោកត្រេកអរទទួលបំពេញព្រះទ័យ ជាសេចក្តីរាគខ្លាចគោរពទើបគួរ មិនត្រូវនឹងហ្មងម្លូធ្វើឲ្យទាបព្រះកិត្តិយសដូច្នោះនោះ ឲ្យលោកទទួលទៅចុះ ។

គួនអ៊ូថា កាលពីដើម ខ្ញុំមិនទាន់បានគិត ព្រោះចិត្តរហ័ស ឥឡូវបានអ្នកមករំលឹកដាស់ស្មារតីដូច្នេះ ខ្ញុំក៏នឹករលឹកឡើងបាន បើកុំបានអ្នករំលឹកដូច្នេះ ខ្ញុំក៏បានសេចក្តីខុសប្រាកដ ថាហើយក៏ទទួលយកត្រា

តាំងនោះទៅទុក ប៉ិស៊ីក៏យកសំបុត្រព្រះតម្រាស់ឲ្យទៅគួនអ៊ីហើយថា ព្រះចៅឡោពីត្រាស់ឲ្យលោកលើកទាហាន ទៅវាយយកស្រុកអ៊ួនសៀឲ្យបាន គួនអ៊ីក៏ទទួលធ្វើតាមព្រះតម្រាស់ រួចប្រើចៅស៊ីយិននិងប៉ីហាំងទាំង ២ នាយ លើកទាហានជាទ័ពមុខ ទៅបោះទ័ពនៅក្រៅស្រុកកេងដីឲ្យព្រមហើយ ទើបឲ្យភ្នាក់ងាររៀបតុលៀងឲ្យប៉ិស៊ីបរិភោគអាហារ ទាល់តែដល់យាម ១ ថ្ងាយទើបមក បម្រើចូលមកប្តឹងថា កងទ័ពមុខដែលលើកទៅបោះនៅក្រៅស្រុកកេងដីនោះ កើតភ្លើងឆេះសន្ធឹកសន្ធាប់ណាស់ ។

គួនអ៊ី ឮដូច្នេះក៏ភ័យណាស់ ពាក់អាវក្រោះឡើងសេះស្រូតបរចេញទៅប្រញាប់ បង្គាប់ទាហានឲ្យជួយលត់ភ្លើង ហើយសួរដឹងថាចៅស៊ីយិននិងប៉ីហាំងរវល់តែផឹកស្រាស្រវឹង មិនបានយកចិត្តទុកដាក់និងត្រួតមើលការ បានជាបណ្តាលឲ្យភ្លើងឆេះឡើងដូច្នេះ លុះគួនអ៊ីលត់ភ្លើងរលត់អស់ហើយក៏ត្រឡប់មកវិញ ហើយឲ្យហៅខ្លួនចៅស៊ីយិន និងប៉ីហាំងចូលមកសួរថា យើងប្រើឲ្យខ្លួនទាំង ២ នាក់ លើកកងទ័ពទៅតាំងបន្ទាយនៅខាងក្រៅសិន មិនទាន់នឹងលើកទៅធ្វើការ ហេតុម្តេចបានជាធ្វេសប្រហែសភ្លើងឆេះស្បៀងអាហារនិងគ្រឿងសស្ត្រាវុធអស់ មនុស្សម្នាក្នុងកងទ័ពក៏របួសពិការជាច្រើន ដែលខ្លួនធ្វើឲ្យខូចខាតរបស់រាជការយ៉ាងនេះ យើងនឹងលើកទោសម្តេចបាន ទើបបង្គាប់ទាហានឲ្យយកខ្លួនចៅស៊ីយិន និងប៉ីហាំងទៅសម្លាប់ ។

(នៅមានត)

# កំណត់ហេតុ

អនុសំវច្ឆរមហាសន្និបាតទី ២១ នៃមន្ត្រីសង្ឃ មានកំណត់កាល ៥ ថ្ងៃកន្លះ ចាប់ផ្តើមធ្វើពីថ្ងៃ ១៤ កើត ដល់ថ្ងៃ ៤ រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥០៧ ត្រូវនឹងថ្ងៃទី ១៦ ដល់ថ្ងៃទី ២១ មករា ១៩៦៥ នៅវិហារវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

ថ្ងៃសៅរ៍ ១៤ កើត ខែបុស្ស ជាថ្ងៃប្រកបដោយអភិលក្ខិតសម័យ ដែលគួរឲ្យកត់សំគាល់ ។ នៅក្នុងវិហារវត្តឧណ្ណាលោម មានការតាំងការិយាល័យពិសេសមួយ មានប្រធាន អនុប្រធាន សមាជិក និងលេខាធិការ សំរាប់ទទួលភារៈ ខាងចាត់ចែងកិច្ចការផ្សេងៗ មានធ្វើសេចក្តីកត់ហេតុជាដើម ក្នុងអនុសំវច្ឆរមហាសន្និបាត ។ នៅវេលាម៉ោង ១៤ មន្ត្រីសង្ឃគ្រប់ឋានៈ គ្រប់តំណែង ជាអាទិ៍ ព្រះរាជាគណៈ ឋានានុក្រម មេគណ អនុគណ នៃគណៈមហានិកាយ ក្នុងក្រុង និង ខេត្តក្រៅ និមន្តមកជួបជុំគ្នាជាផ្លូវការ ដើម្បីរួមជាមហាសន្និបាត តាមប្រពៃណីរៀងរាល់ឆ្នាំ ។

នៅពេលបើកសម័យមហាសន្និបាតជាផ្លូវការ ឯ.ឧ. អ៊ិន-តាំ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងធម្មការ មួយអន្លើដោយលោកអ្នកឧកញ៉ា ម៉ែន ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការ ព្រមទាំងសហការីរបស់លោក អញ្ជើញជាអធិបតី ក្នុងការបើកសម័យប្រជុំ ។ សម្តេចព្រះសង្ឃរាជ ថ្នាក់ទី ១ នៃគណៈ មហានិកាយ ទ្រង់ជាព្រះអធិបតី ក្នុងមហាសន្និបាត គ្រប់ទាំង ៥ ថ្ងៃកន្លះ ។ ក្នុងឱកាសបើកសម័យប្រជុំនោះ ឯ.ឧ. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ធម្មការ បានមានប្រសាសន៍ ប្រស្រ័យចំពោះមន្ត្រីសង្ឃ

ទាំងអស់ ក្នុងមហាសន្និបាត មានសម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ជាព្រះប្រមុខ ថា ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា សូមបវារណាដោយស្មោះត្រង់ថា សូមសម្ដេចជាអម្ចាស់ និងមន្ត្រីសង្ឃទាំងអស់ ជួយរំលឹកឬជួយប្រដៅខ្លួនផង ក្នុងពេលណាដែលមានការត្រាំត្រង់ ហើយលោកបានបវារណាទៀតថា តាមតែនៅទីណាក៏ដោយ ទោះនៅតាមខេត្តក្ដី ស្រុកក្ដី ភូមិក្ដី បើបានជួបនឹងទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ហើយមានការត្រូវប្រស្រ័យចំពោះកិច្ចការណាមួយ សូមទ្រង់សព្វព្រះរាជហឫទ័យនិងតាមសព្វព្រះទ័យចុះ ដោយកុំញញើតឡើយ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា និងទទួលបម្រើឲ្យអស់ពីកម្លាំងកាយនិងសមត្ថភាព ដែលអាចធ្វើទៅកើត ៗ លុះចប់សេចក្ដីថ្លែងការណ៍ប្រស្រ័យនឹងមន្ត្រីសង្ឃ នៃឯ.ឧ. រដ្ឋមន្ត្រីរួចហើយ ទើបសម្ដេចព្រះសង្ឃរាជ ទ្រង់សព្វព្រះរាជហឫទ័យទទួលអំណរគុណ រួចហើយព្រះអង្គ ព្រមទាំងមន្ត្រីសង្ឃទាំងអស់ស្វាធ្យាយធម៌ ជយន្តោ . . . ប្រសិទ្ធពរជូន ឯ.ឧ. រដ្ឋមន្ត្រី ព្រមទាំងសហការី ៗ បន្ទាប់មក សម្ដេចព្រះសង្ឃរាជ ទ្រង់សព្វព្រះរាជហឫទ័យព្រះរាជានុញ្ញាតបើកឱកាស ឲ្យលោកមេគណគ្រប់ខេត្ត ធ្វើសេចក្ដីថ្លែងការណ៍រៀបរាប់ អំពីព្រះពុទ្ធសាសនាក្នុងខេត្តនីមួយ ៗ រៀងរាល់ខ្លួនជាបន្តបន្ទាប់គ្នា ៗ នៅក្នុងសេចក្ដីរាយការណ៍នីមួយ ១ ខ្លះក៏មានធ្វើសំណូមពរអំពាវនាវនិងយោបល់ ថ្វាយ ប្រគេន ដល់មហាសន្និបាត

ដល់រាជរដ្ឋាភិបាល សូមឲ្យជួយរិះរកមធ្យោបាយយ៉ាងណា ដើម្បីឲ្យព្រះពុទ្ធសាសនាបម្រើនរុងរឿង ។ នៅពេលដែលចប់សេចក្តីរាយការណ៍នៃព្រះមេគណនីមួយ ។ សម្តេចទ្រង់សព្វព្រះរាជហឫទ័យ ទទួលអំណរគុណ ហើយទ្រង់សរសើរមន្ត្រីសង្ឃខ្លះ ដែលខិតខំយកចិត្តទុកដាក់បំពេញមុខការរបស់ខ្លួន ។ សេចក្តីរាយការណ៍ របស់ព្រះមេគណខ្លះដែលមានជាប់ទាក់ទងដល់ក្រសួងសម្តេចព្រះសង្ឃរាជ ឬរាជរដ្ឋាភិបាល សម្តេចសុំទុកមានព្រះបន្ទូលរែកញែកបញ្ជាក់ថែម ឲ្យបានច្បាស់លាស់ដល់ទីប្រជុំ ដើម្បីកុំឲ្យមានការសង្ស័យ ។ លុះចប់សេចក្តីរាយការណ៍របស់ព្រះមេគណគ្រប់ខេត្តហើយ ទើបសម្តេចទ្រង់ប្រោសព្រះរាជទានបើកឱកាសដល់មន្ត្រីសង្ឃគ្រប់រូប ដែលចង់ស្នើបញ្ហាអ្វីផ្សេង ។ ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ព្រះពុទ្ធសាសនា ឲ្យឡើងកាន់ទីគ្រោសនសព្វចំពោះព្រះភក្ត្រ និងចំពោះមុខមហាសន្និបាត ដើម្បីថ្លែងនូវបុព្វហេតុនិងយោបល់ខ្លួន ដែលនាំឲ្យកើតជាបញ្ហានីមួយ ។ ឡើង ។ បញ្ហាដែលមន្ត្រីសង្ឃយកមកសុំចុះក្នុងរបៀបវារៈ មានជាច្រើនបញ្ហា ។ បណ្តាបញ្ហាទាំងនោះ បញ្ហាខ្លះ ត្រូវមហាសន្និបាតដោះស្រាយសម្រេចជាភ្លាម, បញ្ហាខ្លះ សម្តេចទ្រង់ដោះស្រាយសម្រេចដោយផ្ទាល់ព្រះអង្គ, មានបញ្ហាខ្លះទៀត ដែលពុំសូវមានប្រយោជន៍ មហាសន្និបាតទុកជាមោឃៈ ដូចខាងក្រោមនេះ :

១- មេគណខេត្តកំពង់ចាម បានស្នើអំពីពួកលោកអ្នកធ្វើសមាធិខ្លះ ច្រើនតែនាំគ្នាផ្តួចផ្តើមកសាងវត្តថ្មី ទៅទីព្រៃក្បែរ ៗ វត្តចាស់ ដោយឥតមានច្បាប់អនុញ្ញាតពីរាជការមុខក្រសួងមានសមត្ថកិច្ចសោះ ទោះបីមន្ត្រីសង្ឃសាលាអនុគណ ឬសាលាគណ ហាមប្រាម ក៏មិនស្តាប់ ហៅឲ្យចូលមកសាលាអនុគណ ឬសាលាគណ ក៏មិនព្រមមក ។ ចំណែកខាងមេគណខេត្តកំពត ក៏មានការស្នើអំពីរឿងលោកអ្នកធ្វើសមាធិនៅទីព្រៃចេះតែនាំគ្នាកសាងវត្តថ្មីបែបនេះដែរ ។ សម្តេចព្រះសង្ឃរាជទ្រង់មានព្រះបន្ទូលក្នុងរឿងនេះយ៉ាងវែង ហើយទ្រង់បញ្ជាក់ ថា រឿងកសាងវត្តថ្មីនេះ មានចែងក្នុងច្បាប់រាជការគ្រប់គ្រាន់អស់ហើយ មិនមែនចេះតែកសាងបាន តាមអំពើចិត្តរបស់ខ្លួននោះទេ ហើយជាភារៈលើលោកចៅហ្វាយខេត្ត-ស្រុកជាដើមទទួលការខុសត្រូវផង ។ សម្តេចព្រះពោធិវ័ង្ស បានបន្ថែមសេចក្តី ថា រឿងនេះ សូមសម្តេចព្រះសង្ឃរាជ.ចេញព្រះសង្ឃរាជ.ប្រកាស ហាមប្រាមយ៉ាងតឹងរ៉ឹងទៅគ្រប់ខេត្ត ដើម្បីកុំឲ្យពួកភិក្ខុទាំងនោះប្រព្រឹត្តធ្វើតាមទំនើងចិត្តដូច្នេះ តទៅទៀត ។ មហាសន្និបាតបានសម្រេចសេចក្តី ជាឯកច្ឆន្ទ យល់ស្រប តាមសម្តេចព្រះពោធិវ័ង្សដូច្នោះដែរ ។

២- មេគណខេត្តព្រៃវែង ស្នើសុំឲ្យរៀបចំស្រុកពាមជរមានអនុគណត្រឹមត្រូវតាមផ្លូវច្បាប់ដូចស្រុកឯទៀតឡើង ពីព្រោះស្រុកពាមជរនេះ នៅក្នុងខេត្តព្រៃវែង ជាស្រុកចុងកាត់មាត់ញក ឋិតនៅជាប់នឹងព្រំប្រទល់ដី

ស្រុកឃ្លួនផង, ក្នុងស្រុកពាមជរនេះ មានវត្តពុទ្ធសាសនិក ប្រហែលជា ៦ ឬ ៧ វត្តដែរ គួរតែបង្កើតរៀបចំឲ្យមានអនុគណឡើង ដើម្បីរក្សាការពារព្រះពុទ្ធសាសនានៅទីនោះឲ្យបានរីកចម្រើនឡើង ។ សម្ដេចទ្រង់មានព្រះបន្ទូលថា នឹងជួយលៃលកឲ្យបានសម្រេចតាមសេចក្ដីស្នើនេះ ។

៣- មេគណខេត្តព្រៃវែងដែល ទូលស្នើរលឹកអំពីរឿងកែប្រែចម្រង់សាលពុទ្ធិកបឋមសិក្សា ដែលមហាសន្និបាតបានសម្រេចជាឯកច្ឆន្ទកាលពីឆ្នាំ ១៩៦៤ ហើយនោះ ។ សម្ដេចព្រះពោធិវង្ស ជាអគ្គាធិការនៃពុទ្ធិកសិក្សាបានបញ្ជាក់ថា រឿងនេះពជការកំពុងតែគិតគូររៀបចំហើយ, ឯប្រាក់ថវិកាជាតិ ក៏ពជការបានគ្រោងទុកបម្រុងហើយដែរ ព្រោះកាលពីថ្ងៃទី ១៧ មករា ១៩៦៥ ក្នុងឱកាសជួបជុំមន្ត្រីសង្ឃ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត សម្ដេចព្រះប្រមុខរដ្ឋទ្រង់មានព្រះបន្ទូលថា នឹងជួយការនេះឲ្យខាងតែបានសម្រេចប្រគេន; ហេតុនេះ សូមមហាសន្និបាតសង្ឃមទុកចុះ ប៉ុន្តែក្នុងឆ្នាំ ១៩៦៥ នេះ ត្រូវទុកឲ្យនៅដដែលដូចជាឆ្នាំមុនៗ សិនៗ

៤- មេគណខេត្តតាកែវ ស្នើសុំឲ្យបង្កើតពុទ្ធិកវិទ្យាល័យមួយ នៅខេត្តតាកែវ ។ សម្ដេចព្រះពោធិវង្ស បានពន្យល់អំពីថវិកាជាតិកំពុងទន់ខ្សោយ, ការបង្កើតពុទ្ធិកវិទ្យាល័យនីមួយ ១ ត្រូវចំណាយប្រាក់កាសអស់ជាច្រើនណាស់ក្នុងមួយឆ្នាំ ១, ដោយហេតុនេះ ឃើញថា ពុំអាចនឹងសម្រេចតាម សេចក្ដីសុំរបស់យើងបានភ្លាម ១ ទេ ។

៥- សម្តេចព្រះពោធិវ័ង្ស ស្នើយោបល់ចំពោះមហាសន្និបាត ដើម្បីកែប្រែមណ្ឌលប្រឡងចេញនៃសាលាពុទ្ធិកបឋមសិក្សា ក្នុងព្រះរាជអាណាចក្រទាំងមូល គឺក្នុងមួយខេត្ត ឲ្យមានមណ្ឌលប្រឡង ត្រឹមតែមួយមណ្ឌលប៉ុណ្ណោះ ដើម្បីឲ្យស្រួលក្នុងការត្រួតត្រាឲ្យបានដិតដល់ ។ មេគណ គ្រប់ខេត្ត ព្រមទាំងមន្ត្រីសង្ឃទាំងអស់ ក៏បានយល់ស្រប តាមសេចក្តីស្នើនេះ ។

៦- មន្ត្រីសង្ឃខ្លះ ស្នើថា គួរធ្វើយ៉ាងណា ដើម្បីកុំឲ្យគ្រហស្ថចូលមកធ្វើអន្តរាគមន៍ជ្រៀតជ្រែក ក្នុងរឿងអធិករណ៍នៃសង្ឃ ព្រោះអធិករណ៍ទីមួយ ៗ បើបណ្តោយតាមតែសង្ឃនិងសង្ឃ មិនជាយូរប៉ុន្មានទេ ឆាប់ស្ងះជាបាត់ទៅវិញ, កាលបើមានគ្រហស្ថណាមួយ ចូលមកជ្រៀតជ្រែកកាន់ជើងហើយ អធិករណ៍នោះត្រឡប់ទៅជារ៉ឹងត្អឹង ប្តឹងផ្តល់មិនចេះចប់ ។ សម្តេចទ្រង់មានព្រះបន្ទូលថា ក្នុងព្រះវិន័យពុទ្ធសាសនា មានច្បាប់ពិសេសមួយ ដែលសង្ឃត្រូវធ្វើពិធីសូត្រផ្កាប់បាត្រ-ផ្ងារបាត្រ ជាកិច្ចដាក់ទណ្ឌកម្មចំពោះគ្រហស្ថខិលខូចឲ្យរាងចាល គួរតែស៊ើរើបង្កើតច្បាប់នេះឲ្យមានឡើង កុំឲ្យគប់កំបាំងនៅតែក្នុងគម្ពីរ ។ មហាសន្និបាត បានសម្រេចជាឯកច្ឆន្ទ ថ្វាយព្រះភារកិច្ចនេះចំពោះសម្តេចព្រះសង្ឃរាជ ធ្វើសៀវភៅ ស្តីពីការសូត្រផ្កាប់បាត្រ-ផ្ងារបាត្រ ដើម្បីចែកមេគណ អនុគណ និងចៅអធិការគ្រប់វត្ត ឲ្យយល់ច្បាប់នេះខ្លះផង ។

៧- អនុលេខាធិការ អនុគណស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ស្នើសុំឲ្យមានបញ្ញត្តជាដាច់ខាត ចំពោះចៅអធិការវត្តខ្លះ ដែលចេះតែលបពង្រីកកសាងវត្តថ្មី ដែលគ្មានការយល់ព្រមពីក្រសួងមានសមត្ថកិច្ច ។ មហាសន្និបាត មានយោបល់សម្រេចថា កាលណាចង់កសាងវត្តថ្មី ត្រូវតែធ្វើពាក្យមាន ថ្វាយសម្ដេចព្រះសង្ឃរាជ ឬ ប្រគេនពាក្យមានទៅអនុគណ មេគណ ឬ ក៏ចៅហ្វាយស្រុក-ខេត្ត ដើម្បីពិនិត្យកន្លែងនោះ ជាមុនសិន ។

៨- ព្រះមុនីកោសល សួរ-ហាយ ចៅអធិការវត្តនិពេធវង្ស ស្នើសុំឲ្យតាំងគណៈកម្មការសង្ឃមួយ ក្រោមព្រះរាជាធិបតីភាពនៃសម្ដេចព្រះសង្ឃរាជ ដើម្បីទិមទួមគ្រឿសង្ឃខ្លះ ឬចៅអធិការ ឬក៏គ្រូសូត្រគ្រប់វត្ត ក្នុងព្រះរាជអាណាចក្រ ខាងគណៈមហានិកាយ ឲ្យចូលមកប្រជុំអប់រំ ដើម្បីឲ្យចេះធ្វើការ ក្នុងករណីយកិច្ចផ្សេងៗ មានការហាត់សូត្រធម៌ជាដើម ។ បញ្ហានេះ សម្ដេចព្រះសង្ឃរាជ ទ្រង់សព្វព្រះរាជហឫទ័យយល់ថា គួរតែឲ្យបង្កើតឡើង ព្រោះជាការមានប្រយោជន៍ច្រើនណាស់ ។ មហាសន្និបាត បានយល់ស្របតាមសេចក្ដីស្នើ របស់ព្រះមុនីកោសល សួរ-ហាយ នេះ ។ សម្ដេចព្រះពោធិវង្ស ជួយគាំទ្រសេចក្ដីស្នើនេះ ដោយពេញព្រះហឫទ័យផងដែរ ។

៩- មេគណខេត្តកណ្ដាល ស្នើអំពីសីមាកម្ម គួរសង្ឃធ្វើយ៉ាងណា

ឲ្យមានរបៀបបែបបទតែមួយ ។ សម្តេចព្រះសង្ឃរាជ ទ្រង់មានព្រះបន្ទូលថា ខ្ញុំករុណា មានបំណងនឹងធ្វើសៀវភៅសមាគមមួយ ហើយនឹងសៀវភៅបត្តដូចសម្បទាមួយទៀត សូមមហាសន្និបាតសង្ឃឹមចុះ បើជីវិតទៅមាន ។

១០- អនុលេខាធិការ តំបន់ល្វា ខេត្តបាត់ដំបង ស្នើសុំឲ្យកែប្រែសទ្ទឹកឆាយា ឬសង្ឃដីការបៀបវាស់សព្វថ្ងៃនេះ ឲ្យមានបែបភាពជាថ្មីវិញ គឺធ្វើកូនសៀវភៅតូច របៀបដូចជាលិខិតឆ្លងដែន ឲ្យមានកម្រាស់ប្រហែលជា ៨ ឬ ៩ សទ្ទឹក ជាការងាយស្រួលចុះទិដ្ឋាការនៃចៅអធិការទាំងឡាយ ។ សម្តេចព្រះពោធិវង្ស បានជួយគាំទ្រ ហើយបញ្ជាក់ថ្វាយសម្តេចព្រះសង្ឃរាជថា ទូលព្រះបង្គំយល់ថា បើធ្វើជាសៀវភៅតូចវិញនោះ ជាការស្រួលណាស់ក្នុងការចុះទិដ្ឋាការម្តង ៗ ។ មហាសន្និបាតបានយល់ព្រមតាមទាំងអស់ហើយ ។ សម្តេចព្រះសង្ឃរាជទ្រង់សព្វព្រះរាជហឫទ័យថា គួរដែរហើយ ប៉ុន្តែសូមប្រគល់ឲ្យក្រសួងធម្មការរួមជាមួយនឹងក្រុមជំនុំគិតគូរធ្វើឲ្យសមរម្យល្អ ហើយចាត់ការបោះពុម្ពចំណាយថោក ។ ដើម្បីឲ្យបានកម្រៃខ្លះដល់ក្រសួង ទោះបីក្រសួងនេះ ប្រគល់ឲ្យឯកជនណាមួយធ្វើក៏ដោយ ។

១១- អនុគណស្តីទី ស្រុកមុខកំពូល ខេត្តកណ្តាល ស្នើអំពីរឿងជូនដំណឹងឧបោសថ៍, ការជូនដំណឹងឧបោសថ៍ គួរតែលោកអ្នកសួរនិងលោក

អ្នកធ្វើយបុព្វករណៈ- បុព្វកិច្ច អង្គុយនៅខាងក្រោមដិតក្រែ សួរធ្វើយឲ្យហើយស្រេច រួចហើយសឹមលោកអ្នកសម្តែងបាតិមោក្ខ ឡើងអង្គុយលើក្រែសម្តែងតែម្តង ៗ សម្តេចព្រះសង្ឃរាជ ទ្រង់សព្វព្រះរាជហឫទ័យថា គួរតែធ្វើយ៉ាងនេះទាំងអស់គ្នា ៗ សេចក្តីស្នើនេះ ទុកជាបានការ សុំឲ្យមហាសន្និបាតសម្រេចយកតាមបែបនេះ ធ្វើឲ្យដូចគ្នាទៅ កុំឲ្យខុសរបៀបគ្នា ៗ មហាសន្និបាត ក៏បានបញ្ចេញមតិយល់ស្រេច ទាំងអស់គ្នាហើយ ៗ

១២- ព្រះមុនីកោសល សួរ-ហាយ ស្នើសុំឲ្យមេគណគ្រប់ខេត្ត ធ្វើសេចក្តីរាយការណ៍ ក្នុងឱកាសអនុសំវច្ឆរមហាសន្និបាតម្តង ៗ បញ្ជាក់ឲ្យបានច្បាស់លាស់ អំពីវត្តដែលនៅក្នុងខេត្តរបស់ខ្លួនថា តើវត្តណាខ្លះដែលមិនទាន់រៀនសូត្រធម៌វិន័យត្រឹមត្រូវ- សាមណេរនៅត្រង់ចំពោះ- នៅប្រើបីពារថ្មើរប្រែក មានចំនួនប៉ុន្មានវត្ត ដើម្បីយកមកចំរៀនក្នុងបញ្ជីស្ថិតិ ៗ

១៣- សម្តេចព្រះសង្ឃរាជ ទ្រង់ធ្វៀតឱកាសរំលឹកចំពោះមន្ត្រីសង្ឃដោយន័យជាច្រើន :

ក- ឲ្យនាំគ្នាអនុវត្តតាមព្រះសង្ឃប្រកាស លេខ ៥២ណ. ចុះថ្ងៃទី ២ កញ្ញា ១៩៦៣ ស្តីពីការធ្វើទោសបោសថកម្ម ៗល ៗ

ខ- កាលណាបើមានធ្វើបុណ្យបូជាសព ឬ បុណ្យបញ្ចុះសីមាជាដើម មិនត្រូវឲ្យអ្នកបួស ឬ គ្រហស្ថស្រែកឃោសនាបច្ច័យ ឲ្យពារឬសម្ទេងឡូឡា តាមទំនៀមសន្ដ័ព្ទឡើយ ៗ ល ៗ

គ. សុំឲ្យ មេគណ អនុគណ ពន្យល់ចៅអធិការគ្រប់វត្ត ឲ្យចេះសរសេរឆាយា ឬ សង្ឃដីកា ឲ្យបានត្រឹមត្រូវឡើង ។ល។

ឃ. ការចុះហត្ថលេខាលើទិតអ៊ូមួយ ត្រូវតែនាំគ្នាធ្វើអក្សរខ្មែរ ដើម្បីឲ្យសមនឹងប្រទេសយើង ជាប្រទេសឯករាជ្យ ។ល។

ង. ធ្វើសេចក្ដីថ្លែងការណ៍មកថ្លែងក្នុងមហាសន្និបាត ត្រូវបញ្ជាក់ឲ្យច្បាស់ថា ចៅអធិការវត្តណា ឈ្មោះអ្វី ដែលរឹងទទឹងមិនព្រមចូលមកកាន់ទីប្រជុំ ។ល។

ច. អំពីការប្រើប្រាស់បាត្រ; បាត្រពុំគួរបោះបង់ចោលឡើយ ព្រោះសព្វថ្ងៃនេះ សង្កេតទៅឃើញថា បព្វជិតខ្លះ ចេញពីវត្តមួយទៅនៅវត្តមួយទៀត ច្រើនតែបោះបង់បាត្រចោល មិនយកទៅជាមួយនឹងខ្លួន, ហេតុនេះ សុំឲ្យ មេគណ អនុគណ និងចៅអធិការគ្រប់វត្ត ហាមប្រាមចំពោះសិស្សគណរបស់ខ្លួន ក្នុងរឿងនេះឲ្យម៉ឺងម៉ាត់ កុំចេះតែបណ្ដោយទៅៗ ។ល។

ចំណែកខាងបញ្ហាដទៃទៀត ដែលមន្ត្រីសង្ឃខ្លះ ស្នើសុំឲ្យចុះក្នុងរបៀបវារៈនោះ គណៈកម្មការការិយាល័យបានពិនិត្យទៅឃើញថា បញ្ហាខ្លះ មាននៅក្នុងករណីយកិច្ច ដែលបានចែកពីឆ្នាំមុនសព្វគ្រប់អស់ហើយ, បញ្ហាខ្លះ ស្របនឹងព្រះសង្ឃបញ្ញត្តិ និងព្រះរាជក្រម ដែលបានចេញឲ្យប្រតិបត្តិជាផ្លូវការរួចមកហើយ, បញ្ហាខ្លះ ស្របនឹងព្រះសង្ឃប្រកាស, បញ្ហាខ្លះ ផ្ទួនគ្នានឹងបញ្ហានៃលោកអ្នកស្នើមុនក៏មាន, បញ្ហាខ្លះ ស្របទៅ

លើបញ្ហាពីឆ្នាំមុន ដែលមហាសន្និបាតបានដោះស្រាយរួចមកហើយក៏មាន, បញ្ហាខ្លះទៀត ពិនិត្យទៅឃើញថា ពុំសូវមានប្រយោជន៍ក៏មាន, បញ្ហាទាំងអស់នេះ គណៈកម្មការការិយាល័យ មិនបានលើកយកទៅឲ្យមហាសន្និបាតដោះស្រាយទេ ។

នៅថ្ងៃបញ្ចប់មហាសន្និបាត សម្តេចព្រះសង្ឃរាជ ទ្រង់មានព្រះបន្ទូលថ្លែងរៀបរាប់អំពីការប្រជុំមន្ត្រីសង្ឃ អស់រយៈវេលាចំនួន ៤ ថ្ងៃកន្លះនេះ ឃើញថា មានប្រយោជន៍ច្រើនយ៉ាង :

១. មន្ត្រីសង្ឃគ្រប់ឋានៈ នៅទីក្រុងភ្នំពេញ និង ខេត្តក្រៅ ក្នុងព្រះរាជអាណាចក្រកម្ពុជា បានមកជួបជុំស្គាល់គ្នាទៅវិញទៅមក ។

២. បានពិភាក្សាបញ្ហាផ្សេង ៗ ខាងព្រះពុទ្ធសាសនារួមជាមួយគ្នា ។

៣. បានដឹងថា ព្រះពុទ្ធសាសនា នៅខេត្តខ្លះ ចម្រើនរុងរឿង ខេត្តខ្លះ ពុំសូវចម្រើនរុងរឿង ។

នៅទីបំផុតចប់ សម្តេចព្រះសង្ឃរាជ ទ្រង់ជាព្រះប្រមុខនៃមហា-សន្និបាត ទ្រង់ថ្លែងសេចក្តីរៀបរាប់អំពីអនុសាវរីយ៍មហាសន្និបាតនេះ ថាមានប្រយោជន៍សំខាន់ដល់ព្រះពុទ្ធសាសនា ។ល។ បន្ទាប់មក សម្តេចព្រះសង្ឃរាជ ទ្រង់និមន្តមន្ត្រីសង្ឃទាំងអស់ក្នុងមហាសន្និបាត សូត្រធម៌ថ្វាយព្រះរាជកុសលចំពោះសម្តេចព្រះមហាក្សត្រិយានី ជាព្រះមាតាជាតិ និងសម្តេចព្រះប្រមុខរដ្ឋជាព្រះបិតាឯករាជ្យជាតិ សូមព្រះអង្គទ្រង់គង់នៅ

ប្រកបដោយព្រះបរមសុខ ក្នុងសិរីពេជសម្បត្តិ ទាំងមានព្រះជន្មាយុយឺនយូរ ជាងរយឆ្នាំ ដើម្បីជាទីពឹងពំនាក់ នៃប្រជាពលរដ្ឋទាំងឡាយតទៅទៀត ។

ម្យ៉ាងទៀត ពួកពុទ្ធបរិស័ទ នៅក្រុងភ្នំពេញ និង ខេត្តក្រៅខ្លះ មានសទ្ធា បានបរិច្ចាគទ្រព្យធន និង កម្លាំងកាយ ចូលមកជួយផ្គត់ផ្គង់ចង្ហាន់បិណ្ឌបាត ទាំងពេលព្រឹក ទាំងពេលថ្ងៃត្រង់ ប្រគេនមន្ត្រីសង្ឃ និងចៅអធិការខ្លះ ជាច្រើនរយអង្គ ដែលបាននិមន្តមក ក្នុងឱកាសអនុសំវច្ឆរមហាសន្និបាតទី ២១ នេះ សូមឲ្យអស់លោក-អ្នកទាំងឡាយ បានប្រកបដោយសេចក្ដីសុខ - ចម្រើនគ្រប់ ៗ គ្នា កុំបីឃ្លៀងឃ្លាតឡើយ !

អនុសំវច្ឆរមហាសន្និបាតទី ២១ នៃមន្ត្រីសង្ឃ ឆ្នាំ ១៩៦៥ បានបញ្ចប់សព្វគ្រប់ នៅម៉ោង ២២ នាថ្ងៃទី ២១ ខែមករា ឆ្នាំ ១៩៦៥ ក្រោមបរិយាកាសយ៉ាងប្រសើរបំផុត ។

| លេខាធិការ | ប្រធាន |
|---|---|
| នៃគណៈកម្មការការិយាល័យ | នៃគណៈកម្មការការិយាល័យ |
| អ៊ុម-ស៊ុម | កិម-ទួរ |

# ព្រះរាជាណាចក្រកម្ពុជា

## ឆាយាគណៈ មហានិកាយ

តាមសេចក្តីសម្រេច

របស់អនុសំវច្ឆរមហាសន្និបាតទី ២១ នៃមន្ត្រីសង្ឃ

ព.ស ២៥០៧ គ.ស. ១៩៦៤

( ចំនួនប្រាំបីសន្លឹក )

ឆាយានេះ បានសេចក្តីអនុមតិជាឯកច្ឆន្ទក្នុងពេលអនុសំវច្ឆរៈមហាសន្និបាត នៃមន្ត្រីសង្ឃទី ២១ ហើយក្រសួងធម្មការ និងក្រសួងសម្តេចព្រះសង្ឃរាជអនុញ្ញាត ឲ្យព្រះសង្ឃក្នុងព្រះរាជអាណាចក្រកម្ពុជា ប្រើជាផ្លូវការ ។

## ប្រកាសប្រឡងប្រជែងទំនៀម

## ទម្លាប់ខ្មែរ

## សម្រាប់ឆមាសទី ១ ឆ្នាំ ១៩៦៦

---

នៅឆមាសទី ១ គឺតាំងពីខែមករា ដល់ខែមិថុនា ឆ្នាំ ១៩៦៦ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារទំនៀមទម្លាប់ខ្មែរ ដោយបើកការប្រឡងប្រជែង ២ មុខគឺ:

១- អំពីកុលសម្ពន្ធផ្សេងៗ

២- អំពីល្ខោនប្រជាប្រិយខ្មែរ

*ដូច្នេះ អស់លោក-អ្នកទាំងឡាយ ជាស្ត្រី ជាបុរស ឬជាបុព្វជិត ដែលស្ម័គ្រចិត្តប្រឡង សូមសរសេរតែងអត្ថបទ តាមគោលបញ្ហាដូចរៀបរាប់ខាងមុខ* ឲ្យការណ៍ទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ យ៉ាងយូរបំផុត ត្រឹមថ្ងៃដាច់ ខែឧសភា ឆ្នាំ ១៩៦៦ គឺមុនដាច់ឆមាស ១ ខែ ។

ការប្រឡងប្រជែងនេះ មានរង្វាន់ ៤ ថ្នាក់ :

ថ្នាក់លេខ ១ . . . . . . ១.០០០៛០០

ថ្នាក់លេខ ២ . . . . . . ៨០០៛០០

ថ្នាក់លេខ ៣ . . . . . . ៦០០៛០០

ថ្នាក់លេខ ៤ . . . . . . ៤០០៛០០

បើអស់លោកណា ត្រូវការសរសេរអត្ថបទ ដូចខាងលើនេះ ដាក់ប្រឡង សូមសរសេរលើសៀវភៅ កុំសរសេរលើក្រដាស តែ ១ ឬ ២ សន្លឹកឡើយ ហើយសូមសរសេរនាម និង ទីលំនៅរបស់ខ្លួន ឲ្យច្បាស់លាស់លើក្រដាសស ១ សន្លឹក ដាក់ក្នុងស្រោមសំបុត្រដោយឡែក ជាមួយនឹងអត្ថបទនោះ យកទៅឲ្យក្រុមជំនុំផ្ទាល់ខ្លួន ក៏បាន ផ្ញើទៅតាមប្រៃសណីយ៍ ក៏បាន ដោយការខ្ចងសំបុត្រថា :

ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

(ផ្នែកទំនៀមទម្លាប់ខ្មែរ)

# គោលបញ្ហានៃការប្រឡង

## ១. អំពីកុលសម្ព័ន្ធផ្សេងៗ

នៅប្រទេសកម្ពុជាយើង មានកុលសម្ព័ន្ធរស់នៅលាយជាមួយអ្នកស្រុកច្រើនកន្លែងណាស់ ដូចជា គួយ ព្នង ស្ទៀង រដែ សម្រែ ស្អូច ព័រ ។ល។ ពួកនេះ ជាកុលសម្ព័ន្ធចាស់ ដែលចាត់ជាពួករដ្ឋវាសី (Autochtones) រស់នៅលើទឹកដីនេះ តាំងពីដំបូង ដែលមិនទាន់មានសាសន៍ដទៃ ចូលមកកាត់លាយឡំនៅឡើយ ។

ក្រៅពីកុលសម្ព័ន្ធដើម ស្រុកយើងនៅមានកុលសម្ព័ន្ធចំណូលខ្លះទៀត ដូចជា ពួកកុឡា (នៅប៉ៃលិន) និងជនជាតិចាម ដែលសព្វថ្ងៃ យើងហៅថា ខ្មែរឥស្លាម ។ ជនជាតិទាំងនេះ ពិតមែនតែមានដើមកំណើតមកពីប្រទេសក្រៅ ប៉ុន្តែតាំងពីចូលមកនៅក្នុងប្រទេសយើងហើយ ក៏តាំងយកទឹកដីនេះធ្វើជាមាតុភូមិខ្លួន រស់នៅប្រកបអាជីវកម្មយ៉ាងសុខសាន្តរហូតមក (សូមកុំរាប់ចិន, វៀតណាម, ឥណ្ឌា, ពួកអឺរ៉ុប ព្រោះពួកនេះ ជាជនបរទេសទេ) ។

កុលសម្ព័ន្ធទាំងពីរបែប ដែលរាប់រៀបខាងលើនេះ ទោះបីមានសញ្ជាតិពេញច្បាប់ជាខ្មែរហើយ ក៏ប៉ុន្តែអ្នកទាំងនេះ នៅថែរក្សាទំនៀមទម្លាប់ដើមរបស់គេ យ៉ាងខ្ជាប់ខ្ជួនណាស់ រហូតមកដល់គ្រាសព្វថ្ងៃ ។

តែទំនៀមទម្លាប់ទាំងនោះ នៅចេះដឹងតែក្នុងចំណោមអ្នកនៅភូមិស្រុកជាមួយគ្នា ឬជិតខាងគ្នា ប៉ុណ្ណោះ ចំណែកអ្នកដែលមិនធ្លាប់ទៅដល់ ឬទៅឃើញភូមិភាគនោះៗ ផ្ទាល់ខ្លួនទេ ទំនៀមទម្លាប់ទាំងនេះឯង ក៏នៅជាអាថ៌កំបាំង ឬជាការចម្លែកមួយ ដែលខ្លួនពុំដែលធ្លាប់ឃើញសោះ ។

អាស្រ័យហេតុនេះ ក្រុមជុំនុំទំនៀមទម្លាប់ ត្រូវការប្រមូលយកឯកសារទាំងអស់ ដែលទាក់ទងដោយជីវភាព នៃពួកកុលសម្ព័ន្ធទាំងនេះ សម្រាប់តម្កល់ទុកឲ្យអ្នកជាន់ក្រោយ ឬអ្នកត្រូវការស្រាវជ្រាវ ស្គាល់នូវអារ្យធម៌បុរាណរបស់ជនទាំងនោះផង ។

ដើម្បីឲ្យបានងាយស្រួលចំពោះអ្នកសរសេរទៅប្រឡងក្នុងពេលនេះ យើងសូមធ្វើជាគោលសេចក្ដីខ្លះៗ សម្រាប់បំភ្លឺ ដូចតទៅ :

## ក- អំពីស្ថានភាពនៃភូមិស្រុក

ភូមិលំនៅរបស់កុលសម្ព័ន្ធ ដែលលោកអ្នកអធិប្បាយនោះ ជាភូមិចាស់ ឬ ជាភូមិថ្មី តាំងឡើងពីកាលណា? ស្ថានភាពភូមិនោះ មានរាងដូចម្ដេច ? ជាទីទួល ជាច្រកភ្នំ ជាមាត់អូរ ។ល។ មានឈ្មោះថាភូមិអ្វីខ្លះ តាមភាសាដើមរបស់គេ? បើប្រែជាភាសាខ្មែរមានន័យថាម៉េច ? សព្វថ្ងៃតាំងនៅ ក្នុងឃុំ - ស្រុក - ខេត្តណា ? ។ ឯរឿងរ៉ាវទាក់ទងនឹងភូមិនោះ មាននិទានដូចម្ដេចខ្លះ ?

## ១- អំពីទំនៀមក្នុងគ្រួសារ

ទំនៀមក្នុងគ្រួសារនេះ សូមកប់រៀបតាំងពីពេលដែលមានកូនកើត គេនិយមធ្វើបែបម៉េច? ដូចជា ការផ្តល់ទន្លេ-បង្កក់ឆ្នប-ដាក់ឈ្មោះ ។ល។ លុះកូនធំដឹងក្តីឡើង តើគេបង្ហាត់បង្រៀនដូចម្តេច? លុះពេញវ័យកម្លោះក្រមុំហើយ គេធ្វើដូចម្តេច ? មុនពិធីរៀបការ ពេលរៀបការ គេធ្វើដូចម្តេចខ្លះ ? ក្រោយរៀបការ គេមានបាត់បែងបែកមតិក ឬ ប្រៀនប្រដៅដូចម្តេច ? លុះដល់មនុស្សនេះចាស់ គេនិយមទុកដាក់មនុស្សនេះជាអ្វី ? បើមានមនុស្សស្លាប់ គេមានជំនឿដូចម្តេច ចំពោះខ្មោចនោះ ? ចូរនិយាយពីសំលៀកបំពាក់ និង ផ្ទះសម្បែងអ្នកភូមិនោះផង ។

## គ- អំពីការទាក់ទងគ្នាក្នុងភូមិនិងក្រៅភូមិ

តាមពិត ពួកកុលសម្ពន្ធទាំងនោះ មានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធណាស់ក្នុងភូមិមួយ ។ ដូចជា មានបង្កើតឲ្យមានអ្នកកាន់កាប់ការជាមេភូមិ ជំនួយភូមិ ឬ មេកន្ត្រាញ សម្រាប់ចាត់ការលើអ្នកភូមិទាំងមូល ។ ក្នុងការរស់នៅផ្សេង ៗ តើគេលើកគ្នាទៅជួយឲ្យហើយការនោះម្តងម្នាក់ ៗ ឬទេ? បើមានអ្នកស្រុកក្រៅទៅដល់ភូមិ គេនិយមអ្នកនេះដែរឬអ្វី ? ។

## ឃ- អំពីរបរចិញ្ចឹមជីវិត

ពួកកុលសម្ពន្ធទាំងនោះ និយមរបរអ្វីជាសំខាន់ ហើយជាបន្ទាប់បន្សំមក មានរបរអ្វីទៀត? ចូរកប់រៀប ពីរបៀបធ្វើរបរទាំងនោះឲ្យ

សព្វគ្រប់ តាំងពេលវេលាធ្វើបរនោះ ប្រដាប់ប្រដាសម្រាប់ធ្វើបរនោះ ផលដែលកើតពីបរនោះផង ។

## ង- អំពីជំនឿ និង ពិធីផ្សេង ៗ

កុលសម្ពន្ធនោះ មានជំនឿអ្វីខ្លះ? ដូចជាអារក្ស បង់បត់ ឬ លទ្ធិ-សាសនាណាមួយ ៗ ក្នុងការគោរពជំនឿនោះ គេមានទម្លាប់រៀបចំគ្រឿងសក្ការៈដូចម្តេចខ្លះ? ពិធីបូជាដោយសក្ការៈនេះ គេធ្វើយ៉ាងណាខ្លះ ? ឯពិធីសំខាន់ ៗ ប្រចាំឆ្នាំរបស់គេ មានអ្វីខ្លះ ? ចូររាប់រៀបពីរបៀបធ្វើពិធីសំខាន់ ៗ តាំងនោះ មួយម្តង ៗ ឲ្យបានច្បាស់លាស់ ៗ ក្រៅពីពិធីប្រចាំឆ្នាំ មានពិធីធំ ៗ ក្នុងគ្រួសារ មានអាពាហ៍ពិពាហ៍ បុណ្យខ្មោចជាដើម តើគេធ្វើបែបណាខ្លះ ? សុំពន្យល់ឲ្យក្បោះក្បាយក្នុងពិធីមួយ ៗ ផង ។

ឯរឿងរ៉ាវដទៃទៀត ដែលយើងនឹកមិនឃើញ និងមិនបាននាំយកមកចុះក្នុងគោលបញ្ហានេះក៏ដោយ បើលោកអ្នកជ្រាប ក៏សូមសរសេរផ្ញើមកផង បើបានហេតុផលច្រើន ក៏រឹតតែប្រសើរឡើងដែរ បើមានទាំងរូបថតបញ្ជាក់ផង ក៏រឹតតែសំខាន់ណាស់ទៅទៀត ។

## ២- អំពីល្បោងប្រជាប្រិយខ្មែរ

ប្រទេសនីមួយ ៗ តែងមានទំនៀមខាងសិល្បៈ ច្រើនបែបច្រើនយ៉ាងណាស់ តាំងពីបែបបទចាក់ក្បាច់លោតកំផ្សេង ៗ រហូតដល់ចាត់

ចែងជាធាតុធំដុំមានជារឿងរ៉ាវពីព្រេះពិសាយ៉ាងល្អមើលឡើង ដែលគេហៅថា « ព្រួង » ។

ប្រទេសកម្ពុជាយើង ក្រៅពីរបាំព្រះរាជទ្រព្យ ដែលមានគោលចារឹកច្បាស់លាស់នោះ, នៅមានល្ខោនសម្រាប់បម្រើអ្នកស្រុកស្រែចំការ ឬទីប្រជុំជនផ្សេងៗ ច្រើនបែបណាស់ ដូចជា : ល្ខោនស្រមោល មានណាំងឬស្បែកធំ, ស្បែកតូច, ល្ខោនយន្ត, ល្ខោនខោល, ល្ខោនបាមោជ័យ, ល្ខោនបាសាក់, ល្ខោនជៅ (ទៅសៀមរាប) ។ល។ ល្ខោនទាំងនេះ សុទ្ធតែមានរបៀបបច្ចេកទេសប្លែកៗគ្នា ហើយដែលសព្វថ្ងៃនេះ ខ្លះក៏បាត់បង់រូបអស់ទៅហើយ ឯខ្លះទៀតមិនទាន់បាត់ទេ ក៏ប៉ុន្តែចេះតែឃ្លៀងឃ្លាតពីគោលដើមបន្តិចម្តង ៗ ទៅដែរ បើយើងពុំប្រមូលយកឯកសារមកទុកជាគោលចារឹកទេ ថ្ងៃក្រោយទៅទៀត នឹងបាត់ជាន់សូន្យជាមិនខាន នាំឲ្យស្តាយច្រើន ព្រោះសិល្បៈអស់នេះ ក៏ជាសាខានៃអារ្យធម៌ជាតិ ដ៏សំខាន់ណាស់ ។

សម្រាប់ជួយបំភ្លឺអ្នកប្រឡូងឲ្យងាយ ក្នុងការសរសេរឯកសារនេះ យើងដៅជាគោល ៗ ខ្លះ ដូចខាងក្រោម :

## ក- អំពីដើមកំណើត

ក តើល្ខោននេះ មានឈ្មោះប្រាកដថាអ្វី? អ្នកហៅក្លាយថាអ្វី ? មានច្រើន នៅក្នុងស្រុក-ខេត្ត ណា ?

១- សូមនិយាយពីកំណើតដើមនៃល្ខោននេះ តើមានពីគ្រឹមពីសម័យណាមក ? នរណា ឬ ក្រុមណា ឬ សាសន៍ណា ជាអ្នកបង្កើត ? តាំងពីកើតដល់ឥឡូវ មានកែប្រែដូចម្ដេចខ្លះ ?

## ១- អំពីរបៀបរៀបចំសម្ដែង

៣- អំពីតួ.- តើតួនីមួយ ៗ មានកាក់កែងកាយប្លែកគ្នាត្រង់ណា ក្នុងពេលចេញសម្ដែង ? ដូចជាការចេញដើរ ការលោតហក់ចាក់ក្បាច់ ការរាំ តើតួណា ត្រូវធ្វើដូចម្ដេច ៗ ? ។

២- អំពីការសម្ដែង.- សូមបញ្ជាក់ពីរបៀបរៀបចំក្នុងកន្លងឆាកនីមួយ ៗ ដែលតួចេញមកសម្ដែងនោះ មានរបៀបរៀបចំឆាករបៀបបញ្ចេញកាយវិការប្លែក ៗ គ្នា តាមរឿង តាមបង្អាក់ ដូចជា: ឈុតត្រូវកេកាយ, ត្រូវកំសត់, ត្រូវធ្វើសង្គ្រាម, ត្រូវលួងលោម ឬត្រូវកំប្លែង ។ល។

៣- បទភ្លេង.- បទដែលគេត្រូវពោល ឬ ត្រូវច្រៀងក្នុងល្ខោនដែលលោក-អ្នកអធិប្បាយនោះ មានបទអ្វីខ្លះ ? ហើយបទនីមួយ ៗ សម្រាប់ប្រើក្នុងឆាកណា ? ឆាកទុក្ខ, សប្បាយ, សង្គ្រាម ។ល។ ឯទំនុក មានសេចក្ដីថាម៉េច ? (បើមិនចាំច្រើន គ្រាន់តែប្រាប់ដើមបទខ្លះ ៗ ក៏បាន ) ។

## គ- អំពីប្រដាប់ប្រដា

១- សូមពប់របៀបពិស្ដារភាពក្នុងដែលសម្ដែងនោះ ជាកេងធ្វើបណ្ដាះអាសន្ន ឬ កេងជាប់លាប់ មានរបៀបចំបែបណា ?

២- គ្រឿងប្រដាប់តុបតែងនៅក្នុងកេងនោះ មានអ្វីខ្លះ ? ដូចជា នាំង , ពាំងនន , តុ , កៅអី ។ល។

៣- គ្រឿងអលង្ការសម្រាប់តុបតែងតួរាំ មានអ្វីខ្លះ? គ្រឿងស្លៀកពាក់, មកុដ, សង្វារ , ស្បែកជើង , កងដៃ, កងជើង ។ល។ ហើយតួដែលលេងជាមុខងារអ្វីនីមួយ ៗ មានគ្រឿងតែងប្លែកគ្នាយ៉ាងណាខ្លះ ?

៤- គ្រឿងភ្លេងសម្រាប់ផ្សំជាមួយល្ខោននោះ មានអ្វីខ្លះ? សូមពប់មួយមួង ៗ អំពីប្រដាប់ភ្លេងនោះ បើគូរជារូបបាន ក៏រឹតតែប្រសើរណាស់ ។

## ឃ- អំពីទំនៀមទម្លាប់

១- តើល្ខោនដែលលោក-អ្នកអធិប្បាយនេះ មានពាក់ទងនឹងទំនៀមទម្លាប់ ដូចម្ដេចខ្លះ? ដូចជា លេងល្ខោនថ្វាយព្រះ ថ្វាយអ្នកតាជាដើម ។

២- ទំនៀមរើសកូនល្ខោនឲ្យចូលរៀនសម្ដែង តើគេធ្វើដូចម្ដេចខ្លះ? របៀបបង្ហាត់យ៉ាងណា ?

៣. របៀបរើសរឿងយកមកលេង តើគេនិយមដូចម្តេច? រឿងណា សម្រាប់លេងនៅពេលណា ?

៤. រណ្តាប់ថ្វាយគ្រូមានអ្វីខ្លះ ? គេត្រូវឲ្យកូនល្ខោននោះគោរពគ្រូបែបណា ? ។

សេចក្តីដែលជាគោលគំនិត ពន្យល់មកហើយនេះ ពុំទាន់បានសព្វគ្រប់ទេ បើលោក-អ្នកនឹកឃើញថាមានការអ្វីប្លែកទៅទៀត ក៏សូមសរសេរបញ្ចូលមកផង គឺថា បើបានន័យច្រើន ក៏រឹតតែប្រសើរណាស់ទៅទៀត ។

សេចក្តីបញ្ជាក់ = អត្ថបទដែលបេក្ខជនសរសេរដាក់ទៅប្រឡង ទោះបីជាប់ក្តី មិនជាប់ក្តី ត្រូវទុកជាសម្បត្តិរបស់ក្រុមជំនុំតទៅ មិនបង្វិលឲ្យសាមីខ្លួនវិញទេ ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# សេចក្តីកត់ហេតុនៃការប្រជុំការងារទី ៣

# នៅពុទ្ធសាសនបណ្ឌិត្យ ថ្ងៃ ១៥-៩-៦៥

ឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំ ថ្ងៃទីដប់ប្រាំ ខែកញ្ញា វេលាម៉ោង ១០ ព្រឹកមានការប្រជុំការងារមួយនៅក្រោមអធិបតីភាពនៃ សហ. លាង-ហាប់អាន ជានាយកនៃពុទ្ធសាសនបណ្ឌិត្យ ដោយមានសមាជិកមករួមប្រជុំផង គឺ :

១. សហជីវិន វៀល-ហេង អគ្គលេខាធិការ
២. – ញ៉ុង-សៀង អគ្គលេខាធិការរង
៣. – ឈឹម ណាក នាយការិយាល័យគណនេយ្យ
៤. សហជីវិនី ពេជ្រ សល់ – ទំនៀមទម្លាប់
៥. សហជីវិន ឌុក-គាម – ព្រះពុម្ពផ្សាយ
៦. – ស៊ីង-ផន – បណ្ណាល័យ
៧. – លី-ធាមតេង សមាជិកទំនៀមទម្លាប់
៨. – ទុន-សោម គណនេយ្យករកាន់បញ្ជី

ជាបឋម បន្ទាប់ពីសេចក្តីថ្លែងអំគុណរបស់លោកនាយក ចំពោះទីប្រជុំរួចហើយ សហ. នាយកបានថ្លែងជំរាបទីប្រជុំអំពីសកម្មភាពខ្លះ ៗ ដែលលោកបានធ្វើរួចមកហើយពីថ្ងៃមុនដូចជា :

-បានទាក់ទងជាមួយក្រសួងអប់រំជាតិ ដើម្បីសុំឲ្យគេជួយជាវ និងជួយផ្សាយសៀវភៅយើង ដោយបានតាំងនាំយកសៀវភៅជាច្រើនក្បាល ទៅថ្វាយទ្រង់ទេសរដ្ឋមន្ត្រីផង ។ ក្រសួងនេះ ក៏បានសន្យាថានឹងជួយតាមសេចក្តីស្នើសុំ ។

-បានទាក់ទងជាមួយបណ្ណាល័យជាតិ ដើម្បីសុំសៀវភៅគេខ្លះ ត្បិតនៅឯនោះ មានច្បាប់គេតម្រូវឲ្យអ្នកបោះពុម្ពផ្សាយ យកទៅតម្កល់ ៨ ច្បាប់គ្រប់ ១ រឿង ក្រែងមាននៅសល់ក្នុងចំណោមនោះខ្លះ សុំរំលែកយកទុកនៅបណ្ណាល័យយើងខ្លះ ។ លោកអភិរក្សបណ្ណាល័យជាតិ ក៏បានសន្យាថានឹងជួយផ្តល់ឲ្យត ៗ ទៅទៀត ឯសៀវភៅចាស់ពីមុនមក លោកបានផ្តល់ឲ្យយើងខ្លះ ៗ មកហើយដែរ ។

អំពីកន្លែងក្រុមជំនុំព្រះត្រៃបិដក លោកនាយកបានទាក់ទងជាមួយសម្តេចព្រះពោធិវង្សហើយ ព្រះអង្គបានទទួលធានាបន្តមុខងារជាអធិបតីក្រុមជំនុំនេះហើយ ចំពោះកន្លែងវិញទំនងជាព្រះអង្គសព្វព្រះទ័យរំលែកឲ្យកន្លែងថ្មីមួយដែរ ចាំកាលណាលោកធ្វើរួចហើយ ។

-ចំពោះមូលនិធិអាស៊ី លោកបានធ្វើការទាក់ទងរួចហើយ ហើយគេបានតាំងមកគួរសមដល់កន្លែងយើងផង ។ ការទាក់ទងនេះ យើងមានប្រាថ្នានឹងស្នើសុំជំនួយខ្លះ សម្រាប់រៀបចំបណ្ណាល័យ និងខាងទំនៀមទម្លាប់ ។

-ចំពោះសេចក្តីព្រាងព្រះរាជក្រឹត្យ សម្រាប់រៀបចំអង្គការគ្រឹះស្ថាន-សាសនបណ្ឌិត្យ ដើម្បីកុំឱ្យយឺតយូរដោយពិបាកលើកយកមកជំនុំពិនិត្យញយ ៗ ពេកនោះ លោកបានសម្រេចយកតាមសេចក្តីព្រាងរបស់សហ អគ្គលេខាធិការ រួចហើយចាំបាច់ឱ្យរាយអង្គលីលេខ ចម្លងឱ្យបានច្រើនចប់ចែកគ្នាពិនិត្យមើល ហើយជួបជុំគ្នាម្តងទៀត ដើម្បីបញ្ជូនទៅស្នើដល់រាជការមុខក្រសួង ។

បន្ទាប់ពីនោះមក លោកនាយក ក៏លើកយកបញ្ហាដែលចុះក្នុងរបៀបវារៈមកពិភាក្សា គឺ ;

## បញ្ហាបោះពុម្ពផ្សាយ

ដើម្បីឱ្យល្អិតល្អន់ លោកនាយកបានលើកយកសេចក្តីសង្ខេបមួយរបស់ សហជីវិន អៀល-ហេង ដែលធ្វើជាអក្សរប្រាក់មាន ២ ទំព័រ គឺ ១ ទំព័រ ស្តីពីការសង្កេតលើរបៀបលក់សៀវភៅ ហើយមួយសន្លឹកទៀតស្តីពីស្ថានភាពនៃប្រាក់ចំណូលនៅពុទ្ធសាសនបណ្ឌិត្យ មកពិភាក្សា ៗ

ក- អំពីស្ថានភាពប្រាក់ចំណូល :

សេចក្តីសង្កេតនេះ បានចោទជាបញ្ហាថា សព្វថ្ងៃប្រាក់ចំណូលពីការលក់សៀវភៅ មានចែកជាបីប្រភេទ គឺ :

១- ផ្នែកសៀវភៅ ដែលបោះពុម្ពផ្សាយដោយថវិកាជាតិ

២- ផ្នែកដែលបោះពុម្ពផ្សាយ ដោយប្រាក់ធម្មសម្បត្តិរបស់ក្រសួង-ធម្មការ ។

៣- ផ្នែកសៀវភៅ ដែលបោះដោយប្រាក់ជំនួយពីមូលនិធិអាស៊ី ចំនួន ៧ ក្បាល ។

ដើម្បីឲ្យបានទីប្រជុំយល់ច្បាស់ លោកនាយកបានសុំឲ្យសហជីវិន ឈឹម-ណាក ជានាយការិយាល័យគណនេយ្យ ពន្យល់ពីដើមកំណើតនិង វិធីចាត់ចែងប្រាក់ចំណូលក្នុង ខ ទី ១ និង ខ ទី ៣ ។ ឯប្រាក់ក្នុង ខ២ ជា ប្រាក់ធម្មសម្បត្តិនោះ មិនបាច់លើកមកពិចារណាទេ ត្បិតមានលក្ខខណ្ឌ ត្រឹមត្រូវតាមព្រះរាជក្រិត្យតម្រូវឲ្យអនុវត្តមានរបៀបត្រឹមត្រូវហើយ ។

ពេលនោះ សហ. ឈឹម-ណាក ពន្យល់ទីប្រជុំថា ចំពោះសៀវភៅ បោះពុម្ពដោយថវិកាជាតិ ពុំមានការអ្វីជាសង្កេតទេ ព្រោះមានលក្ខខណ្ឌ ច្បាប់សម្រាប់អនុវត្តស្រាប់ហើយ គឺយើងបានថវិកាអនុញ្ញាតមកប៉ុន្មាន ក៏ចាត់ចែងបោះពុម្ពប៉ុណ្ណោះទៅ ហើយលក់យកប្រាក់មកដាក់ឃ្លាំងវិញ ក្នុងមួយឆ្នាំ ៗ តែងតែបានកើនហួសពីប្រាក់ថវិកាអនុញ្ញាតនោះជាដរាប ។ ចំពោះសៀវភៅដែលបោះពុម្ពដោយប្រាក់មូលនិធិអាស៊ីនោះ ទាំងអស់ ៧ ឈ្មោះ ។ ប្រាក់នេះទាំងអស់មានចំនួន ២០០.០០០ រៀល គេសម្រាប់ ឲ្យចាត់ការបោះពុម្ព ហើយលក់យកប្រាក់មកបោះពុម្ពលើកក្រោយ ៗ និង សម្រាប់ចាយវាយក្នុងកិច្ចការចាំបាច់ខ្លះ ដែលជាការប្រញាប់

ហើយដែលពុំបានគ្រាន់ទុកក្នុងថវិកា ។ ដូច្នេះហើយ បានជាសព្វថ្ងៃ ដោយត្រូវចាយបោះពុម្ពជាថ្មីផង និងចំណាយចាំបាច់ខ្វះផង យើងនៅសល់ប្រាក់នេះតែប្រាំពីរពាន់រៀល «៧.០០០» ទេ ។

ទីប្រជុំបានសាកសួរថា បើប្រសិនជាយកសៀវភៅទាំងអស់នេះលក់តែម្ដង តើយើងអាចបានប្រាក់ប៉ុន្មាន ។

សហ. ឈឹម ណាក ថា អាចបានប្រហែលដប់ម៉ឺនរៀល ដូច្នេះទីប្រជុំយល់ថា គួរតែយើងលក់ទាំងអស់ហើយយកប្រាក់មកទុកមួយកន្លែង គឺផ្ញើនឹងធនាគារណាមួយ ទុកក្នុងក្រសួងសម្រាប់ចាយរាយពារង៍កុំឲ្យលើសពីប្រាំពាន់រៀល ហើយនឹងចាយរាយបាន ឬ ដកចេញពីធនាគារបាននោះ លុះត្រាតែមានសម្រេចគ្នាពីនាយក អគ្គលេខាធិការ និងនាយកគណនេយ្យ ។

ទីប្រជុំសម្រេចថា ត្រូវធ្វើជាច្បាប់ទម្លាប់បង្កើតបេឡាពិសេសនេះឡើង ឲ្យត្រឹមត្រូវតាមលក្ខណៈច្បាប់ គឺមានប្រកាសក្រសួងតាត់ទុកប្រាក់នេះ ជាបេឡាសម្រាប់បង្វិល ( Fonds de roulement ) ក្នុងការបោះពុម្ពរបស់យើង ។

១- អំពីរបៀបលក់-ផ្សាយសៀវភៅ :

មុននឹងពិភាក្សាតទៅ ទីប្រជុំបានពិនិត្យសេចក្ដីសង្កេតរបស់ សហ. រៀល ហេង ដែលបានកំណត់យកប៉ពីហេតុផលខ្វះ ដែលធ្វើសៀវភៅយើង

ពុំសូវបានដើរស្រួល ប៉ុន្តែសរុបទៅមានតែពីរទេ ដែលលោកបានចុចជាគោលគឺ :

១- គួរតែឲ្យរថយន្តលក់សៀវភៅ ចេញទៅលក់បានយ៉ាងតិចក្នុង ១ ខែម្តងដែរ ព្រោះសម្រាប់ផ្សាយផង និងយកការណ៍ឲ្យច្បាស់នៅក្នុងមជ្ឈដ្ឋានវត្តទាំងឡាយឲ្យដឹងថា តើគេត្រូវការសៀវភៅអ្វីជាសំខាន់ផង ។

ប៉ុន្តែចំពោះចំណុចនេះ ដោយហេតុថា សហ. អនុរដ្ឋលេខាធិការធម្មការ បានបាត់ឲ្យរកលេខល្បងមើល កាលពីថ្ងៃមុនទៅឃើញថា ពុំបាច់ចេញរថយន្តទៅទៀតទេ ឲ្យតប្រាក់ចំណូល បើធៀបនឹងចំណាយថ្លៃសាំង សោហ៊ុយជួសជុលរថយន្ត ជាដើមទៅ ក៏នៅតែឃើញខាតបើដូចេះគួរតែផាកសិន ។

២- ត្រូវតម្លើងរង្វាន់ឲ្យអ្នកទទួលទៅលក់បាន ២០ ភាគរយ ដែលសព្វថ្ងៃឲ្យតែ ១០ ភាគរយប៉ុណ្ណោះ ។

ចំពោះចំណុចនេះ ទីប្រជុំថាគួរណាស់ - ទម្រាំតែព្រះករុណាក្រិត្យស្តីពីការរៀបចំពុទ្ធសាសនបណ្ឌិត្យបានសម្រេចចេញរួចមក គប្បីសុំឲ្យចេញជាសេចក្តីសម្រេចពីក្រសួងធម្មការមួយអនុញ្ញាតថា នឹងឲ្យរង្វាន់ ២០ ភាគរយចំពោះជនណា ដែលទិញសៀវភៅមានតម្លៃចាប់ពីប្រាក់មួយរយរៀល (១០០៛០០) ឡើងទៅ មិនប្រកាន់ចំពោះតែបណ្ណាគារមានប៉ាតង់ដែលទទួលជាវជុំ ឬអ្នកជាវធម្មតាឡើយ ។ ក្នុងសេចក្តីសម្រេចនោះទៀត ត្រូវសុំអនុញ្ញាតឲ្យយើងតម្លើងប្រាក់បន្ថែម (Majorations) ពី

១៩ ភាគរយជាន់មុនទៅ ជា ៤០ ភាគរយលើថ្ងៃដើមគ្រប់សៀវភៅទាំងអស់ដែលយើងបោះពុម្ពផ្សាយ ។

— តមកទីប្រជុំយល់ថា យើងគួរតែទាក់ទងជាមួយពួកសហករណ៍ដើម្បីសុំឲ្យអង្គការនេះ ជួយផ្សាយដល់សាខាគ្រប់ខេត្ត ឲ្យជួយជាវសៀវភៅយើងផង ។

— ចំពោះកន្លែងលក់នៅស្ថានីយរថភ្លើង ដោយយល់ថាពុំសូវជាប់ផងហើយខ្វះបុគ្គលិកផង ទីប្រជុំសុំឲ្យហៅយកបុគ្គលិកយើងម្នាក់ ដែលចាត់ឲ្យទៅលក់ឯនោះ ឲ្យមកជួយនៅកន្លែងលក់ ឯពុទ្ធសាសនបណ្ឌិត្យយើងវិញ ។

— ចំណែកទស្សនាវដ្ដីកម្ពុជសុរិយា ទីប្រជុំសុំស្នើថា ឲ្យសើរើមើលតាំងពីឆ្នាំ ១៩២៧ មកដល់ ១៩៥៩ បើឆ្នាំណាមិនគ្រប់ក្បាលទេ យើងគួរតែចែកដល់វត្តនានាជាអំណោយទៅ ៤ ឆ្នាំដែលមានលេខគ្រប់នោះត្រូវទុកមួយអន្លើសម្រាប់ជាវបាន ។

— មុននឹងបិទពេលប្រជុំ លោកនាយកបានថ្លែងអំណរគុណជាទីឡារិកចំពោះ សហ. វៀល-ហេង ដែលបានខិតខំធ្វើសេចក្ដីសង្ខេបនេះបានច្បាស់លាស់ល្អណាស់ ជាការជួយបំភ្លឺដល់ទីប្រជុំ ។ សេចក្ដីសរសេរនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរផង ។

ដោយឃើញថាអស់បញ្ហាហើយ លោកប្រធាននៃទីប្រជុំក៏ប្រកាសបិទពេលប្រជុំនៅម៉ោង ១២ កន្លះ នៅថ្ងៃខែឆ្នាំដូចខាងលើ ។

# សេចក្តីកត់ហេតុនៃការប្រជុំការងារទី ៤

# នៅពុទ្ធសាសនបណ្ឌិត្យ ថ្ងៃ ៥-១០-៦៥

ឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំ ថ្ងៃទីប្រាំខែតុលា វេលាម៉ោង ៩ ព្រឹក មានការប្រជុំការងារមួយ នៅក្រោមអធិបតីភាពនៃសហជីវិន លាង-ហ័បអាន ជានាយកនៃពុទ្ធសាសនបណ្ឌិត្យ ដោយមានសមាជិកមករួមប្រជុំផងគឺ :-

១- សហជីវិន វៀល-ហេង អគ្គលេខាធិការ

២ — ឈឹម ណាក នាយការិយាល័យគណនេយ្យ

៣- — ឌីក-គាម នាយការិយាល័យបោះពុម្ពផ្សាយ

៤- សហជីវិន ពេជ្រ-សល់ នាយការិយាល័យទំនៀមទម្លាប់

៥- សហជីវិន ស៊ូ-ប៊ូរ លេខាធិការនៃទីប្រជុំ

បន្ទាប់ពីសេចក្តីថ្លែងអំណរគុណចំពោះទីប្រជុំរួចហើយ សហជីវិន នាយក បានថ្លែងបំភ្លឺចំពោះអង្គប្រជុំ អំពីហិបប្រាក់ ពុទ្ធសាសនបណ្ឌិត្យ និងមូលនិធិអាស៊ី ។ សហជីវិន នាយកបានស្នើឲ្យទុកហិបទាំងពីរនេះ ជាធម្មតា តែត្រូវរៀបចំឲ្យបានស្រួលបួលឡើងវិញ ដោយធ្វើសេចក្តីកត់ហេតុតាមរបៀបចំណាយឲ្យត្រឹមត្រូវ ធ្វើជាលាយល័ក្សអក្សរ ក្នុងការរក្សាទុក និងក្នុងការចាយវាយ បិទទុកនៅក្នុងហិបប្រាក់ទាំងពីរនេះ ។

រីឯហិបប្រាក់ទាំងពីរនេះ យើងមិនត្រូវទុកខ្លួនឯងទេ ទុកបានបន្តិចបន្តួច តែមិនឲ្យហួសពី ៥ ០០០រ ទេ ។ សហជីវិន នាយក បានមានប្រសាសន៍ទៅកាន់អង្គប្រជុំថា បុះបើប្រាក់នោះលើសពី ៥.០០០រ ទៅ តើយើងត្រូវយកទៅទុកឯណា ? ពេលនោះសមាជិកអង្គប្រជុំក៏បានប្តូរយោបល់គ្នាយ៉ាងយូរ ហើយក៏បានសម្រេចដូចតទៅ :

១- ចំពោះប្រាក់ដែលតិចជាង ៥.០០០ រៀល :

–យើងត្រូវរក្សាទុកខ្លួនយើង ដើម្បីងាយក្នុងការចាយអ្វីបន្តិចបន្តួច ។

–នាយកនៃពុទ្ធសាសនបណ្ឌិត្យ ជាអ្នករក្សាទុកហិបប្រាក់ទាំង២ នេះ។

–នាយការិយាល័យគណនេយ្យ និង នាយការិយាល័យទំនៀមទម្លាប់ ត្រូវរក្សាទុកបញ្ជីចំណូល និង ចំណាយ ។

–បញ្ជីចំណូលចំណាយ ក្នុងមួយខែត្រូវបញ្ឈប់ម្តង ដោយយកទៅសុំលោកនាយក បញ្ជាក់ និង យល់ព្រមផង ។

២- ចំពោះប្រាក់ដែលលើសពី ៥. ០០ រៀលទៅត្រូវ :

–យកទៅដាក់ធនាគារខ្មែរពាណិជ្ជកម្ម ក្នុងនាមលោកនាយក ចាប់តាំងពីថ្ងៃដែលបានអនុញ្ញាតពីចៅក្រសួងធម្មការ ។

–លោកនាយក ត្រូវចុះហត្ថលេខាលើសន្លឹកមូលប្បទានប័ត្រ ។

· នៅពេលត្រូវការបើក លោកនាយកចុះហត្ថលេខាលើមូលប្បទានប័ត្រនោះ កាលណាយល់ឃើញថា ការចាយវាយនេះ ជាការចាំបាច់

ក្នុងក្រសួងពិតប្រាកដខានពុំបានមែន ។

២- របៀបចាយរាយត្រូវតាំងគណៈកម្មការមួយ

ក ចាយរាយតិចជាង ១.០៤០ រៀល

- ត្រូវសុំសេចក្ដីសម្រេចរបស់លោកនាយក តាមសេចក្ដីស្នើរបស់លោកអគ្គលេខាធិការ - លោកអគ្គលេខាធិការរង និងនាយការិយាល័យទាំងអស់ ក្នុងករណីណាដែលថវិការជាតិខ្វះខាត «ពុំបានគ្រោងទុក»។

ខ- ចាយរាយលើសពី ១.០០០ រៀល :

- ត្រូវដាក់ជូនក្រុមជំនុំ មានលោកនាយក - លោកអគ្គលេខាធិការ លោកអគ្គលេខាធិការរង និងនាយការិយាល័យទាំងអស់

- ចំណាយនិមួយ ៗ ត្រូវមានលិខិតបញ្ជាក់ មុនចំណាយចុះហត្ថលេខាអ្នកចំណាយ - អ្នកផ្គត់ផ្គង់ និងចុះហត្ថលេខាយល់ព្រមពីនាយកផង ។

៣- វិធីចាយរាយ :

ក- ហិបទី ១

- តាមអនុសញ្ញារបស់ក្រុមពុទ្ធសាសនបណ្ឌិត្យ និង មូលនិធិអាស៊ី ចុះថ្ងៃទី ៣០ មេសា ១៩៥៦ «មាត្រា ៤» ។

២- ចំណាយបានចំពោះការផ្សព្វផ្សាយវប្បធម៌ របស់ក្រសួងពុទ្ធសាសនបណ្ឌិត្យ

-ផាវព្រះត្រៃបិដក សម្រាប់បណ្ណាល័យ កំពង់ចាម

-ចំណាយចំពោះកិច្ចការវប្បធម៌ជាចាំបាច់ ក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យដូចជា :

ក. បោះពុម្ពសៀវភៅណាមួយជាថ្មីក្នុងចំណោមសៀវភៅ ៦ មុខ ដែលមូលនិធិអាស៊ីបោះឲ្យ

ខ. ចំណាយចំពោះការធ្វើបដិសណ្ឋារកិច្ច ក្នុងការទាក់ទងវប្បធម៌នានា

គ. ចំណាយក្នុងការចម្លងឯកសារចាស់ ៗ ទុកក្នុងបណ្ណាល័យ ឬដើម្បីបោះពុម្ពផ្សាយ

ឃ. ចំណាយក្នុងការទិញអត្ថបទសម្រាប់ទស្សនាវដ្ដីកម្ពុជសុរិយា

ង. ចំណាយចំពោះការជាវវត្ថុចាំបាច់ ដែលក្រសួងត្រូវការ ហើយគ្មានគ្រោងទុកក្នុងថវិកា «ចំណាយតិចតួច»

ខ ហិបទី ២

១. តាមអនុសញ្ញា របស់ក្រុមពុទ្ធសាសនបណ្ឌិត្យ ក្រុមជំនុំទំនៀមទម្លាប់ និង មូលនិធិអាស៊ី ចុះថ្ងៃទី ២ មេសា ឆ្នាំ ១៩៦៣ ។

២. ចំណាយចំពោះការឲ្យរង្វាន់ក្នុងពេលប្រឡងទំនៀមទម្លាប់ម្ដង ១ "កាលណាខ្វះថវិកាជាតិ " ។

៣. ចំណាយក្នុងការទិញឯកសារផ្សេង ១ របស់សមាជិក

៤-ចំណាយក្នុងដំណើរឲ្យអ្នកទៅស្រាវជ្រាវ ឯកសារទំនៀមទម្លាប់នៅតាមខេត្ត

៥. ចំណាយក្នុងការកែសម្រួលរៀងថ្មី សម្រាប់បោះពុម្ពផ្សាយរបស់ក្រសួង ខាងការិយាល័យទំនៀមទម្លាប់

៦- ចំណាយក្នុងការប្រែរឿងនានា

៧- ចំណាយក្នុងការទិញរបស់ផ្សេង ៗ សម្រាប់តាំងនៅសារមន្ទីរទំនៀមទម្លាប់

៨- ចំណាយសម្រាប់ជាវគំនូរ និងរូបថតពាក់ព័ន្ធខាងរឿងទំនៀមទម្លាប់

៩- ចំណាយក្នុងការទិញឯកសារចាស់ ៗ ដែលមាននិយាយ អំពីទំនៀមទម្លាប់

១០- ផ្តល់រង្វាន់ជូនអ្នកសរសេរសៀវភៅខាងទំនៀមទម្លាប់ ។

បញ្ជាក់ :- ចំណាយផ្សេង ៗ នេះ ត្រូវយោងទៅតាមសេចក្តីសម្រេចក្នុងវគ្គទី ២ «ក» និង «ខ» ។

មុននិងបិទពេលប្រជុំលោកនាយក បានថ្លែងអំណរគុណចំពោះអង្គប្រជុំសាជាថ្មីម្តងទៀត ទីប្រជុំក៏បានបិទពេលប្រជុំ នៅម៉ោង ១០ កន្លះព្រឹក នៅថ្ងៃ ៤ ឆ្នាំដដែលខាងលើ ។

# សេចក្ដីកត់ហេតុនៃការប្រជុំការងារទី ៥
# នៅពុទ្ធសាសនបណ្ឌិត្យ ថ្ងៃ ១៥-១០-៦៥

ឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំ ថ្ងៃទីដប់ប្រាំ ខែតុលា វេលាម៉ោងប្រាំបីព្រឹក មានការប្រជុំការងារមួយនៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្រោមអធិបតីភាពនៃសហជីវិន លាង-ហ័បអាន ដោយមានសមាជិកជាច្រើនរូបបានចូលរួមប្រជុំផងគឺ :

១- សហជីវិន ញុង សឿង អគ្គលេខាធិការង
២- — ឌឹក-គាម នាយការិយាល័យបោះពុម្ពផ្សាយ
៣- — អៀង-ស្យាង នាយឃ្លាំងសៀវភៅ
៤- — ទុន-សោម អ្នកកាន់បញ្ជីសារពើភណ្ឌ
៥- — សឹង ផន បណ្ណារក្ស
៦- សហជីវិនី ពេជ្រ សស់ នាយការិយាល័យទំនៀមទម្លាប់
៧- សហជីវិន សូ-ប៊ូវ លេខាធិការនៃទីប្រជុំ

មុនដំបូង សហជីវិននាយក បានថ្លែងសេចក្ដីអំណរគុណចំពោះអង្គប្រជុំទាំងអស់ រួចហើយក៏មានប្រសាសន៍ទៅទៀតថា ដើម្បីឲ្យមានសហប្រតិបត្តិការជិតស្និទ្ធជិតដល់នោះ យើងត្រូវតែប្ដូរយោបល់គ្នាទៅវិញទៅមក ៗ ជាពិសេស នាយការិយាល័យគ្រប់ផ្នែកនៅក្នុងក្រសួង ត្រូវ

បញ្ចេញយោបល់ជំកបដល់អង្គប្រជុំ នូវការប្រព្រឹត្តទៅនៃកិច្ចការរៀង ៗ ខ្លួន ដើម្បីឲ្យអង្គប្រជុំជួយដោះស្រាយ។បស័គ្គខ្វះ ដែលជាហេតុនាំឲ្យកិច្ចការយើងប្រព្រឹត្តទៅមិនបានស្រួល ។ យើងពិភាក្សាប្តូរយោបល់គ្នាយ៉ាងនេះ គឺធ្វើដើម្បីឲ្យក្រសួងយើងចម្រើនជឿនលឿនទៅមុខ តាមការដឹកនាំដ៏វៀងវៃនៃសម្តេចសហជីវិនតែប៉ុណ្ណោះ ។ សេចក្តីស្នើរបស់លោកនាយកនេះ ត្រូវអង្គប្រជុំយល់ព្រម និងសម្រេចតាមតាំងស្រុង ។

ដើម្បីកុំឲ្យខាតម៉ោងច្រើន សហជីវិននាយកក៏បានលើកបញ្ហាដែលចុះក្នុងរបៀបវារៈ មកជូនអង្គប្រជុំដោះស្រាយមួយម្តង ៗ ដូចតទៅនេះ :

## បញ្ហាទី១ឃ្លាំងសៀវភៅ បញ្ជីសៀវភៅមានរៀបរយតាមប្រក្រតី

ក- បញ្ជីព្រះត្រៃបិដក :

| | | | | |
|---|---|---|---|---|
| បញ្ជីទី ១ | – | ភាគ ១ | ដល់ | ២៥ |
| បញ្ជីទី ២ | – | ភាគ ២៦ | ដល់ | ៤៧ |
| បញ្ជីទី ៣ | – | ភាគ ៤៨ | ដល់ | ៦៧ |
| បញ្ជីទី ៤ | – | ភាគ ៦៨ | ដល់ | ៨៧ |

សេចក្តីសម្រេច :

ទី១- ឃើញថា បញ្ជីសៀវភៅព្រះត្រៃបិដកក្នុងឃ្លាំង ចាប់ពីភាគ ១ ដល់ ៨០ បានធ្វើរួចស្រេច មកត្រឹមថ្ងៃ ៣១ ធ្នូ ១៩៦៤ ។ បញ្ជីនេះមានភ្ជាប់មកជាមួយសេចក្តីកត់ហេតុនេះ ។

ទី២- ឲ្យសហជីវិន ធុន-សោម ផ្ញើបញ្ជីបន្តសៀវភៅព្រះត្រៃបិដក ចូលចេញនិងនៅសល់បន្ទាប់ពីបំណាច់ឆ្នាំ ១៩៦៤ មកទល់ថ្ងៃ ៣១ តុលា ១៩៦៥ រួចយកមកជូនលោកនាយកចុះហត្ថលេខាបញ្ជាក់ ។

ទី៣- ចាប់ពីដើមខែវិច្ឆិកាតទៅ បញ្ជីសៀវភៅព្រះត្រៃបិដកត្រូវបញ្ឈប់ ១ ខែម្ដង យកមកជូនលោកនាយកចុះហត្ថលេខាបញ្ជាក់ ។

១- បញ្ជីសៀវភៅផ្សេង ១ :

បញ្ជីនេះមានតាំងអស់ ៤ គឺ :

ទី ១- ពីអក្សរ «A» ដល់ «M» (N° 1 à 74)

ទី ២- — «M» ដល់ «P» (N° 75 à 149)

ទី ៣- — «P» ដល់ «Y» (N° 14 à 226)

ទី ៤- បម្រុះ

សេចក្ដីសម្រេច :

ទី ១- ឃើញថាបញ្ជីសៀវភៅទូទៅចំនួន ២៩៧ មុខ បានផ្ញើមកត្រឹមថ្ងៃ ៣១ ធ្នូ ១៩៦៤ ដូចមានភ្ជាប់មកជាមួយសេចក្ដីកត់ហេតុនេះ ។

ទី២- សុំសហជីវិន ធុន-សោម បន្តបញ្ជីសៀវភៅចាប់ពីឆ្នាំ ១៩៦៥ ឲ្យចប់ ក្នុងបញ្ជីទី ១ ដល់ទី ៤ មុនថ្ងៃ ៣១ តុលា ១៩៦៥ រួចយកជូនលោកនាយកចុះហត្ថលេខាបញ្ជាក់ ។

ទី៣- ចាប់ពីដើមខែវិច្ឆិកា តទៅបញ្ជីសៀវភៅតាំង ៤ ក្បាល

នេះត្រូវបញ្ជប់ ១ ខែមុន យកមកជូនលោកនាយកចុះហត្ថលេខាបញ្ជាក់ ។

## បញ្ហាទី ២ រឿងទស្សនាវដ្ដីកម្ពុជសុរិយាពីឆ្នាំ ១៩២៦ មកដល់ឆ្នាំ ១៩៥៨

ទី ១ - ទីប្រជុំបានសង្កេតឃើញថា ទស្សនាវដ្ដីនេះមានឆ្នាំខ្លះមិនគ្រប់លេខ សៀវភៅខ្លះចាស់ពុកផុយ រហែក ឬកណ្ដៀរកាត់ ហើយទីប្រជុំបានសម្រេចថា ធ្វើអំណោយចំពោះអ្នកជាវសៀវភៅ សម្រាប់ដាក់បណ្ណាល័យ ។

ទី ២ - ចំពោះទស្សនាវដ្ដីដែលគ្រប់ចំនួនលេខតាមឆ្នាំហើយ និងទស្សនាវដ្ដីពីឆ្នាំ ១៩៦៥ តទៅ សុំឲ្យសហជីវិន ទុន-សោម ធ្វើបញ្ជីចំនួនបោះពុម្ពលក់អស់និងសល់ ឲ្យបានមុនដាច់ខែវិច្ឆិកា ១៩៦៥ យកមកជូនលោកនាយកចុះហត្ថលេខាបញ្ជាក់ ។

៣- ចំពោះបញ្ជីអ្នកជាវប្រចាំឆ្នាំ និងបញ្ជីអំណោយ សុំឲ្យសហជីវិន អៀង-សេង្សាង យកមកជូនលោកនាយក ចុះហត្ថលេខាបញ្ជាក់

បញ្ជីនេះបានឃើញ :

ក- អ្នកជាវឆ្នាំ ១៩៦៥ មានចំនួន ៣១៩ នាក់

ខ- អំណោយនិងប្តូរវប្បធម៌ ៥៧ នាក់

សារុប ៣៧៦ នាក់

បញ្ហាគឺ :- ចំនួនបោះពុម្ពមួយលេខ ៗ ក្នុងឆ្នាំ ១៩៦៥ នេះ ចំនួន ៥.០ ក្បាល ។

## បញ្ហាទី ៣- បញ្ជីសារពើភណ្ឌ

ទី១- បញ្ជីអសង្ហារិម«immeuble» ពុំដែលមាន ។ ដូច្នេះ សុំឲ្យសហជីវិន ឈឹម-ណាក ធ្វើបញ្ជីនេះពយឈ្មោះអសង្ហារិម ជាកម្ម-សិទ្ធិរបស់រដ្ឋស្ថាន រួចយកជូនលោកនាយកចុះហត្ថលេខាបញ្ជាក់ ។

ទី២- បញ្ជីសង្ហារិម «mobilier» និងសម្ភារៈ «matériel» មានបញ្ជីជាប្រក្រតីទៀងទាត់ ។ សម្រេចសុំឲ្យសហជីវិន ឈឹម.ណាក នាយការិយាល័យគណនេយ្យប្រគល់ឲ្យសហជីវិន ស៊ិន-ស៊ីផុន ទទួលកាន់កាប់បន្ថែមទៅលើមុខការសព្វថ្ងៃ ។

បញ្ជីសង្ហារិមនិងសម្ភារៈនេះ សុំឲ្យអ្នកទទួលខុសត្រូវយកមកជូនលោកនាយកចុះហត្ថលេខាបញ្ជាក់ ។

## បញ្ហាទី ៤- រឿងបណ្ណាល័យ

ក- ខាងបណ្ណាល័យមានបញ្ជីចុះសារពើភណ្ឌ ឈ្មោះសៀវភៅទូទៅ ៣ ក្បាលចំពោះបណ្ណាល័យនេះ មានពយចំនួនសៀវភៅតាមផ្នែកមកត្រឹមដំណាច់ឆ្នាំ ១៩៦៤ ដូចតទៅនេះ :

១- សៀវភៅផ្នែកភាសាអឺរ៉ុប Fonds européen មាន ១៤-០១៧ ក្បាល

២- ទស្សនាវដ្ដីដែលបង់ហើយ ១.៨៧៩ ដែលមានចំនួនសារុប

ទាំងអស់ ៥.៦០៦ លេខ

៣- ទស្សនាវដ្ដីមិនទាន់បង់មានចំនួន ៦.៤៣១ លេខ

៤- ឯកសារជាក្រាំងនិងគម្ពីរស៊ូករិត ១៣.៤៧៨ ក្បាល ដែល

ចែកជា ១.៦៤៦ គម្ពីរ បើគិតជា អក្សរ ភាសា គឺមាន :

- ក្រាំងអក្សរខ្មែរ ៨២ ក្បាល

- ក្រាំងអក្សរសៀម ២២៣ ក្បាល

- សាស្ត្រាស៊ូករិត ១៣.១៧៣ ក្បាល

បញ្ជាក់ :-

១- សារុបសៀវភៅផ្នែកអក្សរបារាំង ២៦-០៥៤ ក្បាល

២- សារុបគម្ពីរ និងក្រាំង ១៣-៤៧៨ ក្បាល

៣- សារុបឯកសារទាំងអស់គង់បណ្ណាល័យមាន ៣៩-៥៣២ ក្បាល

ខ- សម្រេចឲ្យបណ្ណារក្ស ធ្វើបញ្ជីសៀវភៅចូលបណ្ណាល័យ គង់

ឆ្នាំ ១៩៦៥ បន្ថែមទៅដំណាច់ឆ្នាំ ជារៀងរាល់ឆ្នាំ ហើយយកមកជូន

លោកនាយកចុះហត្ថលេខាបញ្ជាក់និងទុកជាឯកសារមួយ ។ តទៅ ។

បន្ទាប់ពីសេចក្ដីថ្លែងអំណរគុណជាថ្មីចំពោះអង្គប្រជុំមក សហជីវិន

នាយកក៏បានប្រកាសបិទពេលប្រជុំ នៅម៉ោង ១០ គត់នាព្រឹក ថ្ងៃ ខែ

ឆ្នាំ ដូចខាងលើ ។